សមាគមបុគ្គលិកសិក្សាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត ~ សំភារៈ

២៣

# ទស្សនាវដ្ដី គ្រូបង្រៀន



ផ្ទះគ្រូបង្រៀន នៅក្រុងព្រះសីហនុ ចាប់ដំណើរការសាកល្បង

ខែ មេសា - ឧសភា - មិថុនា ឆ្នាំ ២០០៥

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | លិខិតជូនពរឆ្នាំថ្មី | ១ |
| ២ | វិចារណកថា | ២ |
| ៣ | ការចាត់តាំងការងាររបស់អ្នកគ្រប់គ្រង | ៤ |
| | **ទស្សនវិជ្ជាទូទៅ** | |
| ៤ | អំពីកំណត់ហេតុ | ៦ |
| ៥ | អត្ថិភាពនិយម | ៩ |
| ៦ | ការអប់រំសីលធម៌ និងការអប់រំសាសនា | ១១ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៧ | បុគ្គលិកលក្ខណៈ | ១៧ |
| ៨ | សង្គមកម្ម និងគ្រួសារ : ការលែងលះគ្នា | ១៩ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ៩ | ការអប់រំក្នុងសាលារៀនដ៏មានប្រសិទ្ធភាព | ២២ |
| ១០ | ភាសា : ក្រុមញាតិ | ២៦ |
| ១១ | ភាសា : អំណាន : សេចក្ដីសុខរបស់ប្រជាជន | ២៨ |
| ១២ | គណិតវិទ្យា : ចំណុះ | ២៩ |
| ១៣ | គំនូរ : វិធីបង្រៀនគំនូរ (ត) | ៣០ |
| | **នាទីកំសាន្ត និង កំសាន្ត** | |
| ១៤ | ឥស្សា | ៣២ |
| ១៥ | ចាស់ទុំជាមគ្គុទេសក៍ | ៣៣ |
| ១៦ | ដើមកំណើតរឿង "មួយពាន់ មួយយប់" | ៣៥ |
| ១៧ | ល្បែងផ្គុំអក្សរ | ៣៧ |
| | **វេទិកាស្នេហ៍** | |
| ១៨ | ពិធីធ្វើស្លឹករឹត (តចប់) | ៣៨ |
| ១៩ | ដើមទ្រូង ៥ ហត្ថ | ៤១ |
| ២០ | តើអ្នកគ្រូ លោកគ្រូដឹងដែរឬទេ...? | ៤២ |
| | **ព័ត៌មាន** | |
| ២១ | ចំនួនសាលារៀនតាមឃុំ-សង្កាត់ (ឆ្នាំសិក្សា ២០០៣-០៤) | ៤៣ |
| ២២ | វេទិកាស្ត្រី | ៤៥ |
| ២៣ | ស្ថិតិសព្វខែមករា-កុម្ភៈ-មីនា ២០០៥ | ៤៧ |



**គណៈកម្មការរៀបរៀង និង និពន្ធ**

- លោក កែវ យ៉ារ
- លោក ជុំ ហ៊ីន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ ទិត្យ
- លោកជំទាវ ប៉ែន ណារុល
- លោក ថោង បូរ៉ាន់
- លោក កៅ ជឿន
- លោកស្រី ប្រាក់ សូលីដា
- លោកស្រី នន់ សុភ្ញុំ
- លោក ប៉ែន សារុន
- សមាជិក-សមាជិកាស.ប.ស.ខ

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អ៊ាង
- លោកជំទាវ ហួរ ស៊ីរី
- លោកបណ្ឌិត អ៊ឹម កុច
- លោក ស៊ិន ស៊ុម
- លោក ស៊ុង វ៉ាន់ថន
- លោក ស្លួង សារុន

**វិចិត្រករ**

លោក ប៉ាន់ ត្រា

**ការីកុំព្យូទ័រ**

ក. ម៉ៃ សួនី

**ក្របខាងក្រៅ**

- ពីមុខ: ផ្ទះគ្រូបង្រៀនក្រុងព្រះសីហនុ
- ពីក្រោយ: ភ្នំពេញកាលពី១០០ឆ្នាំមុន



**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

កំពត : ០១២ ៨៥៦ ៧២២, ភ្នំពេញ : ០១២ ៨៩៧ ១៧៧, ក្រុងព្រះសីហនុ : ០១២ ៦៩៩ ៥៦០



# ជូនពរឆ្នាំថ្មី

## ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំ រកា សប្តស័ក

## ព.ស ២៥៤៩

## គណៈកម្មាធិការនាយក ស.ប.ស.ខ

សូមប្រសិទ្ធពរជ័យ សិរីមង្គលវិបុលសុខ មហាប្រសើរ ជូនចំពោះសមាជិក សមាជិកានៃសមាគមបុគ្គលិកសិក្សាខ្មែរទូទាំងប្រទេស សូមប្រកបបានសុខភាព ល្អបរិបូណ៌ អាយុយឺនយូរ និង មានពលានុភាពខ្លាំងក្លា ដើម្បីអភិវឌ្ឍការងារ អប់រំ និង ការងារសមាគមអោយបានរីកចំរើនរុងរឿងតរៀងទៅ ។

ជ.គណៈកម្មាធិការនាយក

ប្រធាន

យស់ អឹង

# ទិចារណកថា

## ការអប់រំសំរាប់ទាំងអស់គ្នា និងបញ្ហាអេដស៍

ការសិក្សាស្រាវជ្រាវថ្មីៗនេះរបស់យូណេស្កូ (UNESCO) អោយដឹងថា ពីពេលនេះដល់ឆ្នាំ ២០១៥ វិស័យអប់រំបឋមសិក្សាទូទាំងសកលលោក ត្រូវការគ្រូបង្រៀនថ្មីចំនួន ៣៥លាននាក់ ដើម្បីអោយការអប់រំសំរាប់ទាំងអស់គ្នាសំរេចគោលដៅរបស់ខ្លួន ។

បញ្ហាធំ ២ ត្រូវបានគិតថា ជាឧបសគ្គចំបងចំពោះការធ្វើអោយសំរេចគោលដៅនេះ ។ បញ្ហាទី១ គឺវិសមភាព( ភាពមិនស្មើគ្នា) រវាងភេទក្នុងវិជ្ជាជីវៈជាគ្រូបង្រៀន និងផលវិបាកនៃជំងឺអេដស៍ ។ ចំពោះបញ្ហាទី ២ ធនាគារពិភពលោកគ្រោងថា គ្រូបង្រៀនចំនួន ១៣៣ ០០០ នាក់នៃប្រទេសអាហ្វ្រិកខាងត្បូង (Afrique du Sud) និងចំនួន ២៤ ០០០នាក់នៃប្រទេស Tanzanie នឹងស្លាប់ដោយជំងឺអេដស៍ពីពេលនេះដល់ឆ្នាំ ២០១០យ៉ាង និងម្យ៉ាងទៀត ការសិក្សារបស់ UNESCO ក៏បង្ហាញដែរថា គ្រូបង្រៀនដែលបាត់បង់ជីវិតដោយសារជំងឺអេដស៍នៅក្នុងប្រទេសខ្លះ មានចំនួនច្រើនជាងគ្រូបង្រៀនដែលបណ្តុះបណ្តាលថ្មី ។ នេះជាមូលហេតុនាំអោយចំនួនបុគ្គលិកសិក្សាខ្វះបទពិសោធមានចំនួនថេរជានិច្ចក្នុងប្រទេសទាំងនោះ ឧទាហរណ៍ ÷

ក្នុងឆ្នាំ១៩៩៨ គ្រូបង្រៀនមានបទពិសោធដែលបានទទួលមរណភាពដោយជំងឺអេដស៍របស់ប្រទេស Zambie មានចំនួនស្មើនឹង ២/៣ នៃជំនាន់បណ្តុះបណ្តាលប្រចាំឆ្នាំនីមួយៗ ។ ប្រទេស Afrique Centrale បានបិទសាលារៀនរាប់សិបកន្លែងដោយសារហេតុផលនៃចំនួនគ្រូបង្រៀនដ៏ច្រើនដែលមានជំងឺអេដស៍ ។ នៅប្រទេស Malawi ការស្លាប់ និងការប្តូរមុខវិជ្ជាជីវៈរបស់គ្រូបង្រៀនមានសារៈសំខាន់ និងមានចំនួនកើនឡើងជានិច្ច ។ ប៉ុន្តែចំណោទដូចគ្នានេះមានចំនួនតិចតួចបំផុតក្នុងមុខវិជ្ជាជីវៈផ្សេងៗទៀត ។ ជាមួយនេះ ថវិកាដែលគ្រោងសំរាប់បណ្តុះបណ្តាលគ្រូបង្រៀនរបស់ប្រទេស Malawi ត្រូវបានបង្វែទៅរ៉ាប់រងចំណាយសំរាប់បុណ្យសពគ្រូបង្រៀនទៅវិញ ។ នៅប្រទេស Botswana ដោយសារគ្រូបង្រៀនបានទទួលការព្យាបាលទប់ទល់នឹងជំងឺអេដស៍ អត្រាអ្នកស្លាប់មានចំនួនថេរ ។ ប៉ុន្តែ វាមិនមែនជាករណីទូទៅទេ ។

ផលវិបាកនៃជំងឺអេដស៍មានច្រើន ដូចជាក្មេងកំព្រា អវត្តមានជាញឹកញាប់របស់គ្រូបង្រៀន ការជួយឧបត្ថម្ភជាប្រាក់កាសរបស់គ្រួសារ និងសហគមន៍ចំពោះសាលារៀនថយចុះ គុណភាពអប់រំធ្លាក់ចុះ និងកត្តាដទៃទៀតដែលមានផលប៉ះពាល់ដល់ការអប់រំសំរាប់ទាំងអស់គ្នា ។

ចំពោះសភាពការណ៍ខាងលើ តើអនុសាសន៍ខាងក្រោមនេះ អាចជាការពិចារណាដែរឬទេ ?

* រដ្ឋាភិបាល និងអង្គការអន្តរជាតិ ត្រូវបង្កើនគុណភាពនៃការអប់រំសំរាប់ទាំងអស់គ្នា ដោយផ្អែកលើកត្តាទាំងឡាយមានជាអាទិ ការពិភាក្សាជុំវិញលក្ខណៈសម្បត្តិរបស់គ្រូបង្រៀនបច្ចុប្បន្ន ក៏រិតបណ្តុះបណ្តាលគរុកោសល្យ

និងនិយាមនៃវិញ្ញាបនកម្ម[១] ដើម្បីអោយកត្តាទាំងនេះ ត្រូវបានយកចិត្តទុកដាក់ដោយពិតប្រាកដក្នុងសកម្មភាពពាក់ព័ន្ធនឹងការអប់រំសំរាប់ទាំងអស់គ្នា ។

* អង្គការអន្តរជាតិការងារ OIT និង UNESCO ត្រូវជួយពង្រឹងឆន្ទៈនយោបាយ ការគៀងគរ និងការចូលរួមរបស់រោងចក្រ សហគ្រាស និងសមាគមគ្រូបង្រៀន ដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ ។

* ដើម្បីធ្វើសីលធមិរបស់គ្រូបង្រៀនអោយប្រសើរឡើង OIT និង UNESCO រួមនឹងដៃគូរប្រយុទ្ធប្រឆាំងជំងឺអេដស៍ត្រូវយល់ព្រមផ្តល់អាទិភាពខ្ពស់ដល់ការផ្សព្វផ្សាយពត៌មានដែលមានលក្ខណៈលើកទឹកចិត្តចំពោះករណីបុគ្គលិកសិក្សាដែលមានផ្ទុកមេរោគ HIV ហើយនៅតែបន្តរស់នៅបាន និងបង្រៀនបាន ។

ដូច្នោះ អនាគតនៃការអប់រំសំរាប់ទាំងអស់គ្នា អាស្រ័យនឹងគោលនយោបាយយុទ្ធសាស្ត្រ និងសកម្មភាពរបស់យើង ។

**គណៈកម្មាធិការនាយក**

កូនខ្មែរចេះភាសាបរទេស
គួរកុំប្រហែសធ្វេសអោយសោះ
គួរស្រូបវិជ្ជាសាស្ត្រនោះៗ
ហើយប្រែចំពោះជាខ្មែរទៅ ។

ដើម្បី អោយខ្មែរមានក្បួនច្បាប់
សំរាប់សិក្សាចេះជ្រាលជ្រៅ
ធ្វើអោយជាតិយើងមានសៀវភៅ
សំបូរគ្រប់ផ្លូវតាមត្រូវការ ។

សៀវភៅក្បួនច្បាប់ជាតិដទៃ
មានច្រើនក្រាស់ក្រៃគ្រប់គំរា
ជាតិគេមិនខ្វះក្បួនសិក្សា
សិល្បវិជ្ជាសម័យថ្មី ។

បើភាសាខ្មែរខ្មែរងាយអាន
មើលបានឆាប់ស្គាល់យល់សេចក្តី
ហេតុនេះគួរយើងខំឃ្មាតខ្មី
សាងក្បួនថ្មីៗជាខ្មែរអើយ ។

ឌិម ណាត្រី

(១) ការធានាជាលាយលក្ខអក្សរ-ការបញ្ជាក់ដោយលិខិត

# ការចាត់តាំងការងារ របស់អ្នកគ្រប់គ្រងការិយាល័យ ស្ថាប័ន

អ្នកគ្រប់គ្រងមិនត្រឹមតែស្មោះត្រង់ប៉ុណ្ណោះទេ គឺត្រូវតែមានចំណេះដឹង ថាមពលក្នុងការងារ ត្រូវចេះរបៀបរបបធ្វើការងារ និងចេះផ្លាស់ប្តូរអាកប្បកិរិយា ដើម្បីពង្រឹងនូវកិត្តិយសរបស់ខ្លួនជានិច្ចកាល ។

ហេតុនេះ ការចាត់តាំងបានល្អ និងអាកប្បកិរិយាត្រឹមត្រូវ គឺជាសំណូមពរយ៉ាងសំខាន់ ហើយជាបញ្ហាដែលត្រូវដោះស្រាយជាបន្ទាន់ និងយូរអង្វែងក្នុងដំណាក់កាលបច្ចុប្បន្ន ។

## I. ការប្រើប្រាស់ និងការបែងចែកពេលវេលា

- <u>អត្ថន័យ</u> : អ្នកគ្រប់គ្រងចាំបាច់ចាត់តាំង និងបែងចែកពេលវេលាបំពេញបេសកកម្មរបស់ខ្លួនបានល្អ ។
- <u>ការវិភាគថ្លឹងថ្លែងការចំណាយពេលវេលា</u> : អ្នកគ្រប់គ្រងត្រូវប្រមូលផ្តុំពេលវេលាសំរាប់ធ្វើការងារផ្សេងៗ ។ ដើម្បីសំរេចពេលវេលាបានល្អ គឺត្រូវប្រើប្រាស់ពេលវេលាគ្រប់គ្រាន់ ។

ឧទាហរណ៍ : ក្នុង១ខែ ត្រូវទុកពេលប៉ុន្មានសំរាប់ទាក់ទងការងារខាងក្រៅ ទទួលភ្ញៀវ ចុះបេសកកម្ម អានពតិមាន អានឯកសារ និងចុះហត្ថលេខា ។ ប្រការចាំបាច់ គឺត្រូវដឹងមុនថា តើត្រូវការពេលវេលាប៉ុន្មានសំរាប់ដោះស្រាយការងារនោះ ?

## II. ផែនការការងារ

- <u>អត្ថន័យ</u> : ផែនការត្រូវមានភាពស្ថិតស្ថេរជាប់ជានិច្ចលើរាល់សកម្មភាពរបស់ខ្លួន ពិសេសគឺចំពោះអ្នកគ្រប់គ្រង ។

អ្នកគ្រប់គ្រងមានមុខងារផ្សេងៗ មានទំនាក់ទំនងផ្ទៃក្នុងប្រទាក់ក្រឡាគ្នាសំបូរបែបតំរូវអោយធ្វើពលីកម្មរបស់ខ្លួន ដើម្បីគ្រប់គ្រងដឹកនាំសមូហភាព ។

- <u>សំណូមពរ</u> : ផែនការការងាររបស់អ្នកគ្រប់គ្រងមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺធ្វើអោយចំបញ្ហាគន្លឹះ ដោយយកចិត្តទុកដាក់លើការងារចំពោះមុខ និងការងារយូរអង្វែង ។
- <u>បណ្តាផ្អែកសំរាប់លើកផែនការរបស់អ្នកគ្រប់គ្រងត្រូវផ្អែកលើ</u> ÷
  - ច្បាប់ បណ្តាលិខិតបទដ្ឋានគោលការណ៍នានា
  - ផែនការរួម និងសភាពការណ៍ជាក់ស្តែង ឬអង្គភាពដែលខ្លួនធ្វើការងារ
  - មុខងារភារកិច្ចដែលបានប្រគល់អោយ និងសមត្ថភាព លទ្ធភាពរបស់ខ្លួន
  - រាល់ទំនាក់ទំនងនិងការចូលរួមប្រាស្រ័យទាក់ទងការងារជាមួយស្ថាប័ននានា ឬអង្គការផ្សេងៗ ។

- <u>របៀបធ្វើផែនការការងារ</u>
  - ផែនការប្រចាំថ្ងៃ : អនុវត្តក្នុងអំឡុងពេលដែលមានកំណត់ក្នុងកាលវិភាគការងារសំរាប់ធ្វើកិច្ចការនីមួយៗ ប៉ុន្តែមានការងារខ្លះ លើកឡើងដោយពុំបានប៉ាន់ស្មានមុន គឺលើកឡើងដោយចៃដន្យ ។
  - ផែនការប្រចាំសប្តាហ៍ : ជាបែបបទដែលមានសារៈសំខាន់ណាស់ ទាមទារពេលវេលាគិតគូរដើម្បីងាយអនុវត្ត ។
  - ផែនការប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ : ការងារប្រចាំឆ្នាំ បែងចែកជាឆមាស ត្រីមាសដែលត្រូវលើកជាក់ស្តែងប្រចាំខែ ត្រូវកត់ត្រាទុកក្នុងសៀវភៅផែនការការងាររបស់ខ្លួន ។

នៅរាល់ដំណាច់ខែ ត្រីមាស ឆមាស ឆ្នាំ ត្រូវតែពិនិត្យឡើងវិញ ការងារដែលធ្វើហើយ និងធ្វើមិនទាន់ហើយ ។

ឧទាហរណ៍ : របាយការណ៍បូកសរុបសំរាប់ឆ្នាំ ១៩៩៩ ។

មានតែផែនការកម្មពេលវេលាសំរាប់ធ្វើការងារទេ ទើបធ្វើអោយយើងមានរបៀបរៀបរយជៀសវាងការកត់ត្រា និងការជាន់គ្នាដែលប្រតិឃាតទៅលើគុណភាពការងារ ។

## III. ការចាត់ចែង និងដឹកនាំអង្គប្រជុំ

១- <u>អត្ថន័យ</u> : ការប្រជុំ គឺជាការប្រមូលផ្តុំមនុស្សមួយក្រុម ដែលបានចាត់តាំង ហើយជួបជុំគ្នាដើម្បីពិភាក្សាតាមរបៀបវារៈដែលបានគ្រោងទុក ។

២- <u>គោលបំណងរបស់ការប្រជុំ គឺដើម្បី</u> :

- ប្រមូលគំនិតយោបល់
- ពិភាក្សាបញ្ហា និងរកដំណោះស្រាយ
- ផ្តល់ពត៌មាន
- បញ្ចុះបញ្ចូល
- លើកផែនការ
- វាយតំលៃការងារ

ឧទាហរណ៍ : លើកកម្មវិធីសាងសង់អ្វីមួយ...

(នៅមានត)

ដកស្រង់ដោយ : លោក ឆេង ឡឿន




# អំពីកំណត់ហេតុ

ក្នុងគ្រប់រាល់ការប្រជុំ ទោះក្នុងអង្គការរដ្ឋក្ដី ក្នុងអង្គការក្រៅរដ្ឋាភិបាលក្ដី សហគ្រាសក្ដី គេតំរូវអោយមានកត់ត្រាជាលាយលក្ខអក្សរអោយបានសមស្របនៃស្មារតីអង្គប្រជុំនីមួយៗតាមវិធីផ្សេងៗក្នុងវិធីSFOR (S =sujet ប្រធានបទ,F = faits ព្រឹត្តិការណ៍, O = opinions មតិយោបល់, R = recommandation អនុសាសន៍)ដូចជា÷

១- កំណត់ហេតុ (P.V = Procès-verbal) = ប្រធានបទ + ព្រឹត្តិការណ៍

២- គណនាការណ៍ (C.R = Compte-rendu) = ប្រធានបទ + ព្រឹត្តិការណ៍ + មតិយោបល់

៣- របាយការណ៍ (Rapport) = ប្រធានបទ + ព្រឹត្តិការណ៍ + មតិយោបល់ + អនុសាសន៍

៤- អនុសាសន៍ (Recommandation) = កំណត់អំពីសេវា រឺបទបញ្ញត្តិសេចក្ដីសំរេច ។

## ១. អ្វីជាកំណត់ហេតុ ?

១/. <u>និយមន័យ</u> : គេអាចកត់សំគាល់ឃើញនិយមន័យ ពីរ យ៉ាង ÷

ក- សំនុំឯកសារកត់ត្រាដោយមន្ត្រីភ្នាក់ងារដែលបានតាក់តែងដោយស្មោះត្រង់នូវព្រឹត្តិការណ៍ បទល្មើសមួយ ។

ខ- ការកត់ត្រាសង្ខេបនូវអ្វីដែលគេបាននិយាយ បានធ្វើ បានសំរេចក្នុងកាលៈទេសៈមួយ ទោះជាឧឡារិកក្ដី មិនឧឡារិកក្ដី ។

២/. <u>អ្នកផ្ដល់គំនិតជំនាញ</u> : សមាជិកអង្គប្រជុំបញ្ជាក់អោយបានច្បាស់នូវ ÷

ក- ការដកស្រង់ដោយមិនលំអៀងនូវអ្វីដែលគេបាននិយាយ រឺធ្វើនៅចំពោះអ្នកកត់ត្រា ។

ខ- ការបំពេញជាសារវន្តនៃខ្លឹមសារពិភាក្សាក្នុងអង្គប្រជុំក្រោមទំរង់ ÷

- រឺជាកាលប្បវត្តិដោយគោរពដាច់ខាតនូវរបៀបរៀបរយបទអន្តរាគមន៍
- រឺជាការវិភាគដោយគោរពដាច់ខាតនូវគំនិតសមាជិកអង្គប្រជុំ ។

គ- ការចំលងត្រឹមត្រូវតាមព្យញ្ជនៈ រឺតាមន័យរបស់ពាក្យនៃចំលើយកសិណ (transcription littérale) និងកាលៈទេសៈរបស់វា គឺទីកន្លែង កាលបរិច្ឆេទនៃការចំលងអត្រានុកូលដ្ឋានរបស់កសិណ ។

ឃ- ការពិនិត្យកត់ត្រា (Constat) តាមសារលិខិតដែលធ្វើនៅមន្ទីរសារការី (Notariat) ដែលបានបញ្ញត្តិតាមច្បាប់ បញ្ជីសារពើភ័ណ្ឌ ការជំរះបញ្ជី... ។

ង- តាមន័យយុត្តិសាស្ត្រ : សារលិខិតលាយលក្ខអក្សរដែលនៅក្នុងនោះនាពេលបំពេញការងារ អ្នកកត់ត្រា (មន្ត្រីសាធារណៈ អ្នករាជការ ភ្នាក់ងារអាជ្ញាធរ) រាយការណ៍អំពីអ្វីដែលគេបានឃើញ បានលឺ រឺធ្វើ ។

អ្នកផ្តល់យោបល់ ត្រូវយល់ព្រមលើចរិតលក្ខណៈទាំងអស់របស់កំណត់ហេតុ ។កំណត់ហេតុនេះ ត្រូវតែជាលាយលក្ខអក្សរជានិច្ច ហើយត្រូវអានអោយបានច្បាស់ៗជាសាធារណៈ ។

៣/. <u>នៅក្នុងក្របខ័ណ្ឌសកម្មភាពវិជ្ជាជីវៈមានរូបមន្តត្រូវចងចាំ</u> ÷

១- ការចំលងយ៉ាងស្មោះត្រង់ ។

២- ការលើកឡើងជាលាយលក្ខអក្សរ ។

## ២. ប្រភេទផ្សេងៗនៃកំណត់ហេតុ និងអ្នករៀបរៀងកំណត់ហេតុ

### ១. <u>ប្រភេទនៃកំណត់ហេតុ</u>

ក- កំណត់ហេតុស្តីពីការសំគាល់ឃើញ (P.V. de constatation) : ការបន្លំលួច ការបំពាន ការបំបាត់ ការរត់គេច និងឧប្បត្តិហេតុ ។

ខ- កំណត់ហេតុស្តីពីការថ្លែងការណ៍ (P.V. de déclaration) : ការខូចខាត គ្រោះថ្នាក់ឧបទ្ទវហេតុ (កំណត់សំគាល់ និងការថ្លែងការណ៍ ច្រើនបញ្ចូលក្នុងកំណត់ហេតុមួយ) ។

គ- កំណត់ហេតុស្តីពីការទទួល (P.V. de réception)

ឃ- កំណត់ហេតុស្តីពីការសាកល្បង (P.V. d'essai)

ង- កំណត់ហេតុស្តីពីការចាប់ប្រតិបត្តិ (P.V. de mise en service)

ច- កំណត់ហេតុស្តីពីកង្វះខាត (P.V. de carence)

ឆ- កំណត់ហេតុស្តីពីមហាសន្និបាត (P.V. d'assemblée générale de séance)

ជ- កំណត់ហេតុស្តីពីកិច្ចព្រមព្រៀង (P.V. d'accord)

ឈ- កំណត់ហេតុស្តីពីការសំរេចរបស់អាជ្ញាកណ្តាល (P.V. d'arbitrage)

ញ- កំណត់ហេតុស្តីពីការផ្សះផ្សាការសំរុះសំរួល (P.V. de conciliation)

ដ- កំណត់ហេតុស្តីពីកោសល្យវិច័យ (P.V. d'expertise)

### ២. <u>តើនរណាអាចតាក់តែងកំណត់ហេតុ?</u>

ក- *<u>កំណត់ហេតុពាក់ព័ន្ធនឹងច្បាប់ (វិបទបញ្ញា)</u>* : ត្រូវបានប្រគល់អោយតែបុគ្គលបានធ្វើសច្ចាប្រណិធានចំពោះច្បាប់ដូចជា ÷

- សំរាប់តាក់តែង និងទទួលសារលិខិតត្រឹមត្រូវតាមច្បាប់មាន÷ មន្ត្រីរបស់ក្រសួងដែលបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ : សារការី (notaire) ស្នារក្តី (avoué) អាជ្ញាសាលា (huissier) ក្រឡាបញ្ជី (greffier)
- សំរាប់កត់ត្រាបទល្មើស រីការលួចបន្លំ ការបំពាន ការរត់គយមាន ÷
  - ភ្នាក់ងារអាជ្ញាធរ : អាវុធហត្ថ មន្ត្រីប៉ូលីសមួយចំនួន...
  - មន្ត្រីប៉ូលីសតុលាការ : រាជអាជ្ញា សុភាចារបុរស (juge d'instruction) ចៅក្រមសាលាលហុ (juge de paix) ចៅសង្កាត់-សង្កាត់រង ក្សេត្ររក្ស (garde champêtre) វនារក្ស (garde forestier)
  - ភ្នាក់ងារសេវាសាធារណៈ ប្រៃសនីយ៍ គយ...
  - ភ្នាក់ងារទទួលបន្ទុកយាមល្បាត : អ្នកល្បាតការបរបាញ់ អ្នកល្បាតការនេសាទ ។

ខ- *<u>សិទ្ធិសំរាប់លេខាធិការនៃអង្គប្រជុំ</u>*

- មហាសន្និបាត : សហជីព សមាគម សមាគមមិត្ត អ្នកហ៊ុននៃក្រុមហ៊ុន
- ការប្រជុំសាមយិក (Réunion périodique) តាមការកំណត់ ។
  - ការិយាល័យ
  - គណៈកម្មាធិការ
  - សន្និសីទការងារ...

**ដកស្រង់ និងប្រែសំរួលដោយ : កែវ យ៉ារ**

# អត្ថិភាពនិយម
(Existentialisme)

ទស្សនវិជ្ជាមានការវិវត្តជាលំដាប់ : មនោនិយម រូបធាតុនិយម ពិសោធនិយម វិចារណនិយម... ហើយនៅក្រោយសង្គ្រាមលោកលើកទី២ក៏មានការកកើតប្រព័ន្ធទស្សនវិជ្ជាថ្មីមួយទៀត ហើយទស្សនៈថ្មីនេះ ត្រូវបានលេចចេញពីស្រទាប់មហាជន បើនិយាយម្យ៉ាងទៀត នោះគឺជាទស្សនៈមហាជនតែម្តង ។

កាលមុនសង្គ្រាមលោក ពិសេសតាំងពីមានការកកើតអ្នកប្រាជ្ញខាងទស្សនវិជ្ជាមក ទស្សនវិទូក៏ដូចជាមេដឹកនាំសាសនាទាំងឡាយបានផ្តោតគំនិតទៅលើឧត្តមគតិខ្ពង់ខ្ពស់ ទោះបីជាទស្សនៈពុំប្រសើរក្តីដូចជាឋាននរក ឋានប្រេត បើពុំនោះទេ គឺឋានសួគ៌ ឋាននិព្វាន រឺព្រះជួយផុតទុក្ខទោសពីលោកិយ ។ គេបានអោយតំលៃលើទស្សនៈនីមួយៗខ្ពង់ខ្ពស់ពេក ។ គេមិនបាននឹកថា តើមនុស្សដែលពុំមែនជាអាទិទេព រឺព្រះសម្មាសម្ពុទ្ធនេះ អាចធ្វើអំពើនោះបានរឺទេ តើសាសនាអាចធ្វើអោយមនុស្សរស់នៅបានគ្រប់ជ្រុងជ្រោយរឺទេ នាពេលសព្វថ្ងៃនេះ ។ គេមិនបានយកចិត្តទុកដាក់នឹងជីវភាពជាក់ស្តែងរបស់មនុស្សដោយពុំបានសួរ ÷

- តើមនុស្សរស់នៅរបៀបណា ?
- ធ្វើយ៉ាងណាដើម្បីរស់នៅបាន ?
- ត្រូវពឹងលើគេរឺទេ ?
- តើសង្គមមនុស្សអាចធ្វើអោយដំណើរជីវិតរស់នៅរបស់មនុស្សបានប្រព្រឹត្តទៅសមរម្យរឺទេ ?

សំនួរទាំងឡាយខាងលើនេះបានចោទទៅលើតំលៃជីវភាពជាក់ស្តែងរបស់មនុស្ស ហើយខំរកផ្លូវដោះស្រាយអោយមនុស្សអាចសំរេចសុខៈបានតាមសមត្ថភាព លទ្ធភាព និងពេលវេលាដែលខ្លួនរស់នៅ ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានចែកទស្សនទានរបស់ព្រះអង្គជាពីរ : ធម៌លោកិយ និងលោកុត្តរធម៌ ។ ក្នុងករណីទី១ ព្រះអង្គតែងនាំអោយពុទ្ធបរិស័ទគិតគូរពីប្រយោជន៍បច្ចុប្បន្នបួនយ៉ាង : ឧដ្ឋានសម្បទា អារក្ខសម្បទា កល្យាណមិត្តា និងសមជីវិតា រក្សាសីលទានដោយមិនបាច់គិតថា មនុស្សកើតមកពីណា នរណាជាអ្នកបង្កើត ។

ប្រព័ន្ធទស្សនវិជ្ជានេះ គេអោយឈ្មោះថា អត្ថិភាពនិយមរឺភវនិយម ហើយបើនិយាយបែបសាមញ្ញបំផុត "ការរស់និយម" ។

គំនិតខ្មែរយើងខ្លះក៏បានឆ្លុះបញ្ចាំងអំពីទស្សនៈនេះដែរ ដូចជា :

"អោយតែកូនហៅឪៗទៅ"

"បាយកកក៏បាយ មេម៉ាយក៏ស្រី កន្ទុយបារីក៏ថ្នាំ"

"ឱស្វាយចន្ទី នារីអូនអើយបែកមែកសាខា ធ្វើបុណ្យកាលណា ប្រាថ្នាចង់ជួបតែស្រី...។"

"តួឯករង"

តាមទស្សនៈនេះ គេមិនបានគិតគួរអំពីតំលៃម្ដាយឪពុកដែលពេលមុនគេថាជាអ្នកមានគុណប៉ុនភ្នំ ហើយលើសពីនេះទៅទៀត ពួកជ្រុលនិយមក្នុងរបប ប៉ុល ពត បានលើកឡើងយ៉ាងនេះ "ឪពុកម្ដាយគ្មានគុណទេ គេបង្កើតកូនក៏ព្រោះតែចង់សប្បាយតែប៉ុនណោះ" ។

ក្នុងករណីនេះ ការកាន់ព្រះពុទ្ធសាសនានៅកម្ពុជាក៏ត្រូវបានស្រុតចុះ ។ មានតែមនុស្សចាស់ ពិសេសស្ត្រីៗធ្វើការប្រតិបត្តិធម៌អាចិ ហើយយើងក៏តែងលឺពាក្យថា "ភ្លេចបុណ្យ ភ្លេចទានអស់ អាទិតែរកស៊ី" ហើយក្រោយពីសង្គ្រាមរ៉ាំរ៉ៃ និងរបបប្រល័យពូជសាសន៍ប៉ុល ពត អាយុជីវិតមនុស្សត្រូវបានគេមើលងាយមើលថោកជាទីបំផុត អំពើអកុសលរីករាលដាលគួរអោយព្រួយបារម្ភ ។

ដូចបានលើកឡើងខាងលើ ចលនាគំនិតនេះមានប្រភពពីសង្គ្រាម ។ លោកហ្សង់ ប៉ូលសាត (Jean Paul Sartre) ទស្សនវិទូបារាំងបានយកហេតុការណ៍ទាំងនោះមកធ្វើជាបុព្វហេតុបង្កើតទ្រឹស្ដីនេះ : អត្ថិភាពនិយមមានន័យថា ការរស់នៅជាក់ស្ដែងប្រចាំថ្ងៃដែលខ្លួនត្រូវការប្រសើរជាជាងខ្លឹមសារជីវិត ក៏ប៉ុន្តែទស្សនៈនេះក៏ពុំបានបដិសេធចោលខ្លឹមសារនេះដែរ ។

នេះជាទស្សនៈមួយប្រឆាំងនឹងគំនិតណាដែលអោយតំលៃលើអ្វីដែលប្រសើរ អ្វីដែលខ្ពង់ខ្ពស់ អ្វីដែលល្អហួសអ្វីដែលជាគ្រឿងតុបតែងឥតប្រយោជន៍ អ្វីដែលជាគ្រឿងប្រើប្រាស់ហួសពីសេចក្ដីត្រូវការរបស់មនុស្ស ។ ដោយហេតុតែមានគំនិតប្រឆាំងនឹងខ្លឹម ប្រឆាំងនឹងអ្វីដែលល្អប្រសើរ ទើបហ្សង់ប៉ូលសាតពុំព្រមទៅទទួលរង្វាន់ណូបែលអក្សរសិល្ប៍នៅឆ្នាំ ១៩៦៤ ។ មតិខ្លះយល់ថា បានជាហ្សង់ប៉ូលសាតពុំព្រមទៅទទួលរង្វាន់ណូបែល មកពីលោកពុំចូលចិត្តណូបែល (១៨៣៣-១៨៩៦) ដែលជាសេដ្ឋីមួយរូបសញ្ជាតិស៊ុយអែតមានទ្រព្យសម្បត្តិស្ដុកស្ដម្ភដោយហេតុតែណូបែលចេះធ្វើគ្រឿងផ្ទុះលក់បានចំណេញច្រើន ហើយគ្រឿងផ្ទុះនោះត្រូវបានគេយកទៅប្រល័យលោកផងនោះ ។

ជារួម យើងក៏អាចសន្និដ្ឋានបានថា សង្គ្រាមបានធ្វើអោយជួបការលំបាកជាច្រើនទាំងខាងផ្លូវសំភារៈ ទាំងខាងផ្លូវចិត្តដែលធ្វើអោយមនុស្សលោកលែងខ្វល់អំពីខ្លឹមសារទៀត ហើយលោកស្ដង់ដាល (Standhal) អ្នកនិពន្ធជនជាតិបារាំងក្នុងសតវត្សទី ២០ បានពិនិត្យឃើញមានមនុស្ស ៣ ប្រភេទនៅក្នុងសង្គ្រាម : អ្នករស់ដើម្បីសង្គ្រាម អ្នករស់ដោយសារសង្គ្រាម និងអ្នករស់ក្នុងសង្គ្រាម ហើយមានតែប្រភេទមនុស្សទី ២ ទេជាអ្នកធ្វើមានដោយសារសង្គ្រាម ។

ក្នុងករណីនេះផងដែរ ព្រះសម្មាសម្ពុទ្ធក៏ព្រះអង្គបានព្យាករណ៍អនាគតសាសនារបស់ព្រះអង្គថានឹងត្រូវសាបសូន្យទៅវិញរវាង ៥ ០០០ឆ្នាំ នៅពេលវិទ្យាសាស្ត្របានបំរើផលប្រយោជន៍មនុស្សជាតិបានបរិបូរ ហើយនៅពេលនោះមនុស្សនឹងសំរេចយកពរទី ១ : សម្បត្តិមនុស្សក្នុងចំណោមពរទាំង ៣ប្រការ :សម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន ។

**កែវ យ៉ារ**

---

ឯកសារពិគ្រោះ : អត្ថាធិប្បាយទស្សនវិជ្ជា សរ សារុន

# ការអប់រំសីលធម៌ និងការអប់រំសាសនា

ការសិក្សាសីលធម៌រួមមានការសិក្សាពីតំលៃ និងគោលការណ៍ណែនាំពីរបៀបរស់នៅជាមួយការបង្ហាញហេតុ និងផល ។ លោក អេមីលឌឺខេម (Emile Durkheim) សង្គមវិទូជនជាតិបារាំងបានពោលថា សង្គមនីមួយៗសុទ្ធតែមានសីលធម៌រៀងៗខ្លួន ។ ជាការពិត សង្គមដែលគ្មានសីលធម៌ពិតជាក្លាយទៅជាសង្គមអនាធិបតេយ្យគ្មានការគោរពសិទ្ធិមនុស្ស មើលងាយតំលៃមនុស្សដូចគ្នា សង្គមគ្មានអារ្យធម៌ គេអាចនិយាយបានថា ការអប់រំសីលធម៌ ជាគន្លឹះនៃការអភិវឌ្ឍធនធានមនុស្ស ។ ការអប់រំសីលធម៌ គឺជាអាទិភាពទី១នៃការអប់រំដំបូងទាំងក្នុងគ្រួសារ សាលា និងសង្គម ។ ដំណើរជោគជ័យដ៏សំបើមមួយនៃវិទ្យាសាស្ត្រ និងបច្ចេកទេសនៅសតវត្សទី ១៩ និងទី ២០ គឺដោយសារគេគិតគូរពីបញ្ហាសីលធម៌ជាគោលនៅក្នុងដែនកំណត់វិទ្យាសាស្ត្រ ។

មនុស្សជាច្រើនបានចាត់ទុកថាការអប់រំសីលធម៌ គឺស្ថិតនៅក្នុងការប្រៀនប្រដៅសាសនា ។ ពិតមែនថាសាសនាជាការប្រៀនប្រដៅអប់រំ ទូន្មាន ដាស់តឿន ក្រើនរំលឹកពីគ្រូអាចារ្យ ឬបុគ្គលណាម្នាក់ ដើម្បីអោយមនុស្សរស់ក្នុងសេចក្ដីសុខក៏ដោយ ក៏គេអាចសួរថា តើការអប់រំសីលធម៌ត្រូវផ្អែកលើសាសនា ឬក៏ឯករាជ្យពីសាសនា ?

ក្នុងចម្លើយនេះ មានទ្រឹស្ដីជាច្រើនបានលើកឡើងថា :

១- ទ្រឹស្ដីអភិរក្សនិយមបានថែងថា ការអប់រំសីលធម៌មានទំនាក់ទំនងយ៉ាងស្អិតជាមួយសាសនា ឬជាមួយបញ្ញារបស់ព្រះ ឬក៏ទាក់ទងជាមួយបទដ្ឋានវប្បធម៌ ។ ទ្រឹស្ដីអភិរក្សនិយមនេះបានបន្ថែមទៀតថា ការអប់រំសីលធម៌ទាក់ទងទៅអ្វីដែលព្រះបានបញ្ញា ឬបានចារទុក ។ វាគ្មានស្ដង់ដារសកលណាមួយច្បាស់លាស់ដែលបញ្ជាក់ថា ភាពចាំបាច់ធ្វើសកម្មភាពមួយក្លាយទៅជាការត្រឹមត្រូវជាងការបញ្ញារបស់ព្រះអាទិទេពនោះទេ ។ ស្របនឹងគំនិតនេះលោក ហ្សង់ហ្សាក់រ៉ូស្សូ (J.J Rouseau 1712-1778)បានចាត់ទុកថា សីលធម៌មានកំណើតពីអាទិទេព ។ ចំណែកឯលោក (Likewise Quran) បានពោលថា "ខ្លឹមសារនៃគម្ពីរ Bible របស់សាសនាគ្រឹស្តបានបង្កើតជាមូលដ្ឋានគ្រឹះនៃការអប់រំសីលធម៌ក្នុងសម័យបុរាណផងដែរ" ។

២- ទ្រឹស្ដីសាសនវិទូ និងសីលធម៌វិទូភាគច្រើនបំផុតរួមទាំងអ្នកធម្មជាតិនិយម មិនឯកភាពជាមួយទ្រឹស្ដីអភិរក្សនិយមនោះទេ ។ ពួកគេបានជំទាស់ថា ការបង្រៀនសាសនាអាចជាការប្រកាសចំហនូវគោលការណ៍សីលធម៌ជាសកល ។ រីឯការអប់រំសីលធម៌កើតមានឡើងឯករាជ្យពីសាសនា ឬបញ្ញារបស់ព្រះ ហើយការបង្រៀនសីលធម៌ និងក្រមសីលធម៌ត្រូវបានគេបញ្ចូលគ្នានៅក្នុងគម្ពីរសាសនាពិភពលោកសំខាន់ៗ ។ ការសិក្សាពីគម្ពីរសាសនា គឺវាមានសារៈសំខាន់ណាស់ ព្រោះវាបានបង្រៀនពីអ្វីដែលត្រូវរំលេចអោយចេញពីអ្វីដែលខុស ។

នៅក្នុងពិភពលោកយើងនេះ មានសាសនាជាច្រើន ហើយមានទស្សនៈអប់រំសីលធម៌ទៅតាមមធ្យោបាយផ្សេងៗគ្នា ។ ក្នុងនេះយើងលើកយកទស្សនៈអប់រំសីលធម៌របស់សាសនាចំនួន ៤ ព្រោះសាសនាទាំងនោះបានសាប

ព្រោះឥទ្ធិពលរបស់ខ្លួននៅក្នុងសង្គមខ្មែររួមមាន :

**ក. ពុទ្ធសាសនា** : ក្នុងរយៈពេល ៤៥ឆ្នាំ ចាប់ពីព្រះអង្គបានត្រាស់ដឹង ព្រះអង្គតែងនិមន្តទេសនាប្រៀនប្រដៅដល់មនុស្សលោកគ្រប់ទិសទីពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតទាំងយប់ទាំងថ្ងៃរហូតដល់ចូលព្រះនិព្វានក្នុងព្រះជន្ម៨០ព្រះវស្សា ។ ព្រះពុទ្ធបានបន្សល់នូវពាក្យប្រៀនប្រដៅចំនួន ៨៤ ០០០ធម្មក្ខន្ធ ( ព្រះត្រៃបិដក) ចែកជា ៣ ផ្នែកគឺ វិន័យបិដក សុត្តន្តបិដក និងអភិធម្មបិដករួមមាន ១១០ក្បាល ។

ពាក្យអប់រំប្រៀនប្រដៅសីលធម៌របស់ព្រះពុទ្ធមានច្រើនក៏ពិតមែនតែបើបង្រួមមកមានតែ ៣ទេគឺ :

- ត្រូវបញ្ឈប់ធ្វើអំពើអាក្រក់គ្រប់បែបយ៉ាង
- ត្រូវបណ្តុះអំពើល្អអោយកើតមានច្រើនឡើង
- ត្រូវជំរះចិត្តរបស់ខ្លួនអោយស្អាតផូរផង់ជានិច្ច

❖ ***អំពើអាក្រក់ ១០យ៉ាង ( អកុសលកម្មបថ ១០) ដែលគួរជៀសវាង :***

**២. អំពើអាក្រក់ដោយកាយ ៣ យ៉ាង (កាយទុច្ចរិត៣)**

- អំពើបៀតបៀន ឬសំលាប់សត្វមានជីវិត
- អំពើកេងបន្លំលួច ឬប្លន់ទ្រព្យសម្បត្តិអ្នកដទៃ
- អំពើខុសឆ្គងក្នុងកាមទាំងឡាយ គន្លងប្រពៃណីប្តីប្រពន្ធកូនចៅអ្នកដទៃ ។

**៣. អំពើអាក្រក់ដោយវាចា ៤យ៉ាង (វចីទុច្ចរិត ៤)**

- ពាក្យសំដីកុហក ឬបញ្ឆោត
- ពាក្យសំដីញុះញង់អុជអាល
- ពាក្យសំដីទ្រគោះចាក់ដោត
- ពាក្យសំដីឥតប្រយោជន៏

**៤. អំពើអាក្រក់ដោយចិត្ត ៣យ៉ាង (មនោទុច្ចរិត៣)**

- គំនិតសំលឹងរំពៃចង់បានទ្រព្យសម្បត្តិពីអ្នកដទៃ
- គំនិតបៀតបៀនប្រទូស្តរ៉ាយអ្នកដទៃ
- គំនិតយល់ខុសចាកគន្លងធម៌ថា គ្មានបាប គ្មានបុណ្យនោះទេ ។

❖ ***អំពើល្អ ១០យ៉ាង ( កុសលកម្ម១០) ដែលត្រូវអនុវត្ត :***

**១- អំពើល្អដោយកាយ ៣ (កាយសុចរិត៣)**

- វៀរចាកអំពើបៀតបៀន ឬសំលាប់មនុស្ស
- វៀរចាកអំពើកេងបន្លំលួច ឬប្លន់ទ្រព្យសម្បត្តិអ្នកដទៃ
- វៀរចាកអំពើខុសឆ្គងក្នុងកាមទាំងឡាយ

**២- អំពើល្អផ្លូវវាចា ៤ យ៉ាង (វចីសុចរិត ៤)**

- វៀរចាកពាក្យសំដីកុហកបញ្ឆោត
- វៀរចាកពាក្យសំដីញុះញង់អុជអាល
- វៀរចាកពាក្យសំដីទ្រគោះចាក់ដោត
- វៀរចាកពាក្យសំដីឥតប្រយោជន៍

**៣- អំពើល្អផ្លូវចិត្ត ៣យ៉ាង (មនោសុចរិត ៣)**

- មិនសំលឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃ
- មិនគិតបៀតបៀនប្រទូស្តរ៉ាយអ្នកដទៃ
- គំនិតយល់ឃើញត្រូវតាមគន្លងធម៌ថា មានបាប មានបុណ្យ គុណទោស ជឿថាពុកម៉ែជាអ្នកមានគុណ ។

សរុបមក យើងម្នាក់ៗត្រូវជៀសវាងអកុសលកម្មបថ១០ប្រការខាងលើ ហើយត្រូវធ្វើអំពើជាកុសលកម្ម ១០យ៉ាងជាប្រចាំ។

**ខ. *អ៊ីស្លាមសាសនា*** : សាសនាអ៊ីស្លាម គឺកើតឡើងដោយបុគ្គលម្នាក់ឈ្មោះ មហាម៉ាត់ (Mohammed 571-632គ.ស)ជាកូនកំព្រាដែលឪពុកម្តាយបានស្លាប់នៅពេលគាត់នៅជាទារកនៅឡើយ។ មហាម៉ាត់បានចំណាយពេល ៥០ឆ្នាំ ដើម្បីសូត្រធម៌ និងភាវនាធម៌ដោយគាត់យល់ថាមានព្រះអាឡោះជាអ្នកនិយាយមករកគាត់ ។ គាត់បានប្រមូលពិភពអារ៉ាប់ទាំងអស់អោយជឿលើព្រះអាឡោះ ។ ក្រោយពេលមហាម៉ាត់ស្លាប់ទៅ លោក អាប៊ូបែក (Abu Bekr) បានប្រមូលសំដីរបស់មហាម៉ាត់ចងក្រងជាសៀវភៅមួយឈ្មោះថា គម្ពីរកូរាន (Koran) ដែលគេចែក ១១៤ suras ឬជំពូក ។ គម្ពីរ ៣ ក្នុងចំណោមគម្ពីរទាំងនោះត្រូវគេដាក់បញ្ចូលនៅក្នុងអត្ថបទអំណានសំរាប់អោយជនជាតិអារ៉ាប់សូត្រទន្ទេញចាំមាត់ ៥ដងក្នុង១ថ្ងៃ ។ ខ្លឹមសារគម្ពីរត្រូវគេចាត់ទុកជាព្រះគម្ពីរ និងជារឿងរ៉ាវដែលប្រជាជនអារ៉ាប់គោរពយ៉ាងម៉ឺងម៉ាត់ និងគេចាត់ទុកជាកំរងច្បាប់ដូចជាក្បួនចរិយាធម៌ ក្បួនគ្រប់គ្រង ក្បួនសីលធម៌... សំរាប់សង្គមអារ៉ាប់ ។ ព្រះមហាម៉ាត់ជាកំពូលទស្សនវិទូអារ៉ាប់បានលើកទស្សនៈអប់រំជាមូលដ្ឋានដល់ពួកអ៊ីស្លាមទាំងអស់អោយគោរពមានដូចជា :

- អោយជឿលើព្រះអាឡោះតែមួយ
- មានភាពស្មើគ្នាចំពោះមុខព្រះ
- កុំលួចទ្រព្យសម្បត្តិ ឬកេងប្រវ័ញ្ចបោកបញ្ឆោតអ្នកដទៃ
- ហាមឃាត់ទៅលើគ្រឿងស្រវឹង
- មានភាពស្មោះត្រង់
- អំពើបាបនៃការផិតប្តីប្រពន្ធ

- ត្រូវអោយសូត្រធម៌ ៥ដងក្នុងមួយថ្ងៃ ពេលថ្ងៃរះ ពេលថ្ងៃត្រង់ ពេលរសៀល ពេលថ្ងៃលិច និង ពេលយប់
- ការដាក់ទាន ឬការបរិច្ចាគដល់មនុស្សម្នាក់ៗត្រូវបានគេលើកទឹកចិត្តដើម្បីចែករំលែកសំភារៈ ថវិកា ដល់អ្នកក្រីក្រ និងដល់អ្នកគាំទ្រសាលារៀន និងវិហារម៉ូស្លីម ។

ក្រៅពីនេះ មហាម៉ាត់បានប្រៀនប្រដៅដល់អ៊ីស្លាមទាំងអស់អោយខំប្រព្រឹត្តអំពើល្អចំពោះគ្នាទៅវិញទៅមកក្នុងសង្គម មានចិត្តសន្ដោសចំពោះមនុស្សដូចគ្នា ត្រូវអនុញ្ញាតអោយស្ត្រីមានសិទ្ធិស្មើភាពចំពោះបុរស ហាមកុំអោយមានការលក់ដូរមនុស្សដូចសត្វធាតុ តែបុរសម្នាក់រៀបការជាមួយស្ត្រីធ្វើជាប្រពន្ធយ៉ាងហោចណាស់ចាប់ពីពីរនាក់ឡើងទៅ អោយតែមានលទ្ធភាពចិញ្ចឹមគេបាន។ ជនជាតិអ៊ីស្លាមទាំងអស់ត្រូវហ៊ានស៊ូស្លាប់រស់ដើម្បីការពារសាសនាអោយបានគង់វង្ស ។

គ- **<u>គ្រិស្តសាសនា</u>** : សាសនាគ្រិស្ត គឺជាសាសនាមួយក្នុងចំណោមសាសនាធំៗក្នុងពិភពលោកដែលមានកំណើតនៅប្រទេសអ៊ីស្រាអែល ។ ព្រះគម្ពីរប៊ីប គឺជាសំណេរកត់ត្រានៃការជួយសង្គ្រោះដែលបំពេញអោយព្រះយេស៊ូ ។

មូលដ្ឋានគ្រឹះនៃការអប់រំសីលធម៌របស់សាសនាគ្រិស្តរួមមាន ២ សំខាន់គឺ :

១- ត្រូវស្រលាញ់ព្រះជាម្ចាស់ទុកជាព្រះរបស់ខ្លួនអោយអស់ពីចិត្ត អស់ពីស្មារតីប្រកបដោយប្រាជ្ញា ព្រះជាម្ចាស់បានជួយសង្គ្រោះមនុស្សលោកអោយរួចផុតពីបាបតាមរយៈការសន្ដោសប្រណី ។

២- ត្រូវស្រលាញ់មនុស្សទូទៅដូចស្រលាញ់ខ្លួនឯង ពោលគឺត្រូវចេះអត់ធ្មត់ យល់អធ្យាស្រ័យចំពោះមនុស្សដូចគ្នា ។

ព្រះយេស៊ូគ្រិស្តបានមានព្រះបន្ទូលទូន្មានអំពីគុណជាច្រើនប្រការ អំពីការស្វែងរកសុភមង្គលពិតប្រាកដ ។ លោកបានពោលថា :

- **សុភមង្គលពិតប្រាកដកើតឡើងដោយ ÷**
  - អ្នកណាដាក់ចិត្តជាអ្នកក្រខ្សត់ អ្នកនោះមានសុភមង្គលហើយ
  - អ្នកកាន់ទុក្ខ អ្នកនោះមានសុភមង្គលហើយ
  - អ្នកមានចិត្តស្លូតបូត អ្នកនោះមានសុភមង្គលហើយ
  - អ្នកណាស្រេកឃ្លានសេចក្ដីសុចរិត អ្នកនោះមានសុភមង្គលហើយ
  - អ្នកណាមានចិត្តមេត្តា អ្នកនោះមានសុភមង្គលហើយ
  - អ្នកណាមានចិត្តបរិសុទ្ធ អ្នកនោះមានសុភមង្គលហើយ
  - អ្នកណាកសាងសន្តិភាព អ្នកនោះមានសុភមង្គលហើយ
- **ការសងសឹក**

- កុំសំលាប់មនុស្ស អ្នកណាសំលាប់គេ អ្នកនោះនឹងត្រូវផ្តន្ទាទោស អ្នកណាខឹងនឹងបងប្អូន អ្នកនោះនឹងត្រូវគេផ្តន្ទាទោស
- អ្នកណាជេរប្រទេចផ្តាសាបងប្អូន អ្នកនោះត្រូវក្រុមប្រឹក្សាជាន់ខ្ពស់កាត់ទោស ហើយអ្នកណាត្មះតិះដៀលគេ អ្នកនោះនឹងត្រូវគេផ្តន្ទាទោសធ្លាក់ក្នុងភ្លើងនរកអវចី
- កាលណាអ្នកធ្វើដំណើរទៅតុលាការជាមួយគូវិវាទរបស់អ្នក ចូរស្រុះស្រួលជាមួយអ្នកនោះជាប្រញាប់
- ដរាបណាអ្នកមិនបានបង់លុយអោយគេគ្រប់ចំនួន ដរាបនោះអ្នកមិនរួចខ្លួនឡើយ ។

- **ការផិតក្បត់**
  - កុំប្រព្រឹត្តអំពើក្បត់ អ្នកណាមើលស្ត្រីម្នាក់ ហើយមានចិត្តស្រើបស្រាលចង់រួមភេទជាមួយនាង អ្នកនោះដូចជាបានប្រព្រឹត្តអំពើអនាចារជាមួយនាង
  - បើសិនភ្នែកស្តាំរបស់អ្នកជំរុញអោយអ្នកប្រព្រឹត្តអំពើបាបចូរខ្វេះវាចេញហើយបោះចោលអោយឃ្លាតឆ្ងាយពីអ្នក បាត់ភ្នែកមួយនេះប្រសើរជាងបណ្តោយអោយរូបរាងកាយធ្លាក់ចុះនរក ។
- **គំនុំសងសឹក**

កុំតបនឹងមនុស្សកំណាចអោយសោះ បើគេទះកំភ្លៀងស្តាំរបស់អ្នក ចូរបែរអោយគេទះម្ខាងទៀត ។ បើមានគេប្តឹងចង់បានអាវរបស់អ្នក ចូរអោយគេយកអាវធំថែមទៀត ។ ចូរអោយគេទៅ ហើយកុំគេចមុខចេញពីអ្នកដែលសុំខ្ចីអ្វីពីអ្នក ។

**ឃ. ព្រាហ្មណ៍សាសនា** : ព្រាហ្មណ៍សាសនា ជាសាសនាធំមួយនៅប្រទេសឥណ្ឌា មានកំណើតប្រមាណជា១ ៥០០ ដល់ ៥៥០ ឆ្នាំមុនគ.ស ។ សាសនានេះបានជះឥទ្ធិពលយ៉ាងទូលំទូលាយក្នុងប្រទេសមួយចំនួននៅអាស៊ី ជាពិសេសប្រទេសកម្ពុជា ។ ឥទ្ធិពលសាសនានេះ បានធ្វើអោយប្រទេសកម្ពុជាមានការរីកចំរើនដល់កំពូលក្នុងសម័យអង្គរ ។ ប្រទេសកម្ពុជាដែលគេស្គាល់ដល់សព្វថ្ងៃក៏ដោយឥទ្ធិពលសាសនានេះដែរ ។

គោលការណ៍អប់រំសីលធម៌របស់សាសនាព្រាហ្មណ៍ គេផ្អែកលើអាទិទេពជាធំ ហើយខ្លឹមសារសំខាន់ៗគឺមានចែងក្នុងគម្ពីរវេទ ។ ពិធីបុណ្យផ្សេងៗគេធ្វើឡើងដើម្បីថ្វាយពរជ័យដល់អាទិទេព និងទេវៈផ្សេងៗ ។

អ្នកកាន់សាសនាព្រាហ្មណ៍មានជំនឿថា ព្រះព្រហ្មជាអាទិទេពបង្កើតលោក និងផ្តល់ជីវិតដល់មនុស្សសត្វ។ ព្រហ្ម័ន គឺស្ថិតនៅក្នុងព្រលឹងនៃព្រហ្ម ហើយនៅក្នុងនោះមានព្រលឹងតូចៗជាច្រើនហៅថា អាត្ម័ន ។ អាត្ម័នជាអ្នកបង្កើតជីវិត ។

កមិន (កម្ម) សំគាល់អំពើល្អ និងអាក្រក់ដែលបុគ្គលម្នាក់ៗបានធ្វើក្នុងជីវិតបច្ចុប្បន្ន ឬអតីតជាតិរបស់គេ។ កមិន ជាកម្លាំងម្យ៉ាងរុញច្រានអាត្ម័នអោយបែកចេញពីព្រហ្ម័ន ហើយបង្កើតជីវិតដែលជួបទុក្ខសោកគ្រប់បែបយ៉ាង ។ នៅពេលដែលអស់កមិន អាត្ម័នលែងវិលវល់នៅក្នុងវដ្តសង្សារក៏ត្រលប់ទៅភ្ជាប់ខ្លួនជាមួយព្រហ្ម័នវិញ

ហើយក៏បានសុខរហូត ។

ដើម្បីជៀសវាងកមិនអាក្រក់ ព្រាហ្មណ៍សាសនិកតែងតែធ្វើវិធីយោគៈ ដើម្បីអប់រំទូន្មានចិត្តអោយនឹងនរំងាប់កិលេស ធ្វើចិត្តអោយស្អាតបរិសុទ្ធ ។ ម្យ៉ាងទៀតព្រាហ្មណ៍សាសនិកមានទំនោរគោរពអាទិទេពណាដែលបង្កើតពិភពលោកដែលជួយយកអាសាសត្វលោក ហើយដែលមានគុណវិបត្តិតិច ។

ដូចនេះ សាសនាព្រាហ្មណ៍មានគោលការណ៍ច្បាស់លាស់ក្នុងការអប់រំផ្លូវចិត្តដើម្បីដឹកនាំមនុស្សឆ្ពោះទៅរកសេចក្ដីសុខក្នុងជីវិត ។

ក្រៅពីទស្សនៈអប់រំសីលធម៌របស់សាសនាខាងលើ គឺនៅមានគោលការណ៍អប់រំរបស់សាសនាដទៃទៀតដែលយើងមិនបានលើកយកមកវិភាគនោះទេ ។

ជារួម គោលវិធីអប់រំរបស់សាសនាទាំង ៤ ខាងលើនេះ បើចង់រួមចំណែកកសាងសង្គមជាតិខ្មែរអោយមានការរីកចំរើន ជាពិសេសធ្វើអោយប្រជាជនខ្មែរដែលមានជំនឿសាសនាផ្សេងៗនោះអាចរស់នៅក្នុងសង្គមជាតិបានសុខសន្តិភាពកសាងសង្គមបានតរៀងទៅ លុះត្រាតែចេះសំរបសំរួល គោរពសិទ្ធិក្នុងជំនឿគ្នាទៅវិញទៅមក ។

**អនុបណ្ឌិត គួយ ស្វសាន**

សាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិអប់រំ

---

ចូរអ្នកគូសសញ្ញា (✓) នៅខាងមុខប្រយោគដែលបញ្ជាក់ថា វាសកម្មភាពសីលធម៌ , (×) ជាសកម្មភាពអប់រំសាសនា និង (o) ជាសកម្មភាពផ្សេង ÷

ស្ថានភាព ក្នុងរឿងក្មេងលង់ទឹកម្នាក់ អាចមានមនុស្សច្រើនប្រភេទជួយសង្គ្រោះ ÷

១. ប៉ូលិសបានស្ទុះជួយស្រង់ ☐

២. បងប្អូន ឪពុកម្ដាយបានជួយស្រង់ ☐

៣. គេសង្ឃឹមថា ជួយស្រង់ក្មេងនេះពិតជាបានបុណ្យ ☐

៤. បុរសបានស្រង់ក្មេងរួចនាំទៅផ្ទះ សង្ឃឹមនឹងទទួលបានសគុណ ☐

៥. បុរសបានស្រង់រួច ណែនាំអោយក្មេងទៅកាន់លំនៅស្ថាន ហើយគេបន្តដំណើរទៅមុខ ☐

៦. បុរសកំពុងទាក់ទាញសន្ដានចិត្តនារី ស្រវាស្ទុះជួយស្រង់ ☐

ចំលើយនៅទំព័រ ៣៦



# ចិត្តវិទ្យា-អប់រំ

## បុគ្គលិកលក្ខណៈ

តើអ្វីដែលនាំអោយយើងប្រព្រឹត្តបែបនេះ? ហេតុអ្វីបានជាមានអ្នកខ្លះប្រព្រឹត្តអំពើល្អ អ្នកខ្លះទៀតជាមនុស្សអាក្រក់ផុតលេខ អ្នកខ្លះទៀតជាមនុស្សធុនកណ្តាល ?

បុគ្គលិកលក្ខណៈ (Personality) ជាលក្ខណៈនឹងនមានជាប្រចាំដែលធ្វើអោយមនុស្សប្រព្រឹត្តនូវអំពើកាយវិកា អាកប្បកិរិយាខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ (Personality : all the stable, consistent way in which the behavior of one person differs from that of others) ។

នៅសតវត្សទី ១៧ ទស្សនវិទូអង់គ្លេស Thomas Hobbes បានរកឃើញថា មនុស្សយើង មានចរិតពីធម្ម-ជាតិ អាត្មានិយម ។ ប្រសិនបើយើងចង់ការពារកុំអោយមនុស្សម្នាក់រំលោភលើមនុស្សម្នាក់ទៀត យើងត្រូវមានច្បាប់រឹងមាំនៅក្នុងសង្គម ។ រដ្ឋាភិបាលជាអ្នកតាមឃ្លាំមើលការអនុវត្តច្បាប់នោះ (a watchful government) ។

នៅសតវត្សទី ១៨ Jean-Jacques Rousseau ទស្សនវិទូបារាំងផ្នែកនយោបាយមានគំនិតថា មនុស្សកើតមកមានលក្ខណៈល្អពីធម្មជាតិ សង្គមជាអ្នកធ្វើអោយមនុស្សខូចអស់ ។ ដូច្នេះ រដ្ឋាភិបាលត្រូវរៀបចំអប់រំ និងលើកទឹកចិត្តផ្នែកសេរីភាពបុគ្គល (Education and government should promote the freedom of the individual) ។ មនុស្សដែលមានវិចារណញ្ញាណ តែងធ្វើអំពើទៅតាមចិត្តរបស់គេដើម្បីអភិវឌ្ឍសុខមាលភាពអ្នកផងទាំងពួង (Rational people acting freely, he maintained, would advance the welfare of all) ។

Sigmund Freud គ្រូពេទ្យអូទ្រីស បានរកឃើញថា មនុស្សកើតមកតែងតែមានមកជាមួយខ្លួននូវតំរូវការផ្លូវភេទ និងលក្ខណៈចង់តែបំផ្លាញ (People are born with sexual and destructive impulses that must be held in check if civilization is to survive. Natural impulses are detrimental to society.) ពោលគឺលក្ខណៈបំផ្លាញនេះហើយដែលនាំមនុស្សអោយធ្វើអំពើបំផ្លាញសង្គម បំផ្លាញពិភពលោក ។

លោក Carl Rogers (1902-1987) បានរកឃើញថា មនុស្សនឹងសំរេចបានគោលដៅដ៏ល្អ និងថ្លៃថ្នូរបាននៅពេលណាដែលគេមិនមានការរារាំងមិនសមហេតុផល ពោលគឺយើងត្រូវផ្តល់ឱកាសអោយមនុស្សព្យាយាមប្រឹង

ប្រែងធ្វើការងារ ដើម្បីសំរេចគោលដៅថ្លៃថ្នូររបស់គេ ។ មនុស្សតែងតែមានគោលដៅខ្ពង់ខ្ពស់ថ្លៃថ្នូរ និងល្អប្រសើរ (Human being will have natural impulse that are noble and good) ។

លោក Adler (1928-64) បានរកឃើញថា មនុស្សតែងតែត្រូវការទំនាក់ទំនងជាមួយអ្នកដទៃដើម្បីអភិវឌ្ឍតំរូវការសង្គម (social interest) របស់ខ្លួន ។ ការអភិវឌ្ឍទំនាក់ទំនងក្នុងសង្គមនេះក្នុងគោលបំណងអភិវឌ្ឍសុខុមាលភាពរបស់មនុស្សជាតិទាំងមូលផង រាប់ទាំងខ្លួនឯងផងដែរ ។ ដូច្នេះ មនុស្សតែងតែមានចិត្តចង់សហការជាមួយអ្នកដទៃ មិនមែនចង់ប្រជែងគ្នានោះទេ (People want to cooperate with other people, not to compete. ។

លោក Carl Rogers : មនុស្សតាំងពីកើតមកតែងតែខិតខំប្រឹងប្រែងដើម្បីអោយខ្លួនក្លាយទៅជាមនុស្សមានសមត្ថភាព និងគុណសម្បត្តិល្អប្រសើរប្រៀបបាននឹងដើមឈើដែលប្រឹងប្រែងលូតលាស់ឥតឈប់ឈរដូច្នោះដែរ ។

តើទស្សនៈមួយណាដែលត្រឹមត្រូវ? ចូរអ្នកកុំសំរេចចិត្តមួយណាដោយប្រញាប់ប្រញាល់អោយសោះ ព្រោះថា ចំណេះដឹង គំនិតសន្និដ្ឋានត្រូវតែទាញចេញអំពីករណីជាក់ស្ដែងអោយបានច្រើនពីក្នុងសង្គមដែលអ្នកធ្លាប់បានជួបប្រទះដោយផ្ទាល់ ។




ក្នុងនាមជាអ្នកអប់រំ សូមអ្នកដើរតួជាអ្នកសង្កេតនិយមបែបអនុមានរួម និងជាអ្នកអនុវត្តនិយម វាល្អប្រសើរជាងអ្នកទ្រឹស្ដីនិយម( អនុមានញែក) ព្រោះវិធីស្រាវជ្រាវតាមបែបសង្កេតនិយម ឬតាមបែបគុណវិស័យនេះ (qualitative study) អាចនាំយើងទៅដល់សមត្ថភាពកែលំអទ្រឹស្ដីអោយបានសមស្របទៀតផង ព្រោះថាចំណេះដឹង បទពិសោធន៍តែងតែរីកចំរើនតាមរយៈសកម្មភាពអនុវត្តក្នុងការងារ ។

( នៅមានត)

បណ្ឌិត អ៊ឹម គូច

# សង្គមកម្ម និងគ្រួសារ ការលែងលះគ្នា

## I. ផលវិបាកនៃការលែងលះគ្នា

តើការលែងលះគ្នាធ្វើអោយប៉ះពាល់ដល់ការអភិវឌ្ឍប្លែកៗពីគ្នាទៅតាមអាយុសិក្សារបស់សិស្សដែរទេ ?

នៅពេលណាមួយនោះ សាច់ញាតិ និងមិត្តភក្តិមានចិត្តរំភើបភ្ញាក់ផ្អើលខ្លាំងណាស់ កាលណាឮសួរគេ និយាយថា គេលែងលះគ្នា ។ សព្វថ្ងៃនេះ ការលែងលះគ្នាជារឿងដែលកើតឡើងជាធម្មតានៅក្នុងសង្គម ។ គេមានទស្សនៈមួយយល់ឃើញថា បញ្ហានេះធ្វើអោយមានបន្លាស់ប្តូរគ្រួសារគេ (លោក Ahrons និងលោក Rodgers, ១៩៨៧) ។ គេបានវាយតំលៃថា សិស្សសាលាពី ៤០ទៅ ៥០ភាគរយធ្លាប់មានបទពិសោធន៍ចំពោះឪពុកម្តាយគេដែលលែងលះគ្នាហើយគេនឹងចំណាយពេលវេលាគិតជាមធ្យមប្រាំឆ្នាំដែលខ្លួនគេត្រូវចិញ្ចឹម និងអប់រំដោយឪពុក រឺម្តាយមុនពេលដែលឪពុក រឺម្តាយគេត្រូវរៀបការជាមួយប្តី រឺប្រពន្ធថ្មីមួយទៀតនោះ (លោក Glick និងលោក Lin, ១៩៨៦) ។

ថ្វីត្បិតតែមានការយល់ព្រមអោយលែងលះគ្នានៅក្នុងសង្គមក៏ដោយ ការប៉ះពាល់ជាអវិជ្ជមានទៅលើកូន គ្មានអ្វីដែលផ្លាស់ប្តូរគួរអោយកត់សំគាល់ឡើយ ។ ជាទូទៅ ឪពុកម្តាយដែលមានទំនាក់ទំនងនឹងគ្នាតែងតែពាក់ព័ន្ធទៅនឹងការជួយសំរួលបញ្ហាផ្សេងៗដល់កូន ជាពិសេសកូនប្រុសដែលបញ្ចេញប្រតិកម្មតិចជាងកូនស្រី ចំពោះការលែងលះគ្នារបស់ឪពុកម្តាយ ។ មិនមែនមានន័យថា កូនទាំងអស់ដែលចេញពីប្រភពគ្រួសារឪពុក ម្តាយលែងលះគ្នានេះមិនអាចសំរបសំរួលខ្លួនបានក្នុងសង្គមនោះទេ ។ នៅក្នុងករណីខ្លះ ឪពុក រឺម្តាយដែលកាន់កាប់ផ្ទះសំបែងផ្តល់ផលប្រយោជន៍អោយកូនក្នុងការសិក្សា ច្រើនជាងឪពុកម្តាយដែលរស់នៅជាមួយគ្នាក្នុងផ្ទះមួយ តែមានទំនាស់នឹងគ្នាជារឿយៗទៅទៀត (លោក Hetheringto និងលោក Anderson, ១៩៨៨) ។

វាជាការលំបាកណាស់ ដើម្បីទស្សន៍ទាយអោយត្រូវថា តើកូនពិសេស រឺយុវជនពិសេស អាចឆ្លើយតបបានយ៉ាងដូចម្តេចនោះទៅនឹងការរស់នៅបែកគ្នារបស់ឪពុកម្តាយគេ និងការលែងលះគ្នានេះ ។ ដូចជាកត្តានៃអាយុរបស់កូននៅពេលដែលឪពុកម្តាយត្រូវបែកគ្នា ពេលនោះគេឃើញថា បុគ្គលិកលក្ខណៈរបស់កូន កំរិតនៃទំនាស់របស់ឪពុកម្តាយស្ថានភាពនៃសេដ្ឋកិច្ចគ្រួសារដែលកូនត្រូវរស់នៅជាមួយ និងគុណសម្បត្តិនៃចំណងទាក់ទងរបស់កូនជាមួយឪពុក រឺម្តាយដែលកូននោះស្នាក់នៅជាមួយ ទាំងនេះសុទ្ធតែជាកត្តាដែលត្រូវលើកយកមកពិនិត្យពិច័យសិក្សាស្រាវជ្រាវ ។ វាមិនមែនជាព្រឹត្តិការណ៍ដែលកើតឡើងងាយៗទេចំពោះការលែងលះគ្នានេះ ដែលធ្វើអោយមានការប៉ះពាល់ជាអវិជ្ជមានចំពោះកូន ។ ប៉ុន្តែហេតុការណ៍ដែលកើតឡើងទៅថ្ងៃក្រោយគឺថា ភាពជាឪពុក រឺជាម្តាយមិនស្និតស្នេរ ទំនាស់រវាងឪពុកនិងម្តាយ សេដ្ឋកិច្ចនៅក្នុងគ្រួសារជួបការលំបាកដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ដំណើរការអភិវឌ្ឍរបស់កូន និងការចេះសំរបសំរួលខ្លួនរបស់កូន ដើម្បីចុះសំរុងក្នុងសង្គម (លោក Emery, ១៩៨៨) ។

(១) តំលៃទី ២ នៃការគាបសង្កត់ផ្លូវចិត្តរបស់សិស្ស បន្ទាប់ពីឪពុក រឺម្តាយស្លាប់ ។

Applying Educational Psychology in the classroom-Thomas-Sally-David-2001

វាមិនមែនជារឿងដែលចេះតែលេចធ្លោឡើងងាយៗនោះទេ ដែលតម្រូវអោយលែងលះគ្នានោះ។ ការលែងលះគ្នានេះជះឥទ្ធិពលដល់កូនគ្រប់វ័យទាំងអស់ ។នៅក្នុងករណីខ្លះ សាលក្រមសំរេចលែងលះគ្នារបស់តុលាការត្រូវបានគេយកមកពិនិត្យពិច័យជាច្រើនឆ្នាំ បន្ទាប់ពីចាប់ផ្ដើមមានហេតុការណ៍នោះ ។ យុវសិស្សទទួលខុសត្រូវដោយខ្លួនឯងជាងវ័យកុមារ កាលណាឪពុកម្ដាយលែងលះគ្នា ។ ទោះជាយ៉ាងណាក៏ដោយ លោក Wallestein, លោក Corbin និងលោក Lewis (១៩៨៨) បានរាយការណ៍អោយដឹងអំពីទិន្នន័យដែលទទួលបានក្នុងរយៈពេល ១០ឆ្នាំ កន្លងមកនេះពីមជ្ឈដ្ឋានសិក្សាស្រាវជ្រាវពីកុមារដែលឪពុកម្ដាយលែងលះគ្នានៅរដ្ឋកាលីហ្វនីញ៉ា (California) ដោយចង្អុលបង្ហាញអោយដឹងថាវាមានភាពផ្ទុយគ្នាពីរបកគំហើញពីពេលមុនៗ គឺថាក្មេងធំៗមានការឈឺចាប់ក្នុងចិត្តខ្លាំងណាស់ចំពោះការលែងលះគ្នារបស់ឪពុកម្ដាយគេ ។ គាត់បានរកឃើញថា បុរស និងស្ត្រីដែលនៅវ័យក្មេងមានបញ្ហាផ្ទាល់ខ្លួន ហើយស្ត្រីច្រើនតែជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តល្មើស ជាពិសេសគឺភ័យខ្លាចនឹងការផិតក្បត់នេះឯង។

លោក Wallerstein និងលោក Kelly (១៩៨០) បានផ្ដល់នូវពត៌មានជាចម្លើយរួមអំពីការលែងលះគ្នាដែលទាក់ទិនទៅនឹងកំរិតអភិវឌ្ឍរបស់កូន ។ ចំពោះកូនដែលជិតដល់អាយុចូលរៀនតែងតែមានដំណើរវិវត្តថយក្រោយចំពោះទង្វើខ្លះៗដែលកូននោះទើបនឹងចេះដូចជាការចេះងូតទឹក ចេះចូលបង្គន់ ចេះស្លៀកពាក់ និងទៅសាលារៀន ។ កូនប្រភេទនេះ មានការភ័យខ្លាចបែកពីឪពុកម្ដាយ មានភាពមមើមមាយពេលដេកលក់ខ្លាចឪពុកម្ដាយបោះបង់ចោល ឆាប់ខឹងឆាប់យំ ហើយទារនេះទារនោះពីឪពុក រឺម្ដាយ ។ កូនដែលដល់អាយុចូលរៀនខ្លះ ត្អូញត្អែរថា តូចចិត្តនឹងវាសនាខ្លួនឯងណាស់ ព្រោះកើតមកជួបឪពុកម្ដាយលែងលះគ្នា ។

ចំពោះកូនដែលមានអាយុពី ៥ ទៅ ៨ឆ្នាំ បានស្រែកយំខ្លាំងណាស់ ហើយនិយាយបដិសេធមិនព្រមអោយឪពុកម្ដាយលែងលះគ្នា ។ ជាពិសេសកូនប្រុសមានការនឹករលឹកឪពុកគេណាស់ ហើយមានការខឹងសំបារនឹងម្ដាយខ្លាំងណាស់ កាលណាម្ដាយបណ្ដេញគេអោយចុះទៅតាមរកឪពុកនោះ ។ ស្នាដៃសិក្សាស្រាវជ្រាវរបស់សាលារៀនចំពោះសិស្សប្រភេទនេះ មិនទាន់បានទទួលជោគជ័យនៅឡើយទេ ។

កូនដែលមានអាយុពី ៩ ទៅ ១២ឆ្នាំ មានការខឹងសំបារខ្លាំងណាស់ ជាពិសេសនៅពេលដែលគេដឹងថា ឪពុកម្ដាយគេរករឿងទាស់ទែងលែងលះគ្នា ហើយគេព្យាយាមនិយាយសំរបសំរួលបញ្ចុះបញ្ចូលឪពុកម្ដាយគេអោយជានានឹងគ្នាវិញ ភាគច្រើននោះគឺថា កូនច្រើននិយាយអង្វរម្ដាយអោយចុះសំរុង រឺរណបឪពុកវិញ ។ កូនប្រភេទនេះ មានសេចក្ដីសោកសង្រេងខ្លាំងណាស់ មានការព្រួយបារម្ភតែម្នាក់ឯង ហើយកូនខ្លះទៀតកើតទុក្ខសោកសង្រេងនេះជាប់ពាក់ព័ន្ធទៅនឹងការសិក្សាដែលគេកំពុងតែរៀនពូកែផងក៏មានដែរ ។

ក្មេងជំទង់ដែលធ្លាប់មានបទពិសោធន៍រួចមកហើយ នៅក្នុងការអភិវឌ្ឍដ៏លំបាកលំបិនដោយខ្លួនគេផ្ទាល់ រឺតែទទួលនូវបញ្ហាជាបន្ថែមទៀតចំពោះការលែងលះគ្នារបស់ឪពុកម្ដាយនេះ។ គេក្លាយទៅជាអ្នករងទុក្ខព្រួយដោយគេយល់ឃើញថា ឪពុក រឺម្ដាយរបស់គេគ្មានព្រហ្មវិហារធម៌ក្នុងការជួយគិតគូរដល់អនាគតរបស់គេទេ ហើយលទ្ធភាពថ្លៃថ្នូរទៅតាមភេទ និងការមានគូស្រករបស់គេទៅថ្ងៃអនាគត ច្បាស់ជាគេទទួលបរាជ័យជាមិនខានទេ ។ នៅទីបំផុត កូនដែលជួបការលំបាកដោយសារឪពុកម្ដាយលែងលះគ្នា សុខចិត្តបណ្ដែតបណ្ដោយខ្លួនអោយរសាត់ឆ្ងាយពីគ្រួសារ ហើយស្វែងរកការពឹងពាក់ស្នាក់អាស្រ័យពីសំណាក់មិត្តភក្ដិវ័យស្រករគ្នា រឺមនុស្សចាស់ៗដែលជាទីពំនាក់បានរបស់គេ ។

## II. អន្តរាគមន៍ក្នុងការបង្រៀន

គ្រូគួររៀបចំអោយមានលទ្ធភាពក្នុងការជួយសំរបសំរួលបញ្ហាដល់សិស្ស បន្ទាប់ពីឪពុកម្តាយរបស់គេលែងលះគ្នាទៅ ជាពិសេសប្រសិនណាជាបន្លាស់ប្តូរក្នុងការចិញ្ចឹមថែរក្សាកូនមានជាប់ទាក់ទិនទៅនឹងសាលារៀន ។ និន្នាការនៃការកាត់បន្ថយការលែងលះគ្នានេះ អាចជួយណែនាំដល់ឪពុកម្តាយអំពីការលែងលះគ្នានេះ ។ ហេតុផលនៃការលែងលះគ្នានេះ អាចជះឥទ្ធិពលអាក្រក់ដល់អាកប្បកិរិយានិងការរៀនពូកែរបស់កូននៅក្នុងសាលារៀន ។

លោក Hammer និងលោក Turner (១៩៨៥) បានពិពណ៌នានូវគោលការណ៍ណែនាំដល់គ្រូបង្រៀន ចំពោះករណីសិស្សដែលមានឪពុកម្តាយលែងលះគ្នានេះ ដូចតទៅ ÷

- ណែនាំសិស្សនិងលើកទឹកចិត្ត សតិអារម្មណ៍របស់សិស្សអោយផ្តោតស្មារតីយកចិត្តទុកដាក់ស្តាប់គ្រូ និងទទួលយកចំណេះដឹងក្នុងការសិក្សាក្នុងថ្នាក់ ។
- ទទួលស្គាល់នូវទឹកចិត្តរំភើប និងគំនិតដោះស្រាយរបស់សិស្ស ។
- បើកទូលាយការរំពៃកញ្ជែកក្នុងថ្នាក់រៀនស្តីអំពីស្ថានភាពផ្សេងៗនៅតាមគ្រួសារសិស្ស ដោយចៀសវាងការពោលអាងទៅលើគ្រួសារមួយដែលមានតែឪពុក និងកូន រឺមានតែម្តាយ និងកូន ។ គ្រូត្រូវភ្ញាក់រលឹក តាមដានយកចិត្តទុកដាក់ទៅលើភាសាដែលសិស្សនិយាយប្រាប់គ្រូ ចៀសវាងការកំណត់គំនិត ដោយប្រើពាក្យថា គ្រួសារបែកបាក់ឪពុកម្តាយ ។
- ចៀសវាងការរំពឹងទុកថា សិស្សដែលរស់នៅក្នុងគ្រួសារមានតែឪពុក រឺមានតែម្តាយ ជាសិស្សដែលទទួលបរាជ័យក្នុងការសិក្សា ។ គ្រូត្រូវចេះលើកទឹកចិត្តសិស្សអោយរស់នៅក្នុងសេចក្តីសង្ឃឹមជានិច្ច ។
- ផ្តល់ពត៌មានអំពីការលែងលះគ្នារបស់ឪពុកម្តាយថា វាជារឿងដែលកើតឡើងជាធម្មតានៅក្នុងសង្គមទេ ។
- គ្រូត្រូវចេះបង្កើតចំណងទាក់ទងជាមួយឪពុកម្តាយសិស្សដែលរស់នៅបែកគ្នានេះ ប្រសិនណាជាគ្រូអាចធ្វើទៅបាន ។
- ជំរាបឪពុកម្តាយសិស្សអោយបានដឹងផងអំពីការថែទាំកូន និងការសំរួលពីបញ្ហាខ្វះខាតផ្សេងៗទៀតចំពោះកូនដែលកំពុងស្ថិតក្នុងវ័យសិក្សា ។
- បើសាលារៀនអាចធ្វើទៅកើត គួររៀបចំដាក់សិស្សដែលរស់នៅគ្មានឪពុកអោយរៀនថ្នាក់ណាមួយជាមួយលោកគ្រូ ប្រសើរជាងជាមួយអ្នកគ្រូ ។

**បណ្ឌិត ចាន់ រដ្ឋសុធា**

| "គ្រួសារសុខដុមរមនា អនាគតបុត្រធីតារុងរឿង" |
|---|

L'Education pour le XXI Siècle-Jacques Delors-UNESCO-1998




## ការអប់រំក្នុងសាលារៀនដ៏មានប្រសិទ្ធភាព

បញ្ហាដែលលើកឡើងពីប្រសិទ្ធភាពនៃការអប់រំនៅក្នុងសាលារៀនបង្កើតអោយមានកិច្ចពិភាក្សាគ្នាដ៏រស់រវើកក្នុងចំណោមអ្នកស្រាវជ្រាវ អ្នករៀបចំផែនការអប់រំ និងអ្នកធ្វើសេចក្តីសំរេចចិត្តនៅក្នុងវិស័យអប់រំ នារយៈពេលពីរ-បីឆ្នាំកន្លងទៅនេះ ។ អ្នកខ្លះបានអោយតំលៃលើការអប់រំដោយសង្កត់ធ្ងន់ទៅលើកត្តាទាំងឡាយដូចជា : ចំនួនសិស្សក្នុងមួយថ្នាក់ៗ ឬការផ្តល់ប្រាក់បំណាច់អោយដល់គ្រូបង្រៀន ។ គេហាក់ដូចជាមិនសូវយកចិត្តទុកដាក់ដល់ទិដ្ឋភាពដែលពាក់ព័ន្ធទៅនឹងគុណភាពនៃការសិក្សារបស់សិស្សដែលជាអត្ថប្រយោជន៍ដ៏រស់រវើកក្នុងសង្គមដូចជា តំលៃសីលធម៌ក្នុងសាលារៀន ភក្តីភាពរបស់គ្រូចំពោះការបង្រៀន និងការអប់រំសិស្ស ឬកិច្ចគាំទ្រពីឪពុកម្តាយសិស្ស ។ អត្ថបទស្តីពីប្រសិទ្ធភាពនៃការអប់រំធនធានមនុស្សនៅក្នុងសាលារៀនដូចដែលអ្នកខ្លះបានលើកឡើងនោះ ជាករណីស្រាវជ្រាវនៅក្នុងកិរិតទាបដែលពួកគេសំរេចបាននៅក្នុងសាលារៀនខ្លះ ឬថ្នាក់រៀនខ្លះ ដែលមិនអាចបកស្រាយបានយ៉ាងច្បាស់លាស់ពីលទ្ធផល និងគុណភាពនៃការសិក្សារបស់សិស្ស ។ អត្ថបទដែលមានលក្ខណៈសំបូរបែប ជាផ្លែផ្កានៃការស្រាវជ្រាវនៅក្នុងសាលារៀនរបស់សហរដ្ឋអាមេរិច និងអឺរ៉ុបបានផ្តល់នូវសេចក្តីសន្និដ្ឋានដែលមានទស្សនៈផ្សេងៗគ្នា តែវាមានលក្ខណៈពាក់ព័ន្ធគ្នាដែលគេអាចកំណត់បាននូវគំនិតមួយដ៏ភ្លឺស្វាងចំពោះលក្ខណៈពិសេសនៃការអប់រំដ៏មានប្រសិទ្ធភាពនៅក្នុងសាលារៀន ហើយដែលគេអាចលើកយកមកសង្ខេបបានដូចខាងក្រោមនេះ ÷

- បរិយាកាសសន្តិសុខ និងសណ្តាប់ធ្នាប់ប្រកបដោយវិន័យច្បាស់លាស់ដែលគេបានយកមកអនុវត្តប្រកបដោយសមធម៌ដ៏ពិតប្រាកដ
- ការសង្កត់ធ្ងន់ទៅលើសមត្ថភាពក្តាប់បានចំណេះដឹងជាសារវន្តរបស់សិស្ស និងការរេះរៀបចំផែនការបង្រៀន សំដៅធ្វើអោយបានសំរេចនូវការចុះសំរុងគ្នាជាមួយវត្ថុបំណងនៃការសិក្សា
- ការធ្វើការវាយតំលៃដាក់ពិន្ទុសិស្សលើកិច្ចការ និងតាមដានការសិក្សារបស់សិស្សអោយបានញឹក

ញ្ញាយផង

- ការធ្វើការណែនាំតាមលក្ខណៈគរុកោសល្យ និងរដ្ឋបាលដល់ជួរគ្រូបង្រៀន ហើយនាយកសាលាត្រូវប្រកាន់យកការអនុវត្តអោយបានម៉ឺងម៉ាត់ក្នុងជួរសហសេវិក និងជួរគ្រូបង្រៀនក្រោមឱវាទ
- មានសញ្ចេតនារឹងមាំ សាមគ្គីភាពស្អិតរមួតក្នុងជួរគ្រូបង្រៀន មានចិត្តស្មោះត្រង់ក្នុងសាលារៀន និងអ្នកដែលបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអភិវឌ្ឍសាលារៀន
- ការចេះបង្កើត និងកំណត់បាននូវវត្ថុបំណងអប់រំដ៏ច្បាស់លាស់ និងចេះលើកឡើងនូវសំណូមពរចំពោះលទ្ធផលនៃការសិក្សារបស់សិស្ស ៖ សាលារៀនទាំងមូលត្រូវរៀបចំអោយមានពិធីអបអរសាទរ និងមានផ្តល់រង្វាន់លើកទឹកចិត្តចំពោះលទ្ធផល និងស្នាដៃសិក្សារបស់សិស្ស
- ការចេះប្រើប្រាស់ពេលវេលាដ៏មានប្រសិទ្ធភាព និងប្រកបដោយអប្បបរមាចំពោះសកម្មភាពសិក្សានៅក្រៅសាលារៀន
- ការចេះទទួលយកគតិមាន និងកិច្ចគាំទ្រពីឪពុកម្តាយសិស្សចំពោះវត្ថុបំណងនៃការអប់រំនៅក្នុងសាលារៀននិងទំនួលខុសត្រូវរបស់សិស្ស ជាពិសេសចំពោះកិច្ចការដែលគ្រូដាក់អោយធ្វើនៅផ្ទះ ។

ស្នាដៃសិក្សាស្រាវជ្រាវជះឥទ្ធិពលយ៉ាងខ្លាំងដល់អភិបាលកិច្ចនៅក្នុងសាលារៀន តែវាក៏ជះឥទ្ធិពលផងដែរដល់កម្មវត្ថុនៃការទិតៀនដ៏រស់រវើកទៅលើវិធីសាស្ត្របង្រៀនតាមមុខវិជ្ជាឯកទេសរបស់គ្រូនៅតាមសាលារៀន ។ នៅតាមបណ្តាប្រទេសដែលកំពុងអភិវឌ្ឍ ក្រោយសង្គ្រាមអូសបន្លាយ ប្រសិទ្ធភាពនៃការបង្រៀន និងការអប់រំសិស្សក្នុងសាលារៀនស្ថិតនៅត្រង់ដែលរដ្ឋាភិបាលត្រូវតែយកចិត្តទុកដាក់នឹងជីវភាពគ្រូអោយបានគ្រប់គ្រាន់ ដើម្បីអោយគ្រូមានទឹកចិត្ត និងពេលវេលាច្រើនក្នុងការស្រាវជ្រាវមេរៀន និងរៀបចំផែនការបង្រៀនសិស្សអោយបានហ្មត់ចត់ និងទៀងទាត់ ការរៀបចំកម្មវិធីសិក្សា សៀវភៅសិក្សា និងវិធីសាស្ត្របង្រៀនអោយបានសមស្របទៅនឹងជីវភាពរស់នៅជាក់ស្តែងរបស់សិស្សតាមតំបន់ ការរៀបចំពេលវេលាអោយសិស្សបានរៀនពេញមួយថ្ងៃ ការរៀបចំខ្លឹមសារអប់រំសីលធម៌ដល់សិស្សអោយសមស្របតាមវប្បធម៌ប្រពៃណីសាសនារបស់ប្រទេសជាតិនីមួយៗ ។ ក៏ប៉ុន្តែគេទទួលស្គាល់ថា អត្ថបទដែលលើកឡើងពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាលធនធានមនុស្សនៅតាមសាលារៀនបានផ្តល់នូវសម្បទានដ៏មានតំលៃចំពោះកិច្ចពិភាក្សាគ្នា អំពីគុណភាពអប់រំសិស្ស និងការងារស្រាវជ្រាវនាពេលថ្មីៗនេះ ដែលស្ថិតនៅរណបភាពប្រែប្រួលផ្នែកបរិមាណ និងគុណភាពចំពោះវិញ្ញាសាប្រលងម្តងៗដ៏លំបាកដែលអាចផ្តល់នូវអត្ថប្រយោជន៍ដ៏មានតំលៃចំពោះប្រសិទ្ធភាពនៃការអប់រំនៅក្នុងសាលារៀន ថាជាការវាស់វែងបាននូវគុណភាពអប់រំនៅដំណាច់ឆ្នាំសិក្សានីមួយៗ ។

ទំហំនៃប្រសិទ្ធភាពក្នុងការអប់រំដូចដែលបានលើកឡើងខាងលើនេះ ត្រូវបានផ្សារភ្ជាប់ទៅនឹងបញ្ហាគ្រប់គ្រង និងរដ្ឋបាលរបស់ប្រព័ន្ធអប់រំនៅតាមសាលារៀន ។ គុណភាពនៃការគ្រប់គ្រង និងរដ្ឋបាលអប់រំនៅតាមប្រទេសខ្លះ ហាក់ដូចជាស្ថិតនៅឃ្លាតឆ្ងាយពីខ្លឹមសារអប់រំដែលគ្រូយកមកអនុវត្តនៅក្នុងថ្នាក់រៀន ហើយដែលគេ

អាចយកមកគិតពិចារណាទៅឃើញថា គុណភាពនៃការគ្រប់គ្រង និងរដ្ឋបាលនោះ ហាក់ដូចជាមិនសូវជះឥទ្ធិពល និងយកចិត្តទុកដាក់ទៅលើគុណភាពនៃការបង្រៀនរបស់គ្រូ ពោលគឺវិធីសាស្ត្របង្រៀន និងអប់រំសិស្សរបស់គ្រូម្នាក់ៗ ។ នៅពេលនោះ គេមានហេតុផលគ្រប់គ្រាន់ដើម្បីជឿជាក់ថា ការគ្រប់គ្រងវិស័យអប់រំបានល្អ គឺជាប្រការដ៏ចាំបាច់ក្នុងរង្វាយតំលៃទៅលើគុណភាពនៃការបង្រៀន និងអប់រំសិស្សរបស់គ្រូម្នាក់ៗផង ។ តាមពិតការគ្រប់គ្រងល្អ គឺស្ថិតនៅលើទិដ្ឋភាពទាំងឡាយដូចដែលយើងបានរៀបរាប់មកខាងលើស្រាប់ ។ នៅក្នុងបរិបទសព្វថ្ងៃនេះ រដ្ឋបាលអប់រំធ្វើអន្តរាគមន៍ដល់កំរិតអប់រំធំៗ បីយ៉ាងគឺ :

ទី១ កំរិតក្រសួងអប់រំបានដល់មុខងារដ៏សំខាន់របស់ផ្នែកផែន ការ ការតាក់តែងយុទ្ធវិធីតាមផ្នែក ការផ្ដល់សំភារៈ ការតាមដាន និងវាយតំលៃដោយកម្មវិធីប្រលងកំរិតជាតិ....

ទី២ គឺកំរិតមូលដ្ឋាន ពោលគឺរដ្ឋសហព័ន្ធខេត្ត ឬស្រុកដែលរចនាសម្ព័ន្ធរដ្ឋបាលត្រូវផ្ដល់នូវការទ្រទ្រង់ និងជំនួយដល់សាលារៀន ដោយធានាអោយមានដំណើរការជឿនលឿន ការតាមដានលទ្ធផលនៃការសិក្សារបស់សិស្ស និងកិច្ចទ្រទ្រង់ពីសហគមន៍ចំពោះសាលារៀន...

ទី៣ គឺរចនាសម្ព័ន្ធរដ្ឋបាលតាមសាលារៀន តួនាទីនៃការគ្រប់គ្រងរបស់នាយកដល់ដំណើរការប្រចាំថ្ងៃរបស់សាលារៀន ការរៀបចំដំណើរការប្រព្រឹត្តទៅនៃសាលារៀន និងការផ្ដល់សេចក្ដី ណែនាំដល់បុគ្គលិកសិក្សា ។

នៅក្នុងប្រទេសភាគច្រើន រដ្ឋបាលអប់រំត្រូវស្ថិតនៅក្នុងការគ្រប់គ្រងតាមបែបមជ្ឈការ ហើយនៅក្នុងប្រទេសខ្លះទៀត គេកំពុងតែរៀបចំអោយមានការគ្រប់គ្រងតាមបែបមជ្ឈការដូចគ្នានេះដែរ ។ នៅក្នុងប្រទេសមួយចំនួនទៀត ការស្រាវជ្រាវបានបង្ហាញអោយឃើញថា គេអាចលើកកំពស់ប្រសិទ្ធភាពនៃការអប់រំនៅក្នុងសាលារៀនបានដោយរៀបចំអោយមានការគ្រប់គ្រងតាមបែបវិមជ្ឈការទៅលើប្រព័ន្ធអប់រំទៅវិញ ។ ការដែលធ្វើបែបនេះបង្ហាញអោយឃើញថា គេមានបំណងចង់ផ្ដល់អោយសាលារៀននូវស្វ័យតភាព និងវិមជ្ឈការក្នុងការគ្រប់គ្រងបានដោយខ្លួនឯង ។ ជាទូទៅ សាលារៀនត្រូវតែរៀបចំអោយមានសភាពល្អត្រឹមត្រូវតាមនិយាមគរុកោសល្យដើម្បីឆ្លើយតបបានទៅនឹងតំរូវការ និងស្ថានភាពដ៏ចាំបាច់របស់សហគមន៍មូលដ្ឋានដែលតំរូវអោយមានការគ្រប់គ្រងមួយតាមបែបមជ្ឈការ ។ ការបង្រៀនពឹងផ្អែកមួយផ្នែកធំទៅលើចំណងទាក់ទងគ្នារវាងគ្រូ និងសិស្ស ។ ភាគច្រើននៃធនធានមនុស្សដ៏ចាំបាច់កើតមានពីក្នុងសាលារៀនតែម្ដង ហើយធនធានមនុស្សកំរិតខ្ពស់ក៏កើតឡើងពីកំរិតសិក្សាជាន់ខ្ពស់នៃសាលារៀនដែរ ដែលទាមទារអោយគេទាំងឡាយនោះសិក្សាពីកំរិតទាបឡើងទៅដោយប្រើពេលវេលាដ៏យូរអង្វែង ។ ម្យ៉ាងវិញទៀត ទិដ្ឋភាពផ្នែកគុណភាពនៃសាលារៀនមួយដែលមានប្រសិទ្ធភាពក្នុងការអប់រំនោះ អាចជួបការលំបាកនៅក្នុងរង្វាយតំលៃពីថ្នាក់ក្រសួងដែលសុទ្ធតែពួកការិយាល័យនិយមដ៏មានភាពស្មុគស្មាញ ឬក៏ពួកគេសុទ្ធតែជាអ្នកដែលទទួលបាននូវការអប់រំខាងបច្ចេកទេស និងការអនុវត្តតាមមុខជំនាញចំពោះការវាយតំលៃតាមសាលារៀនបានត្រឹមកំរិតមធ្យម ហើយដល់ពេលចុះអនុវត្តជាក់ស្ដែង គឺពួកគេវាយតំលៃមិនបានត្រឹមត្រូវ ឬផ្ដល់នូវរបាយការណ៍ភូតភរច្រើនពេកអោយថ្នាក់លើជឿ ។

តាមពិត មានតែនាយកសាលារៀននីមួយៗទេដែលមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការកំណត់

បានចំពោះរង្វាយតំលៃប្រកបដោយប្រសិទ្ធភាពចំពោះការគោរពបាននូវវិន័យ និងសីលធម៌វិជ្ជាជីវៈចំពោះគ្រូបង្រៀនម្នាក់ៗរបស់គាត់ តែទោះជាយ៉ាងណាក៏ដោយក៏លោកនាយកសាលាខ្លះនៅតែមិនទាន់អាចវាយតំលៃគ្រូអោយមានភាពសុក្រឹតទៅតាមបញ្ញត្តិទាំងពីរនេះ ប្រកបដោយភាពជាក់លាក់បានឡើយ ។ នៅមាននាយកសាលារៀនខ្លះទៀតនោះ ប្រកាន់នូវគំនិតទុទិដ្ឋិនិយម និងអាត្មានិយមប្រើសិទ្ធិវាយតំលៃតាមបែបលំអៀង ឬខ្វះគតិយុត្តិធម៌ទៅលើបុគ្គលិកសិក្សាដ៏ស្លូតត្រង់នៅក្រោមឱវាទ ។ ពេលខ្លះទៀត នាយកសាលាចូលចិត្តប្រើគំនិតអត្តនោម័ត គិតតែពីប្រយោជន៍ផ្ទាល់ខ្លួនដោយឥតអៀនខ្មាស់ដែលជាមូលហេតុធ្វើអោយបាត់បង់ប្រសិទ្ធភាព និងដំណើរការអភិវឌ្ឍនៃការអប់រំនៅក្នុងសាលារៀន ។

បណ្ឌិត ចាន់ រដ្ឋសុផា

## របៀបធ្វើចាប៉ី

(បទពាក្យ ៧)

ចាប៉ីដងវែងមានខ្សែពីរ ឬទាណាសំភីរាងសមសួន
ជាងសាយខៀវពិតព្រោះមានក្បួន ដងវែងចំនួនមួយម៉ែត្រសាម ៗ
បណ្ដោយស្នូកវាមានបួនតឹក ទទឹងនឹងនឹកស្នូក្យម៉ែត្រសាម
ឈើធ្វើចាប៉ីត្រូវធ្វើតាម សម្ពោកលោកហាមធ្វើតាមចង់ ៗ
គីខ្លក់ឈើឆ្លូវស្នូកដើមរាំង ដងដើមក្រសាំងឆ្អឹងធ្វើខ្នង
សន្ទះដើមត្នោតល្អបញ្ចង់ ត្រឹមត្រង់តាមក្បួនធើបព្រាយតាន់ ៗ
ចាប៉ីមិនស្ងួតលេងចូលគេ រិះរម្លាក់ឯងរឿងសំខាន់
រៀបរាប់បរិយាយសប្បាយក្រាន់ រឿងគ្រប់ជំនាន់តាមសម្ដី ៗ
ល្បិចល្បោយរាយល្បាយតាមប្រាជ្ញា រៀងរាល់សប្ដាហ៍រឿងចាស់ថ្មី
ផ្សាយតាមវិទ្យុទូរទស្សន៍ក្ដី ឆ្លើយឆ្លងសេចក្ដីន័យក្បោះក្បាយ ៗ

ទេព សាបាន

# ភាសា

## ក្រុមញាតិ

- ថ្នាក់ទី ៣
- ជំពូកទី ២ : ក្រុមញាតិ
- សៀវភៅសិស្សទំព័រទី ៤៩
- សៀវភៅគ្រូទំព័រទី ១០៦

**អត្ថបទជំនួយ :**

## ញាតកា ៧សន្តាន

ពាក្យ "ញាតកា ៧សន្តាន" នេះ ជាពាក្យដែលប្រជាជនខ្មែរយើងធ្លាប់ឮ ធ្លាប់ប្រើជាទូទៅ ពិសេសនៅក្នុងពិធីឧទ្ទិស រំលឹកនឹកដល់អ្នកដែលចែកឋានទៅ មានមាតាបិតា និងញាតកាទាំង ៧សន្តាន... ។

តើគេរាប់ថ្នាក់ណាខ្លះ ដើម្បីគំរប់បានជា ៧សន្តាននោះ ?

ញាតកា មានន័យថា ពួកញាតិ ។

ញាតិ គឺអ្នកដែលរួមខ្សែលោហិតនឹងគ្នា ខាងមាតា ឬខាងបិតា ។

ញាតកា ៧សន្តាន ឬញាតិ ៧ជួរនោះ តាមន័យក្នុងគម្ពីរពុទ្ធសាសនា លោកអោយរាប់ថ្នាក់ខាងលើ ៣ជាន់ គឺថ្នាក់មាតាបិតា១ ថ្នាក់ជីដូនជីតា១ ថ្នាក់យាយទួត តាទួត១ ថ្នាក់ខាងក្រោមខ្លួន៣ជាន់ទៀត គឺថ្នាក់កូន១ ថ្នាក់ចៅ១ ថ្នាក់ចៅទួត១ រួមជា៦ថ្នាក់ ជា៧ថ្នាក់និងខ្លួនយើង ។ មនុស្ស ទាំងប៉ុណ្ណោះហៅថាញាតិ ៧សន្តាន ។

តាមន័យក្នុងច្បាប់ក្រមរដ្ឋប្បវេណីខ្មែរ អោយរាប់ដូច្នេះថា អ្នកដែលកើតចេញមកពីគោត្រ(*) តែមួយ ហៅថាញាតិ ។ ញាតិមាន ២ ពួក គឺញាតិជួរខ្សែផ្ទាល់មួយពួក និងសាខាញាតិមួយពួក ។ ញាតិជួរខ្សែផ្ទាល់នោះគឺអ្នកដែលកើតតគ្នាពី១ទៅ១ តាមលំដាប់គឺឪពុក កូន ចៅ ចៅទួត ។ល។ រហូតដល់ជាន់ទី ៧ ។ ញាតិជួរនេះ តាមតែថ្នាក់ណានឹងថ្នាក់ណាក៏ដោយ ច្បាប់ហាមមិនអោយយកគ្នាជាប្ដីប្រពន្ធឡើយ ។ ចំណែកឯសាខាញាតិនោះវិញ គឺអ្នកដែលកើតចេញពីគោត្រជាមួយគ្នាដែរ តែបែកទៅជា មែកដទៃដូចយ៉ាងបងប្អូនបង្កើត មាមីង និងក្មួយ បងប្អូនជីដូនមួយ ជីទួតមួយចុះរៀងទៅ ។ ញាតិទាំងពីរខាងនេះ ច្បាប់អនុញ្ញាតអោយយកគ្នាជាប្ដីប្រពន្ធបាន ពីត្រឹមថ្នាក់ទី ៤ គឺត្រឹមបងប្អូនជីដូនមួយចុះរៀងទៅ (វចនានុក្រមខ្មែរសម្ដេច ជួន ណាត) ។

នៅមានទស្សនៈមួយទៀតយល់ថា ញាតកា ៧សន្តាន គឺរាប់អ្នកដែលកើតចេញពីគោត្រជាមួយគ្នាបែកទៅ

(*) គោត្រ ឬគោត្ត : វង្ស ត្រកូល សែ

ជាមែកជទៃរហូតដល់ ៧ថ្នាក់គឺបងប្អូនបង្កើត១ បងប្អូនជីដូនមួយ១ ជីទួតមួយ១ ជីលួតមួយ១ ជីលា១ ជីប៉ា១ និងចុងកុល ឬចុងគល់១ គំរប់ជា ៧សន្តាន ។ តាមទស្សនៈខាងលើនេះក៏ឃើញថា សមរម្យម្យ៉ាងដែរ ព្រោះថាញាតកាខ្មែរយើងមានឈ្មោះតែ ៧ថ្នាក់ ប៉ុណ្ណោះ ទោះរាប់ទៅលើក្ដី ទៅក្រោមក្ដី ឬទៅខាងក្ដី ។

៧ថ្នាក់ទៅលើ គឺឪពុកម្ដាយ ជីដូនជីតា ជីទួត ជីលួត ជីលា ជីប៉ា ចុងកុល ឬចុងគល់( ចុងត្រកូល?) ។

៧ថ្នាក់ទៅក្រោមគឺ កូន ចៅ ចៅទួត ចៅលួត ចៅលា ជីប៉ា ចុងកុល ។

ឯការរាប់ទៅខាង ក៏មាន៧ថ្នាក់ដូចមានជូនក្នុងមែកជទៃក្នុងគោត្រជាមួយគ្នាខាងលើនេះស្រាប់ ។

សេចក្ដីរៀបរាប់មកប៉ុណ្ណោះ ទុកគ្រាន់ជាគំនិតសំរាប់ការបកស្រាយពាក្យញាតកា៧សន្តានអោយបានជ្រាប និងជាការពិចារណាតទៅ ។

យស់ អ៊ាង

## រាជាធិបតេយ្យកម្ពុជា

### ព្រះរាជបច្ឆាញាតិនៃព្រះបាទអង្គអេង




លេខរៀងខាងលើបញ្ជាក់ពីលំដាប់លំដោយនៃការគ្រងរាជសម្បត្តិ

# ភាសា

- ថ្នាក់ទី ៤
- ជំពូកទី ២ : ទីកន្លែងសំខាន់ៗក្នុងសហគមន៍ ▪ សៀវភៅសិស្សទំព័រទី ៥២-៥៣
- មេរៀនទី ១ : អំណានទី១ : សេចក្ដីសុខរបស់ប្រជាជន ▪ សៀវភៅគ្រូទំព័រទី ១០៤-១០៥

## អត្ថបទជំនួយ:

សំណួរ :

| | ក | គ | ច | ជ | ត | ទ | | |
|---|---|---|---|---|---|---|---|---|
| ១ | ព្រះសង្ឃ | ព្រះរាជា | ភ្ញៀវកិត្តិយស | ឪពុកម្ដាយ | ទារក | អ្នកខ្ជិល | | |
| ២ | | ឆាន់ | សោយ | ទទួលទាន | ពិសា | ញ៉ាំ | ស៊ី | |
| ៣ | | | ចង្ហាន់ | ព្រះក្រយា | ភោជ-នាហារ | បាយ | បបរ | អ្វីក៏បាន |
| | | | ខ | ឃ | ឆ | ឈ | ថ | ធ |

- ចូរភ្ជាប់អក្សរគូខាងលើនេះ (គូសអង្កត់)
- ស្រង់ពាក្យតាមលំដាប់ពីជួរទី១ ទៅជួរទី ៣ ពីក្នុងការេដែលអង្កត់នីមួយៗកាត់ (ឃ្លា)
- អានឃ្លានីមួយៗ ។

ចំលើយ :

| | ក | គ | ច | ជ | ត | ទ | | |
|---|---|---|---|---|---|---|---|---|
| ១ | ព្រះសង្ឃ | ព្រះរាជា | ភ្ញៀវកិត្តិយស | ឪពុកម្ដាយ | ទារក | អ្នកខ្ជិល | | |
| ២ | | ឆាន់ | សោយ | ទទួលទាន | ពិសា | ញ៉ាំ | ស៊ី | |
| ៣ | | | ចង្ហាន់ | ព្រះក្រយា | ភោជ-នាហារ | បាយ | បបរ | អ្វីក៏បាន |
| | | | ខ | ឃ | ឆ | ឈ | ថ | ធ |

- អង្កត់ កខ, គឃ, ចឆ, ជឈ, តថ, ទធ ។
- ស្រង់ឃ្លា :
  - ព្រះសង្ឃឆាន់ចង្ហាន់ ។
  - ព្រះរាជាសោយព្រះក្រយា ។
  - ភ្ញៀវកិត្តិយសទទួលទានភោជនាហារ ។
  - ឪពុកម្ដាយពិសាបាយ ។
  - ទារកញ៉ាំបបរ ។
  - អ្នកខ្ជិលស៊ីអ្វីក៏បាន ។
- អាន

លោកស្រី តែង សុទ្ធរិទ្ធ សាស្ត្រាចារ្យចិត្តវិទ្យា-អប់រំ

# គណិតវិទ្យា

## ចំណុះ

- ថ្នាក់ទី ៦
- មេរៀនទី ១៣ : ចំណុះ
- សៀវភៅសិស្សទំព័រទី ១៥២-១៥៤

**អត្ថបទជំនួយ:**

១- ចូរប្តូរឯកតាខាងក្រោមនេះ ដើម្បីបញ្ជាក់អំពីចំណុះ សរសេរជាលេខគត់

៤,២៥ ហ.ល    ៦,២៧ ដា.ល    ៧,៤៨ល    ០,០៤៨ហ.ល    ០,០៩ល    ៤,៧ ហ.ល

**ចំលើយ :** ៤,២៥ ហ.ល = ៤២៥ល    ៦,២៧ ដា.ល = ៦២៧ ដ.ល    ៧,៤៨ល = ៧៤៨ ស.ល

០,០៤៨ ហ.ល = ៤៨ ដ.ល    ០,០៩ ល = ៩ ស.ល    ៤,៧ ហ.ល = ៤៧ ដា.ល

២- ចូររកឯកតា

៦,២៧ ដា.ល { ០,៦២៧....... ; ៦២,៧........ ; ៦២៧០....... ; ៦២៧......... }

៥៦,៤ ស.ល { ០,៥៦៤....... ; ៥៦៤........ ; ០,០៥៦៤....... ; ៥,៦៤......... }

**ចំលើយ :**

៦,២៧ ដា.ល { ០,៦២៧ ហ.ល ; ៦២,៧ ល ; ៦២៧០ ស.ល ; ៦២៧ ដ.ល }

៥៦,៤ ស.ល { ០,៥៦៤ ល ; ៥៦៤ ម.ល ; ០,០៥៦៤ ដាល ; ៥,៦៤ ដ.ល }

៣- ឈ្មួញម្នាក់ទិញស្រាចំនួន ៦ធុង ដែលក្នុង ១ធុងមានចំណុះ ១២៥លីត្រពីផ្សារ ។ ការដឹកជញ្ជូនថ្លៃ ២៥០០៛ ពន្ធក្នុង ១ធុងថ្លៃ ៩២០រៀល និងថ្លៃស្រាមួយលីត្រ ១៥០០រៀល ។ តើឈ្មួញត្រូវចំណាយប្រាក់អស់ប៉ុន្មាន ?

**ចំលើយ :**

ចំនួនស្រាទាំងអស់ : ១២៥ ល x ៦ = ៧៥០ ល

ថ្លៃទិញស្រា : ១៥០០៛ x ៧៥០ = ១១២ ៥០០៛

ថ្លៃពន្ធទាំងអស់ : ៩២០៛ x ៦ = ៥៥២០៛

ចំណាយទាំងអស់ : ១១២ ៥០០៛ + ៥ ៥២០៛ + ២ ៥០០៛= ១២០ ៥២០៛

ឈ្មួញត្រូវចំណាយទាំងអស់ចំនួន = ១២០ ៥២០៛

លោកស្រី កែវ សុទ្ធរិទ្ធ

# គំនូរ

## វិធីបង្រៀនគំនូរ(ត)

លោក ប៉ាន់ ត្រា

### <u>គំនូរលាបពណ៌តាមធម្មជាតិ (ត)</u>

**៤~ ចាបហើរ**

**៥~ ឆ្មាចាប់កណ្ដុរ**




ក្រដាស ស ទំហំ ១៨ x ២៤ ស.ម

<u>របៀបគូរ</u>

១. បន្ទាប់ពីការគូសបន្ទាត់សូន្យទាំងពីរលើផ្ទៃក្រដាសចតុកោណកែង គូសចតុកោណកែងមួយចំកណ្ដាលផ្ទៃក្រដាស បណ្ដោយ២០ស.ម ទទឹង ៩ ស.ម ដែលមានបន្ទាត់សូន្យទាំងពីរពុះចំកណ្ដាល គឺចតុកោណកែង ABCD (រូបទី ១) ។

២. ចែកផ្នែកចតុកោណកែងខាងឆ្វេងបន្ទាត់សូន្យ គឺជ្រុង AE និង DF ជាពីរភាគស្មើ ហើយគូសបន្ទាត់បញ្ឈរភ្ជាប់ចំណុចទាំងពីរនោះ បានជាចតុកោណតូច១បួន ។

៣. ចែកជ្រុង AG និង BH ជាពីរភាគស្មើ ហើយគូសបន្ទាត់យកចំណុចទាំងពីរនោះជាគោល ចាប់ពីបន្ទាត់សូន្យទៅជ្រុង BH (រូបទី ២) ។

៤. គូររង្វង់ពងក្រពើមួយក្នុងការេខាងលើ ហើយខាងស្ដាំនិងរង្វង់ពងក្រពើមួយទៀតក្នុងការេEBCF(រូបទី៣)

៥. គូរត្រចៀក ជើង កន្ទុយ (រូបទី ៤) ។

៦. គូរភ្នែក ច្រមុះ មាត់ ពុកមាត់ (រូបទី ៥) ។

<u>របៀបគូរ និងលាបពណ៌</u>

៧. យកដក់តូចដែលមានចុងស្រួច គូររូបរាងឆ្មានោះដោយប្រើពណ៌ខ្មៅ ។

៨. លាបពណ៌រោមស ពពាលខ្មៅ ឬត្នោត ។

៩. គូរភ្នែក ច្រមុះ មាត់ ពុកមាត់ ដោយប្រើជក់ស្រួច និងថ្នាំលាបពណ៌ខ្មៅ ។

១០. កណ្ដុរក៏ត្រូវលាបពណ៌ខ្មៅដែរ ។

១១. កាលណាគូរនិងលាបពណ៌ឆ្មានេះហើយ ត្រូវលាបពណ៌ថានពាក់កណ្ដាលខាងលើពណ៌ក្រហមចាស់លឿងចាស់ ។ល។ ពាក់កណ្ដាលខាងក្រោមពណ៌ត្នោត ដោយមានទុកខ្សែស ព័ទ្ធជុំវិញរូបភាពនោះ ។

## ផ្ទាំង និងខ្សែគុបតែងលំអ

សិស្សបានហាត់គូសគំនូសទាំង ៣ បែប គំនូសកោង និងរង្វង់មូលថែមទាំងយកគំនូសទាំងនោះមករចនាជារូបភាពផ្សេងៗ និង ខ្សែគុបតែងលំអជាច្រើនទៀត ។ ខាងក្រោមនេះគ្រូត្រូវអោយសិស្សដាក់ពណ៌លើផ្ទាំងគុបតែងលំអ និងខ្សែគុបតែងលំអ ÷

ក- ផ្ទាំងគុបតែងលំអ



(នៅមានត)




# ឥស្សា

(បទពាក្យ ៧)

ឥស្សាកិលេសដែលសៅហ្មង អាសាវៈ(១) ដោតក្រងជាប់ដួងចិត្ត
សំយោជនធម៌យ៉ាងល្អិត ព្រះអង្គត្រាស់ពិតមិនមែនស្មាន ។
បើកើតក្នុងចិត្តបុគ្គលណា ច្រណែនឈឺផ្សាពេញអង្គប្រាណ
លើអ្នកដទៃមិនដែលខាន ខ្លាចគេមានបានល្អលើសខ្លួន ។
បើគេធ្វើខុសកែតំរូវ បើគេធ្វើត្រូវតាមច្បាប់ក្បួន
ផ្លូវលោកផ្លូវធម៌ល្អសមសួន នោះមិនដែលខ្លួនសរសើរឡើយ ។
បើគេក្រខ្សត់ខ្លួនរីករាយ បើបានមាក់ងាយចិត្តធូរស្បើយ
បើគេធ្វើល្អជាងខ្លួនហើយ ចិត្តគ្មានល្ហែល្ហើយអន្ទះសា ។
ចេះតែមួរម៉ៅក្តៅក្រហាយ មិនសុខសប្បាយក្នុងកាយា
ព្រោះខ្លាចគេល្អលើសអាត្មា ក៏រកផែនការមកបៀតបៀន ។
បោះពាក្យសិកសៀតបញ្ឈឺចិត្ត បញ្ចៀងបញ្ចិតឥតខ្មាសអៀន
មានមុសាវាទជាប្រធាន និងអទិន្នាទានចូលលាយឡំ ។
ខាងក្រៅហ៊ឹកហ៊ាក់ផ្ទៀងផែនដី ចិត្តក្នុងអវិចីមកបន្ទំ
សំដីសំដៅពិរោះហំ ទាល់តែមើលចំដឹងថាចោរ ។

លោក : ឈាត ថេង

គ្រូបង្រៀនវិ.ដំដែក ខេត្តសៀមរាប

(១) សេចក្តីច្រណែន សេចក្តីឈ្នានីស (ឫស្យា),   (២) កិលេសជាគ្រឿងប្រកបចិត្ត រួមរិតដែលអាស្រ័យនៅនឹងចិត្ត

(៣) គ្រឿងត្រាំ ទឹកតម្រាំ កិលេសធម៌ដែលត្រាំនៅក្នុងសន្តានរួមមាន ៤យ៉ាង :

កាមាសវៈ(កាម), ភវាសវៈ(ភព), ទិដ្ឋាសវៈ(ទិដ្ឋិ) និង អវិជ្ជាសវៈ (អវិជ្ជា)

# ចាស់ទុំជាមគ្គុទ្ទេសក៍

(បទពាក្យ ៧)

វ័យមនុស្សលោកយើងចែកមានបី    ពេលនៅក្មេងខ្ចីរូបស្អាតស្រស់ថ្លា
លូតលាស់ទាំងកាយ រួមទាំងប្រាជ្ញា    បណ្ឌិតពោលថា ជាបឋមវ័យ ។
លុះធំឡើងយល់នូវអស់ហេតុការណ៍    អត្ថន័យខ្លឹមសារគ្មានចន្លោះអ្វី
ការងារស្រាលធ្ងន់ធ្វើបានដោយហី    បណ្ឌិតពោលខ្ចីថាវ័យយុវ៉ន ។
ថេរវេលាចេះតែទៅមុខ    មិននៅនឹងស្លុកអាចឈោងចាប់កាន់
រូបកាយនឹងចាស់មិនអាចឃាត់ខ័ណ្ឌ    បណ្ឌិតសន្និដ្ឋានជាមជ្ឈិមវ័យ ។
លោកធ្លាប់ឆ្លងកាត់វ័យ២ខាងដើម    ធ្លាប់ពិសោធន៍ច្រើនដឹងយល់សេចក្តី
កុលបុត្រខេមរាទាំងប្រុសទាំងស្រី    កើតរស់លើដីព្រោះគុណដូនតា ។
លោកហត់ទាំងកូនរហូតដល់ចៅ    ទោះបីភ្លៀងក្តៅឡើយហត់យ៉ាងណា
នៅតែតស៊ូដើម្បីគ្រួសារ    រៀបកូនហើយណានៅថៃចៅទៀត ។
លោកចេះចាំច្រើនការងារគ្រប់ផ្នែក    ជាងឈើជាងដែកស្បោងស្លុកសំពៀត
អង្រុតទ្រុងទ្រូ ចង្អេរល្អីទៀត    ត្បាញហូលគ្រប់ស្បៀតស្រស់ល្អវិចិត្រ ។
លោកជាអ្នកផ្តល់ចំណេះបន្ត    ប្រសើរបវរដល់កូនចៅពិត
ជំនាន់ក្រោយៗបានចេះចាំស្និទ្ធ    ដើម្បីជីវិតសមរម្យប្រពៃ ។
លោកបានបន្សល់កេរ្តិ៍មរតក    ទុកជាកញ្ចក់ឆ្លុះនូវស្នាដៃ
ទេពកោសល្យអស្ចារ្យស្អាតឥតបី    អង្គរល្បាញល្បីលើផ្ទៃសកល ។
លោកបំភ្លឺផ្លូវអោយប្រព្រឹត្តល្អ    តាមគន្លងធម៌ព្រោះជាកុសល
ទៅលោកឯនាយសូមអ្នកកុំឆ្ងល់    សប្បុរសបានផលតិចៗទាន់ក្មេង ។
អាសូរចាស់ទុំដែលកូនបោះបង់    អោយដើរត្រាច់ត្រង់សុំទានក្មេងៗ
ចំអ្នកចិត្តខ្មៅគេជៀលក្តែងៗ    ចាស់ហើយដើរស្វែងកូនចៅទៅណា ។
អាសូរចាស់ទុំដែលអត់ទីពឹង    គាត់នៅខំប្រឹងទាំងទឹកនេត្រា
ខ្លះបំរើគេបោកគក់តាមផ្សារ    ដើម្បីតណ្ហាបញ្ជាក្រពះ ។
ដូច្នោះកូនចៅត្រូវតែតបស្នង    អោយសមទំនងត្បិតលោកជាព្រះ
កុំរមិលគុណប្រួលប្រែក្រឡះ    តបវិញអោយណាស់ទាន់ខែនៅភ្លឺ ។

| | |
|---|---|
| ចូរអស់កូនក្មួយទូទាំងរដ្ឋា | ជួបចាស់កាលណាត្រូវជឹងត្រូវលី |
| ដោះមួកក្រមាវាចាបន្ទី | គាត់នឹងសរសើរដល់ម៉ែដល់ឪ ។ |
| រូបខ្ញុំបាទផ្ទាល់សូមសំណូមពរ | ច្បាប់ក្នុងនគរចារចែងតំរូវ |
| សូមមានប្រាក់ខែចាស់ៗផងទៅ | តិចតួចតទៅគ្រាន់បើជាងអត់ ។ |
| រូបខ្ញុំបាទផ្ទាល់សូមគោរពលា | បងប្អូនគ្រប់ថ្នាយាយតាកំសត់ |
| សូមមានសំណាងប្រាសចាកទុរគត | ទាំងក្រុងជនបទបានសុខសាន្តអើយ ។ |

លោក : អេង សុផល

បឋមសិក្សា កំរែង

ឃុំស្ដី ស្រុកបាភ្នំ ខេត្តព្រៃវែង

# នាយកធម៌

នាយកធម៌ (-យៈកៈធ័រ) ន. ជាធម៌របស់នាយក, ធម៌សំរាប់ជនអ្នកដឹកនាំ ឬអ្នកត្រួតត្រាអ្នកដទៃ។

បុគ្គលជាបព្វជិតក្តី គ្រហស្ថក្តី ដែលធ្វើជាប្រធានត្រួតត្រាលើអ្នកដទៃ គប្បីមាននាយកធម៌ ៦ យ៉ាង ប្រចាំនៅក្នុងសន្តានជានិច្ច គឺ:

១. ខមា - សេចក្តីអត់ធន់

២. ជាគរិយៈ - សេចក្តីភ្ញាក់រលឹករឿយៗ

៣. ឧដ្ឋានៈ - សេចក្តី ឧស្សាហ៍ខ្នះខ្នែង

៤. សំវិភាគៈ - ការចែករំលែក ឬការរំលែកអោយនូវវត្ថុផ្សេងៗ

៥. ទយា - សេចក្តីអាណិតអាសូរត្រាប្រណីគេ

៦. ឥក្ខណា - ការរំពៃមើលខុសត្រូវ ។

វីនាយកធម៌ ជំបរទាំងប្រាំមួយនេះឯងតែងលើកស្ទួយអោយនាយកមានតំលៃ ។

សម្តេចសង្ឃរាជ ជួន ណាត

# ដើមកំណើតរឿង "មួយពាន់ មួយយប់"

រឿងមួយពាន់មួយយប់ជាមធ្យោបាយ រឺជាទេពកោសល្យរបស់អ្នកនិពន្ធដែលប្រមូលផ្ដុំរឿងប្លែកៗដោយឡែកៗពីគ្នា ផ្សំឡើងអោយក្លាយជាសាច់រឿងតែមួយ ទំនាក់ទំនងតាមអត្ថរស អត្ថន័យ អត្ថរូបជាលំដាប់លំដោយរណ្ដំដួងចិត្តអ្នកអាន អ្នកស្ដាប់ស្ថិតក្នុងអារម្មណ៍រំភើប រំជើបរំជួលតាមខ្លឹមសារនៃរឿង ។ ជាអាទិ៍ គឺជារឿងនិទានរបស់ស្ដេចឆារីយ៉ា និងនាង សេហេរ៉ាហ្សាដ នាប្រទេសអ៊ីរ៉ាក់សម័យដើម ។

កាលនោះ មានស្ដេចមួយអង្គព្រះនាមឆារីយ៉ា គ្រាំគ្រាផ្លូវចិត្តដោយវិបត្តិគ្រួសារ ។ ព្រះអង្គបានចិញ្ចឹមព្រះទ័យប្រទូសរ៉ាយចំពោះព្រះអគ្គមហេសីជាទីស្រលាញ់ដែលច្រលំភ័ន្តជាមួយទាសៈជនជាតិស្បែកខ្មៅម្នាក់ ។ រីឯព្រះអនុជព្រះនាម ឆាសេណង់ សោយរាជ្យនៅនគរជាប់ព្រំប្រទល់គ្នា ក៏មានបញ្ហាដូចព្រះអង្គដែរ ។ ការលេចឡើងនូវបាតុភូតដ៏អាម៉ាសនេះ ស្ដេចឆារីយ៉ាក៏បណ្ដុះគំនិតព្យាបាទចំពោះស្ត្រីភេទ ។ គំនិតអាក្រក់កើរីកធំឡើងៗជារៀងរាល់ថ្ងៃ ហើយធ្វើអោយព្រះអង្គយល់ឃើញថា ព្រះអាទិទេពក៏ប្រហែលមានបញ្ហាដូចព្រះអង្គដែរ ។ ឆារីយ៉ាសំរេចព្រះទ័យថាលែងទុកចិត្តស្ត្រីទាំងអស់ ។ ក្នុងនាមជាមនុស្ស ព្រះអង្គលែងចង់ឃើញមាយាស្ត្រីទៀតហើយ ។ ព្រះអង្គប្ដេជ្ញាថា ទ្រង់ផ្ដុំជាមួយស្ត្រីក្រមុំពេញការម្នាក់មួយយប់ហើយយកទៅព្យួរកសំលាប់នៅព្រលឹមឡើងមុនថ្ងៃរះ ។ បទបញ្ជានេះ បានប្រព្រឹត្តទៅជាច្រើនឆ្នាំរហូតដល់ពេលមួយដែលនៅសល់តែកូនក្រមុំរបស់មន្ត្រីម្នាក់នៃព្រះរាជាណាចក្រ ។ កញ្ញាសេហេរ៉ាហ្សាដ ជាកូនក្រមុំរបស់មន្ត្រីក្នុងវាំងរបស់ស្ដេច ។ នាម៉ឺនរូបនេះ មិនចង់អោយកូនស្រីរបស់ខ្លួនស្លាប់ តែនាងទទូចប្រាប់ឪពុកថា អោយយកនាងទៅថ្វាយស្ដេចក្នុងគោលបំណងជួយរំដោះមនុស្សស្រីក្នុងប្រទេសអោយឆ្លងផុតពីបាបកម្មនេះ ។ តែបើផ្ទុយទៅវិញនោះ នាងស្លាប់ក៏ស្លាប់ដោយខ្លឹមសារ និងកិត្តិយសថ្លៃថ្នូរដែរ ។ នាងមានគំនិតស្អប់ព្រះមហេសីដែលក្បត់ចិត្តស្ដេច តែព្រះមហេសីសព្វថ្ងៃអស់តំលៃហើយ ដូចនេះនាងអាចរកច្រកជួយដល់ស្ត្រីដែលសល់ពីស្លាប់បាន ។

សេហេរ៉ាហ្សាដបានសិក្សាជ្រៅជ្រះ មានចំណេះដឹងច្រើន មិនឆ្មើងឆ្មៃ ព្រមទាំងជាអ្នកនិពន្ធផង ។ ពេលនេះនាងនឹងប្រើប្រាស់ទេពកោសល្យនិទានរឿងអោយបានល្អប្រសើរបំផុតចំពោះស្ដេច ។

វិធីសាស្ត្ររបស់នាង គឺការនិទានរឿងថ្វាយស្ដេចដែលចង់ស្ដាប់ ចង់ដឹង និងងប់ងល់នឹងសាច់រឿងដែលបាននិទានរួច និងចង់យល់ដឹងបន្តទៀត ពីព្រោះវាពិរោះជាប់ចិត្តរហូតដល់ថ្ងៃណាមួយដែលស្ដេចអាចលើកលែងការសំលាប់នាងបាន ។ នេះជាផែនការបណ្ដោះអាសន្នរបស់នាង ឯសេចក្ដីសង្ឃឹម វាស្ថិតនៅលើចំណេះដឹង និងសាច់រឿងគួបផ្សំនឹងសិល្បៈនិទានរបស់នាង ។ ទស្សនៈរបស់ស្ដេច គឺការចងកំហឹងនឹងស្ត្រី ព្រះអង្គមិនចង់អោយភេទនេះឆ្លិនព្រះនេត្រព្រះអង្គទៀតទេ ។ នៅក្នុងវាំងពេលរាត្រីក្រោយពីស្ដេចឆារីយ៉ាបានសប្បាយនឹងតណ្ហារួចហើយ នាងសេហេរ៉ាហ្សាដលើកសំណូមពរថ្វាយស្ដេចថា អោយប្អូនស្រីឌីណាហ្សាដមកដេកជាមួយនាងដើម្បីស្ដាប់នាងនិយាយ

រឿងអោយស្តាប់មុននឹងស្លាប់នាថ្ងៃស្អែក ។ ស្តេចយល់ព្រម ។ ក្នុងរយៈពេលមាន់រងាវ "កុរ" នាងឌីណាហ្សាដ ក៏ដាស់បងស្រីអោយនិយាយរឿង និងថ្វាយជូនស្តេចអោយសព្វព្រះទ័យផង មុននឹងបែកគ្នាជាអវសាន។ សេហេរ៉ាហ្សាដចាប់ផ្តើមនិទានរឿងទី១ ឡើងលុះត្រាណាថ្ងៃរះនាងក៏ឈប់ដោយរក្សាទុកនូវអាថិកំបាំងបន្តដែលធ្វើអោយស្តេចចង់ដឹង ចង់ស្តាប់បន្តទៀត ។ ស្តេចឆារីយ៉ា មានព្រះឱង្ការថា "យើងរង់ចាំដល់ថ្ងៃស្អែកនឹងយកនាងទៅសំលាប់ចោល ក្រោយពីស្តាប់សាច់រឿងចប់" ។ ក៏ប៉ុន្តែ ទំនាក់ទំនងនៃសាច់រឿងបានផ្សារភ្ជាប់គ្នារដឹករហូតដល់មួយពាន់ និងមួយយប់ ។

ការនិទានរឿងបានដល់ជិតបីឆ្នាំដែលនាងសេហេរ៉ាហ្សាដ អាចឈានទៅកែប្រែផ្លូវចិត្តរបស់ស្តេចឆារីយ៉ាបានល្អវិញ ។ ដំណោះស្រាយនៃការរំដោះស្ត្រីក្រមុំអោយផុតពីរណ្តៅមរណៈកើតមាននៅយប់ទីមួយពាន់ និងមួយយប់ នាពេលដែលខ្សែរឿងបានជុំជាតិ ។ ពេលនោះស្តេចឆារីយ៉ា និងនាងសេហេរ៉ាហ្សាដ ក្លាយទៅជាស្វាមីនិងភរិយាដ៏ល្អក្នុងព្រះរាជាណាចក្រព្រមទាំងបានព្រះរាជបុត្រល្អមួយអង្គជាភស្តុតាងផង ។ ច្បាប់ពិឃាដស្ត្រីក្រមុំក៏រលាយបាត់ ។ ព្រះអង្គឆារីយ៉ាក៏លែងមានព្រះទ័យចង់ព្យាបាទចំពោះស្ត្រីភេទចាប់ពីពេលនោះមក ។

**លោក : ឌិ សាខ៉ាន់**

**មន្ត្រីអប់រំចូលនិវត្តន៍ ខេត្តកំពង់ចាម**

**ប្រែសំរួលពីភាសាបារាំងរបស់លោក Brouno Bettelheim**

**ក្នុង Français (Textes et Activités) ទំព័រ ១៤៩-១៥០**

**ចំលើយទំព័រ ១៦**

១- ...................... ☐

២- ...................... ☐

៣- ...................... ☒

៤- ...................... ☐

៥- ...................... ☑

៦- ...................... ☐

# ល្បែងផ្គុំអក្សរ

សូមអ្នកគ្រូ លោកគ្រូផ្គុំព្យាង្គ និងអក្សរនីមួយៗទាំងនេះអោយបានត្រឹមត្រូវ ដើម្បីឆ្លើយតបនឹងចំណុចទាំង ដប់ដូចខាងក្រោមនេះ ÷

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សុ | បញ្ញ | តុ | សម្មា | ច | ផោ | កា | ឥ | ភ | ក |
| ល | ម | ច្ឆ | ដ្ឋ | សង្ក | សិ | សុទ្ធា | ត្ត | | |
| លះ | ព | ស្សា | ន្ទះ | ព្វ | ក្ខុ | ប្បះ | ត | វាស | ន្ត ។ |

១- ឈ្មោះគម្ពីររបស់ព្រះត្រៃបិដក

២- ឈ្មោះឋានព្រហ្មជាលំនៅរបស់ព្រះអានាគាមិបុគ្គល

៣- ឈ្មោះឋានទេវតាក្នុងចំណោមឋានទាំង ៦ ជាន់

៤- អង្គរបស់អដ្ឋង្គិកមគ្គទាំង ៨

៥- អង្គរបស់អាយតនៈខាងក្នុងទាំង ៦

៦- អង្គរបស់អាយតនៈខាងក្រៅទាំង ៦

៧- អង្គរបស់នីវរណៈធម៌ទាំង ៥

៨- អង្គរបស់សំយោជនៈ ១០

៩- អង្គទី ១០ របស់បដិច្ចសមុប្បាទទាំង ១២

១០- កំណើតសត្វចាប់បដិសន្ធិដំបូងក្នុងគភ៌

**ចំលើយ**

ឧទាហរណ៍ : ឈ្មោះគម្ពីររបស់ព្រះត្រៃបិដក គឺ សុត្តន្ត ។

*ចំលើយនៅទំព័រ ៤០*

ដោយលោក : ឈាត ថេខ គ្រូវិ.ដំដែក

ស្រុកសូទ្រនិគម ខេត្តសៀមរាប



## ពិធីធ្វើស្លឹករឹត (តចប់)

### ខ. ចារសាស្ត្រា

របៀបសរសេរអក្សរនៅលើស្លឹករឹត ធ្វើអោយមានស្នាមច្បាស់ លុះត្រាតែមានសំភារៈច្រើនយ៉ាង ÷

១- <u>ដែកចារ</u> : គេយកឈើធ្វើអោយមូលប៉ុនកូនដៃប្រវែងពី ២តឹក ទៅ ៣ តឹក គេយកម្ជុលខ្នាតធំទៅកាត់អោយខ្លីល្មម រឺយកម្ជុលម៉ាស៊ីនដេរមកវាយបង្កប់ចំកណ្ដាលតាមសាច់បណ្ដោយ ។ គេយកកាំបិតមុតមកចិតប្រម៉ុមមុខយកទៅសំលៀងនឹងថ្ម ។ បើតាមចាស់ៗគាត់បានប្រាប់ថា ការសំលៀងចុងដែកចារមាន ២ បែប ÷

- បែបទី ១ : គេសំលៀងចុងដែកចារអោយមានរាងមូលស្រួច
- បែបទី ២ : គេសំលៀងចុងដែកចារធ្វើអោយមុខ ៤ ជ្រុងស្រួច ។

ការសំលៀងចុងដែកចារមាន ២ យ៉ាងបែបនេះ យោងទៅតាមចំណង់ចំណូលចិត្តរបស់អ្នកចារ ។

២- <u>ធ្វើស្នាប់ដៃ</u> : ស្នាប់ដៃជាអ្វី? កំណាត់បន្ទះក្ដារប្រវែងប្រហែលជា ៣តឹក រឺជាង ៣តឹកដែលមានទទឹងប៉ុនស្លឹករឹត ។ គេយកស្លឹករឹតមកចាក់ធ្វើអោយមានក្បាលដូចជាក្បាលខ្សែក្រវ៉ាត់សំរាប់ស៊កឹរឹតឈើស្នាប់ដៃនោះ ហើយយកស្លឹករឹតមកស៊កបញ្ចូលក្នុងក្រវ៉ាត់នោះ កុំអោយស្លឹករឹតងាកចេញទៅខាងបាន ។

៣- <u>របៀបសរសេរចារ</u> : គេយកដៃឆ្វេងចាប់យកស្នាប់ដៃមកក្ដាប់អោយជាប់ មេដៃឆ្វេងយកទៅសង្កត់លើស្លឹក ។ មេដៃឆ្វេងមាននាទីសង្កត់ស្លឹករឹតផង លួចរុញបង្អិតស្លឹករឹតទៅមុខជាបណ្ដើរៗផង ។ គេយកដៃស្ដាំចាប់យកដងដែកចារទៅដាក់សង្កត់លើមេដៃឆ្វេងចុចចុងដែកចារអោយដាច់ស្លឹករឹតធ្វើជាអក្សរ ។

៤- <u>ធ្វើទឹកល្បប់លាប</u> : គេកោសបាតឆ្នាំងដីយកធ្យូងកិនអោយម៉ត់ រឺយកប្រេងភ្លើងទៅលាយនឹងជ័រ

ទឹកថ្នាល្អ កូរច្របល់គ្នាអោយសព្វល្អកុំអោយរាវពេក រឺខាប់ពេក ។

៥- លាបស្លឹករឹត : គេយកទឹកល្បប់ទៅលាបស្លឹករឹតដែលគេចារហើយនោះអោយពេញសព្វកុំអោយមានសល់ចន្លោះ ។ បើលាបពេញសព្វហើយ ទើបគេយកទៅសំដិលហាលអោយស្ងួតល្អ ។

៦- ជូតស្លឹករឹតអោយស្អាត : គេយកកន្ទក់អង្ករម៉ត់ល្អ រឺដីខ្សាច់ម៉ត់ល្អទៅដាក់ក្នុងថាសធំ គេយកស្លឹករឹតដែលប្រលាក់នោះទៅជូតនឹងកន្ទក់ រឺដីខ្សាច់នោះអោយជ្រះស្អាតល្អ ។ កាលបើជូតស្អាតល្អហើយ ទើបស្លឹករឹតនោះមើលឃើញអក្សរច្បាស់ ។

៧- ធ្វើឈើឃ្នាបថ្មី : របៀបធ្វើឈើឃ្នាបថ្មីមានរបៀបដូចកាលពីធ្វើមុន ។ កាលបើបានរៀបស្លឹករឹតបញ្ចូលក្នុងឈើឃ្នាបរួចហើយ គេសំលៀងដែកឈូសអោយមុតយកទៅឈូសស្លឹករឹតអោយត្រង់ យកក្រដាសខាត់ម៉ត់មកខាត់អោយរលីងស្អាតល្អ ។

៨- ទឹបមាស : គេយកទឹកម្រក្សណ៍ រឺទឹកជាតិហិង្គុលទៅលាបស្លឹករឹតអោយបានច្រើនដងទុកអោយស្ងួត។ គេយកទឹកមើមខ្ទឹមសទៅលាបនៅកន្លែងដែលត្រូវទឹបមាសនោះ ។ កាលបើគេលាបទឹកមើមខ្ទឹមសហើយ ទើបគេយកស្លឹកមាសមកទឹបនៅកន្លែងនោះ ។ គេគ្របទុកអោយជិត រាប់ណាស់ក៏ចំនួន ៧ ថ្ងៃដែរ ទើបហ៊ានបើកចេញ ។

៩- រៀបស្លឹករឹតតាមទំព័រ : គេយកស្លឹករឹតមករៀបតាមទំព័រ តាមខ្សែរួចហើយ ទើបគេយកស្លឹករឹតទៅកាត់ចុងដើមអោយស្មើល្អ ទើបគេយកខ្សែសាស្ត្រាទៅដោតតាមរន្ធ ។

១០- ធ្វើខ្សែសាស្ត្រា : របៀបធ្វើខ្សែសាស្ត្រា គឺគេយកសរសៃអំបោះ រឺសរសៃសូត្រដែលគេបានជ្រលក់ពណ៌ផ្សេងៗពីគ្នាមកលាយចំរុះគ្នាចាក់កន្ទុយកណ្តុរធ្វើជាខ្សែសាស្ត្រា ។

## ច. ចំណងរឹត

កាលបើគេរៀបសាស្ត្រាបានត្រឹមត្រូវហើយ គេត្រូវយកចំណងរឹតសាស្ត្រាអោយមានរបៀបបែបផែនល្អ ÷

១. ក្របនៅអមសាស្ត្រា : គេយកបន្ទះក្ដារដែលបន្ទារនិងប្រវែងប៉ុននឹងប្រវែងស្លឹករឹត និងមានទោលកំរាស់ប្រហែលជា ២ ហ៊ុន ។ ខ្លះគេយកក្របទៅឆ្លាក់ពីខាងក្រៅនូវក្បាច់ផ្សេងៗតាមចំនូលចិត្តនៃការស្រលាញ់នៃមនុស្សម្នាក់ៗតាមលក្ខណៈខ្មែរ ។

២. ខ្សែចំណងសាស្ត្រា : គេយកសរសៃអំបោះដែលមានចំរុះពណ៌ផ្សេងទៅផ្ទួលចាក់ជាខ្សែកន្ទុយកណ្តុរមានរង្វង់ក្បាល មានទំហំប៉ុនចង្កើះ មានប្រហែលជា ២ ជុំកន្លះទៅ ៣ជុំ នៃជុំសាស្ត្រា ។ កាលបើគេរៀបស្លឹករឹតតាមលេខរៀងនៃកណ្ឌនីមួយៗបានហើយ គេត្រូវរៀបតាមលំដាប់ខ្សែទៀត ទើបគេយកឈើក្របមកដាក់នៅអមសាស្ត្រាម្ខាងមួយៗ ។ គេយកខ្សែចំណងសាស្ត្រាមកចងឆ្វាក់រឹតអោយតឹង ។

## ឆ. ព្រួលរុំសាស្ត្រា

កាលបើគេយកឈើក្របទៅដាក់អមនៅពីខាង ទើបគេយកខ្សែចំណងសាស្ត្រាទៅចងរឹតបានល្អហើយ តែ

នៅមានធូលីហុយចូលទៅប៉ះសាស្ត្រាមានភាពមិនស្អាតល្អ ។ ដោយមានចិត្តគោរព និងស្រលាញ់សាស្ត្រាជាឯកសារផ្សេងៗ គេនាំគ្នាធ្វើព្រួលរបុំសាស្ត្រាសំរាប់យកមករុំព័ទ្ធសាស្ត្រាកុំអោយមានធូលីហុយចូលមកប៉ះសាស្ត្រាបាន ។ របៀបធ្វើព្រួលរបុំសាស្ត្រាបែបនេះ ÷

១. __ទ្រៀសព្រួលរបុំសាស្ត្រា__ : គេយកទ្រនុងរឹតដែលគេបានច្រៀកចេញពីស្លឹកទ្រាំងពីពេលមុននោះ មកកាត់ប្រវែងសាស្ត្រា រឺវែងជាងបន្តិច ។ គេយកកំណាត់ទ្រនងរឹតមកបិតអោយបានស្អាតល្អល្មមយកក្រងបានប្រវែង ១ជុំកន្លះនៃជុំសាស្ត្រា ។

២. __ក្រងព្រួលរបុំសាស្ត្រា__ : គេយកសរសៃអំបោះដែលមានចំរុះពណ៌ផ្សេងៗទៅផ្ទួលក្រងទ្រៀសព្រួលរបុំសាស្ត្រានោះអោយបានស្អាតល្អ ។ ការក្រងព្រួលរបុំសាស្ត្រានោះធ្វើអោយកំរងត្រង់ល្អគួរជាទីស្រលាញ់ និងធ្វើអោយមានកំរងញឹក ( មានកំរងជិតគ្នា) ។

៣. __ពាសសំពត់ភ្ជាប់នឹងព្រួល__ : គេយកសំពត់ល្អដែលមានតំលៃខ្ពស់ដូចជាសំពត់ហូល, សំពត់ផាមួង... មកដេរភ្ជាប់នឹងព្រួលរបុំសាស្ត្រានោះធ្វើអោយមានលំអ ធ្វើអោយមានភាពសមរម្យសំរាប់ជាតិខ្មែរ ពីព្រោះជាឯកសារមានតំលៃខ្ពស់បំផុត ។

៤. __ដេរភ្ជាប់ខ្សែចំណងនឹងព្រួលរបុំ__ : គេយកខ្សែចំណងដែលមានប្រវែង ១ ជុំកន្លះទៅ ២ជុំ នៃជុំសាស្ត្រាដែលមានចំនួន ១ រឺចំនួន ២ ទៅដេរភ្ជាប់នៅខាងចុងព្រួលសំរាប់ចងរុំបន្ថែមទៀត ។

**__ការសន្និដ្ឋាន__** : ការធ្វើបែបខាងលើនេះបានបញ្ជាក់អោយឃើញថា ខ្មែរមានលក្ខណៈព្យាយាមស្វិតស្វាញ និងមានភាពគោរពស្រលាញ់ឯកសារនានា ដែលមានសរសេរពីព្រះពុទ្ធសាសនាក្តី ព្រាហ្មណ៍សាសនាក្តី អរិយធម៌ខ្មែរក្តី ជាទីបំផុត ។

**លី សុទ្ធីរ អតីតសាស្ត្រាចារ្យមធ្យមសិក្សា**

__ចំលើយល្បែងផ្គុំអក្សរទំព័រទី ៣៧__

| | |
|---|---|
| ១. សុត្តន្ត | ២. បញ្ចសុទ្ធាវាស |
| ៣. តុសិត | ៤.សម្មាសង្កប្បៈ |
| ៥. ចក្ខុ | ៦.ជោដ្ឋព្វ |
| ៧. កាមច្ឆន្ទៈ | ៨. ឥស្សា |
| ៩. កលលៈ | ១០. ភព |

# ដើមទ្រូង ៥ ហត្ថ

ចាស់បុរាណគាត់បាននិយាយប្រាប់កូនចៅថា "មនុស្សប្រុស បើមិនបានបួស គឺមិនពេញលក្ខណៈជាបុរសមាន ដើមទ្រូង ៥ហត្ថទេ" ។ តើអត្ថន័យនេះយ៉ាងណា ?

ដើមទ្រូង ៥ហត្ថមានអត្ថន័យសំខាន់ ២ យ៉ាងគឺ :

- អ្នកបួសជាភិក្ខុភាវៈក្នុងពុទ្ធសាសនា មានបរិក្ខា ៨ (អដ្ឋបរិក្ខា)សំរាប់ប្រើប្រាស់គឺ ១-ស្បង់ សំពត់សំរាប់ស្លៀក ២-ចីពរ សំពត់សំរាប់បិទបាំងរាងកាយ ៣-សង្ឃាដី សំពត់សំរាប់ដណ្តប់ការពាររងារ (សង្ឃាដីដេរត្រួតគ្នាពីរជាន់) ៤-វត្ថពន្ធចង្កេះ សំពត់សំរាប់ក្រវាត់ពីលើស្បង់កុំអោយរបូត (ខ្សែក្រវាត់) ៥-បាត្រ គឺជាសំភារៈ ឬជាឆ្នាំងសំរាប់ទទួលចង្ហាន់ពីទាយក ទាយិកា ៦-កាំបិតកោរ (ក្នុងពុទ្ធវិន័យផ្នែកអភិសមាចារអនុញ្ញាតអោយព្រះសង្ឃទុកសក់ត្រឹមរយៈ ពេលពីរខែ ឬត្រឹមប្រវែងពីរធ្នាប់បើទុកអោយលើសពីនេះនឹងត្រូវអាបត្តិទុក្កដ) ៧-បំពង់ម្ជុលសំភារៈសំរាប់ដាក់ម្ជុល និងអំបោះដេរប៉ះសំលៀកបំពាក់ផ្ទាល់ខ្លួន ៨-តំរងទឹកប្រដាប់ត្រងទឹក ការពារមិនអោយដោយសត្វមានជីវិតឬកករសំរាមចូលក្នុងទឹកដែលត្រូវយកមកប្រើប្រាស់ ។

ដើម្បីរក្សាបរិក្ខារទាំងប៉ុន្មានអោយមានសណ្តាប់ធ្នាប់ ពិសេសត្រៃចីវរមិនអោយរយីករយាក និងមានបរិមណ្ឌលត្រឹមត្រូវនៅពេលធ្វើសង្ឃកម្មចាំបាច់ត្រូវប្រើបរិក្ខារមួយផ្សេងទៀតគឺ "វត្ថពន្ធទ្រូង" ដែលមានបណ្តោយប្រវែង ៥ហត្ថទទឹង ប្រមាណ០,៨០ម មកចងក្រវាត់ត្រឹមដើមទ្រូង ។ ត្រង់នេះហើយហៅថា "ដើមទ្រូង ៥ហត្ថ" ជាន័យត្រង់ៗ ព្រោះសម័យបុរាណ មិនមានសាលារៀនក្រៅពីវត្តអារាម និងក្នុងព្រះបរមរាជវាំងទេ ។ អ្នកបួស គឺអ្នកស្រលាញ់ការសិក្សា(សិក្ខាកាមកុលបុត្រ) ។ អ្នកបួសចាកផ្នួសមកងាយស្រួលរកភរិយា ព្រោះប្រជាជនយើងរាប់អាន និងត្រូវការអ្នកចេះ អ្នកមានចរិយា មារយាទបានអប់រំហើយ ។ អ្នកសឹកពីបួស ប្រជាជននិយមហៅថា អន្ទិត(បណ្ឌិត) មានន័យថាអ្នកយល់ដឹងការណ៍វាក់ជ្រៅ អ្នកមានកាយវាចាចិត្តបានអប់រំល្អហើយខុសពី "បណ្ឌិត" សម័យបច្ចុប្បន្ន ដែលមានកំរិតថ្នាក់សិក្សា និងជាសញ្ញាប័ត្រមានកំរិតខ្ពស់បំផុតតាមមុខវិជ្ជា ឬតាមផ្នែក ។

- មនុស្សប្រុសដែលពេញជាប្រុសពិតប្រាកដ ត្រូវមានអង្គលក្ខណៈ ៥យ៉ាងគឺ :
  - ១- វិជ្ជាសម្បត្តិបរិបូណ៌ដោយចំណេះដឹង ចំណេះធ្វើ យ៉ាងហោចណាស់ក៏ត្រូវមានមុខវិជ្ជាជីវៈណាមួយសំរាប់រស់ដែរ (សម្មាអាជីវោ)
  - ២- ចរិយាសម្បត្តិបរិបូណ៌ដោយចរិយាធម៌ សីលធម៌ល្អដែលសង្គមរាប់រក
  - ៣- ភាពជាទីសង្ឃឹមកក់ក្តៅនៃមាតាបិតាមិនធ្វើអោយមាតាបិតាមានទុក្ខលំបាក មានវិប្បដិសារៈ
  - ៤- ភាពជាស្វាមីដ៏ល្អរបស់នារីណាមួយ
  - ៥- ស្នេហាមាតុភូមិ ស្រលាញ់ទឹកដីព្រៃព្រឹក្សា ស្រុកកំណើតប្រទេសរបស់ខ្លួន ។

ប្រកបដោយអង្គលក្ខណៈ ៥យ៉ាងនេះ ដូចរៀបរាប់ខាងលើ ទើបពេញជាមនុស្សប្រុសមាន "ដើមទ្រូង៥ហត្ថ" ។

លោក : អ៊ុយ ស្វន នាយក ប.ឋ.ស ព្រែកកំពិស ខេត្តកណ្តាល




# តើអ្នកគ្រូ លោកគ្រូដឹងទេថា...

## អំពីសត្វ និងរុក្ខជាតិសំរាប់ជានិមិត្តសញ្ញានៃព្រះរាជាណាចក្រកម្ពុជា

យោងសេចក្ដីប្រកាសពតិមានលេខ៣១០ សប្រក ស្ដីពីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី បានបង្ហាញថា: ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៥ វេលាម៉ោង ៨:៣០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លង :

១- **សេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពីការជ្រើសរើសសត្វ និងរុក្ខជាតិសំរាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា**

២- ..........................................................................................

៣- ..........................................................................................

ក្រោយពីបានពិភាក្សា និងផ្លាស់ប្ដូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តសំរេច :

### I. សេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពីការជ្រើសរើសសត្វ និងរុក្ខជាតិ សំរាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

សេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពីការជ្រើសរើសសត្វ និងរុក្ខជាតិសំរាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា រៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានអង្គប្រជុំគណៈរដ្ឋមន្ត្រីឯកភាព កំណត់យកសត្វ និងរុក្ខជាតិសំរាប់ធ្វើជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា មានឈ្មោះទៅតាមប្រភេទដូចខាងក្រោម :

១- ប្រភេទសត្វចតុប្បាទ : សត្វគោព្រៃ

២- ប្រភេទបក្សី : សត្វត្រយ៉ង

៣- ប្រភេទឧរង្គសត្វ : អណ្ដើកសរសៃ (អណ្ដើកហ្លួង)

៤- ប្រភេទមច្ឆា : ត្រីគល់រាំង

៥- ប្រភេទរុក្ខជាតិ : ដើមត្នោត

៦- ប្រភេទផ្កា : ផ្ការំដួល

៧- ប្រភេទផ្លែឈើ : ផ្លែចេកពងមាន់ ។

# ចំនួនសាលារៀនតាមឃុំ-សង្កាត់ (ឆ្នាំសិក្សា ២០០៣-០៤)

នៅឆ្នាំសិក្សា ២០០៣-០៤ សាលារៀនសរុបមាន ៧៩៩៩ ដែលចែកជាសាលាមត្តេយ្យសិក្សាចំនួន ១២៣៨ (សាលាមត្តេយ្យក្នុងបឋមសិក្សាចំនួន ១១០៩) សាលាបឋមសិក្សា ៦០៦៣ (សាលាឧបសម្ព័ន្ធ ១០៩៩) អនុវិទ្យាល័យ ៤៨៦ និងវិទ្យាល័យ ២១២ ។ សាលារៀនទាំងអស់នេះស្ថិតក្នុងភូមិចំនួន ៦១៨៦ របស់ឃុំ/សង្កាត់ចំនួន ១៦០៧ ក្នុងស្រុកខ័ណ្ឌទាំង ១៨៥ នៃ ២៤ ខេត្ត/ក្រុង ។ ចំនួនភូមិសរុបទូទាំងប្រទេសមាន ១៣ ៦៥៤ និងឃុំ-សង្កាត់សរុប ១៦២១ ។

**តារាងទី ១ : ចំនួនឃុំ-សង្កាត់មានសាលារៀនតាមកំរិតសិក្សា**

| ចំនួន | ឃុំ-សង្កាត់ | ឃុំ-សង្កាត់មានសាលារៀន | | | |
|---|---|---|---|---|---|
| | | មត្តេយ្យ | បឋមសិក្សា | អនុវិទ្យាល័យ | វិទ្យាល័យ |
| សរុប | ១៦២១ | ៧២២ | ១៦០៤ | ៤៧១ | ២០៦ |

ក្នុងឃុំ-សង្កាត់សរុបចំនួន ១៦២១ មានឃុំ-សង្កាត់ចំនួន ១៤ ដែលពុំមានសាលារៀនសោះ គឺមាននៅខេត្តកណ្ដាលក្នុងស្រុកតាខ្មៅ ឃុំតាក្ដុល ក្រុងភ្នំពេញ ក្នុងខ័ណ្ឌចំនួនបី មានសង្កាត់ចំនួន ១០ និងខេត្តរតនគិរី ក្នុងស្រុកអូរយ៉ាដាវ មានឃុំចំនួន ២ ។

**តារាងទី ២ : ឃុំ-សង្កាត់ពុំមានសាលារៀនសោះ**

| ល.រ | ឈ្មោះឃុំ-សង្កាត់ | ស្រុក-ខ័ណ្ឌ | ខេត្ត/ក្រុង | ល.រ | ឈ្មោះឃុំ-សង្កាត់ | ស្រុក-ខ័ណ្ឌ | ខេត្ត/ក្រុង |
|---|---|---|---|---|---|---|---|
| ១ | តាក្ដុល | តាខ្មៅ | កណ្ដាល | ៨ | ផ្សារថ្មី១ | ដូនពេញ | ភ្នំពេញ |
| ២ | អូរឬស្សី ១ | ប្រាំពីរមករា | ភ្នំពេញ | ៩ | ផ្សារថ្មី២ | ដូនពេញ | ភ្នំពេញ |
| ៣ | អូរឬស្សី ២ | ប្រាំពីរមករា | ភ្នំពេញ | ១០ | ផ្សារកណ្ដាល១ | ដូនពេញ | ភ្នំពេញ |
| ៤ | អូរឬស្សី ៣ | ប្រាំពីរមករា | ភ្នំពេញ | ១១ | ផ្សារដេប៉ូ ២ | ទួលគោក | ភ្នំពេញ |
| ៥ | អូរឬស្សី ៤ | ប្រាំពីរមករា | ភ្នំពេញ | ១២ | ផ្សារដេប៉ូ ៣ | ទួលគោក | ភ្នំពេញ |
| ៦ | មនោរម្យ ២ | ប្រាំពីរមករា | ភ្នំពេញ | ១៣ | បរខាំ | អូរយ៉ាដាវ | រតនគិរី |
| ៧ | ផ្សារចាស់ | ដូនពេញ | ភ្នំពេញ | ១៤ | សេសាន | អូរយ៉ាដាវ | រតនគិរី |

នៅទូទាំងប្រទេសមានសាលាមធ្យមសិក្សាចំនួន ៦៧៧ ដែលច្រើនប្រមូលផ្ដុំក្នុងទីប្រជុំជនធំៗ នៅក្នុងទីក្រុង ទីរួមខេត្ត និងទីរួមស្រុក ។ ក្នុងចំណោមស្រុកខ័ណ្ឌទាំង ១៨៥ នៅមានស្រុកចំនួន ១២ ក្នុងខេត្តចំនួន ៤ មិនទាន់មានអនុវិទ្យាល័យ រឺវិទ្យាល័យ ។

១- ខេត្តកោះកុង : ស្រុកថ្មបាំង (ចំនួន ១ស្រុក)

២- ខេត្តមណ្ឌលគិរី : ស្រុកអូររាំង ស្រុកពេជ្រាដា (ចំនួន ២ស្រុក)

៣- ខេត្តរតនគិរី : ស្រុកអណ្ដូងមាស ស្រុកកូនមុំ ស្រុកលំផាត់ ស្រុកអូរជុំ ស្រុកអូរយ៉ាដាវ ស្រុកតាវែង និងស្រុកវ៉ឺនសៃ (ចំនួន ៧ស្រុក)

៤- ខេត្តសៀមរាប : ស្រុកស្វាយលើ និងស្រុកវ៉ារិន (ចំនួន ២ស្រុក)

ដូចនេះ ក្នុងចំណោមស្រុក-ខ័ណ្ឌ ចំនួន ១៨៥ :

- ស្រុក-ខ័ណ្ឌ ចំនួន ១២៧ មានទាំងអនុវិទ្យាល័យ និងវិទ្យាល័យ
- ស្រុក-ខ័ណ្ឌ ចំនួន ៦ ពុំមានអនុវិទ្យាល័យ
- ស្រុក-ខ័ណ្ឌ ចំនួន ៤០ ពុំមានវិទ្យាល័យ
- ស្រុក-ខ័ណ្ឌ ចំនួន ១២ ពុំមានទាំងអនុវិទ្យាល័យ និងវិទ្យាល័យ ។

ក្នុងចំណោមឃុំ-សង្កាត់ចំនួន ១៦២១ មាន ១៤ ឃុំ-សង្កាត់ពុំមានសាលារៀនសោះ ។

ក្នុងចំណោមឃុំ-សង្កាត់ចំនួន ១៦០៧ ដែលមានសាលារៀន :

- ៧២២ ឃុំ-សង្កាត់មានសាលាមត្តេយ្យសិក្សា
- ១៦០៤ ឃុំ-សង្កាត់មានសាលាបឋមសិក្សា
- ៤៧១ ឃុំ-សង្កាត់មានអនុវិទ្យាល័យ
- ២០៦ ឃុំ-សង្កាត់មានវិទ្យាល័យ ។

កាលពីឆ្នាំសិក្សា ២០០១-០២ មានស្រុកខ័ណ្ឌចំនួន ២៦ របស់ខេត្តក្រុងចំនួន ១០ ដែលមិនទាន់មានសាលាមធ្យមសិក្សា ។ តែដើម្បីជំរុញអោយកុមារយើងបានរៀនចប់ការអប់រំមូលដ្ឋានចំនួន ៩ឆ្នាំ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយនៅឆ្នាំសិក្សា ២០០៣-០៤ អនុវិទ្យាល័យថ្មីយ៉ាងច្រើនចំនួន ១០៣ បានកើតឡើងដែលធ្វើអោយស្រុកមិនមានសាលាមធ្យមសិក្សា បានថយមកនៅត្រឹម ១២ ស្រុក ។ ការកើនឡើងនៃអនុវិទ្យាល័យបាននឹងកំពុងចូលរួមចំណែកក្នុងការសំរេចនូវគោលនយោបាយអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា "ធ្វើសកលកម្មការអប់រំមូលដ្ឋានចំនួន ៩ឆ្នាំ" ។

លោកស្រី ឌួយ ផល្លា

កា.រិ. ប្រព័ន្ធពត៌មានគ្រប់គ្រងអប់រំ

នាយកដ្ឋានផែនការ

ទំនិតាស្ដៃ

# រឿង : លោកម៉ូយូទៅជួបគ្រូពេទ្យ

ឃួរ ស៊ី

- "តើលោកប្រកបការងារអីដែរ ?" លោកគ្រូពេទ្យសួរ

\+ "ខ្ញុំជាកសិករ" លោកម៉ូយូឆ្លើយ

- "តើលោកមានកូនទេ ?" លោកគ្រូពេទ្យសួរ

\+ លោកម៉ូយូក៏ឆ្លើយថា "ព្រះជាម្ចាស់មិនល្អចំពោះខ្ញុំសោះ ! ក្នុងចំណោមកូនកើតមក ១៥នាក់ មានតែ ៩នាក់ប៉ុណ្ណោះដែលនៅសល់" ។

- "តើប្រពន្ធលោកធ្វើការងារទេ ?"

\+ "ទេ ! នាងនៅផ្ទះ "

- "អូហ៍ ខ្ញុំយល់ហើយ ! តើប្រពន្ធលោកចំណាយពេលវេលាមួយថ្ងៃៗរបស់នាងបែបណាទៅ ?

\+ "បាទ ! នាងក្រោកម៉ោង ៤ភ្លឺទៅដងទឹក រកអុស បង្កាត់ភ្លើងចំអិនអាហារពេលព្រឹក និងបោសសំអាតផ្ទះ ។ បន្ទាប់មក នាងធ្វើដំណើរទៅកាន់ទន្លេដើម្បីបោកខោអាវ ។ រៀងរាល់មួយអាទិត្យម្តង នាងដើរទៅកិនម្សៅ ។ បន្ទាប់មកទៀត នាងទៅទីប្រជុំជនជាមួយកូនតូចៗជាងគេ ២នាក់ ដែលនៅទីនោះ នាងលក់ប៉េងប៉ោះក្បែរផ្លូវបណ្ដើរ ចាក់អាវបណ្ដើរ ។ នាងទិញត្រីដែលនាងត្រូវការពីហាង ។ ក្រោយមកទៀត នាងចំអិនអាហារថ្ងៃត្រង់ ។

- "តើលោកត្រលប់មកផ្ទះវិញទេនៅពេលថ្ងៃត្រង់ ?"

\+ "ទេ ! នាងយកអាហារមកអោយខ្ញុំដែលនៅចម្ងាយប្រហែល ៣គីឡូម៉ែត្រពីផ្ទះ"

- "ហើយចុះបន្ទាប់មកទៀត ?"

\+ "នាងទៅស្រែ ជំរះស្មៅ និងបន្ទាប់មកទៅស្រោចទឹកនៅសួនបន្លែ"

- "ចុះលោកធ្វើអ្វីដែរ ?"
+ "ខ្ញុំត្រូវទៅពិភាក្សារឿងមុខជំនួញ និងផឹកជាមួយប្រុស១ក្នុងភូមិ"

- "ចុះក្រោយមកទៀត ?"
+ "ខ្ញុំទៅផ្ទះដើម្បីញ៉ាំអាហារពេលយប់ដែលចំអិនដោយប្រពន្ធខ្ញុំ"

- "តើប្រពន្ធលោកចូលដំណេកវិញទេបន្ទាប់ពីអាហារពេលយប់រួច ?"
+ "ទេ ! នាងមិនទាន់ទៅទេ ! តែខ្ញុំទៅ ! នាងនៅមានអ្វីត្រូវធ្វើនៅជុំវិញផ្ទះទៀតរហូតដល់ម៉ោង ៩ រឺម៉ោង ១០"

- "ប៉ុន្តែខ្ញុំគិតថា មុននេះលោកបាននិយាយថា ប្រពន្ធលោកមិនធ្វើការទេនោះអី ?"
+ "ប្រាកដហើយ នាងមិនធ្វើការងារអីទេ ។ ខ្ញុំបានប្រាប់លោកគ្រូពេទ្យហើយថា នាងនៅផ្ទះប៉ុណ្ណោះ ។"

## ការភុឃកដ៏ធំមួយ



សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការនាយក
លេខ : ០១ គ.ក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនដំណឹងមរណភាព

តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការនាយកនៃ ស.ប.ស.ខ
សូមសំដែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបំរើការ | ថ្ងៃ.ខែ.ឆ្នាំ មរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ក. មរណៈភាពសមាជិក | | | | | | | | | |
| ១ | ឡេង សៅ | ៧១ | ប | គ្រូ ប.ឋ.ស | និវត្តជន ប.ឋ.ស ចុងកោះ ស្រុកស្អាង ខេត្តកណ្តាល | ១០-១០-០៤ | រោគាពាធ | ៦៣៩៨ កណ | សពទី៤០៧៥ |
| ២ | ជុំ មុនីសុខាន់ | ៤៩ | ប | គ្រូ ម.ប.ភ | វិ.ស្អាង ស្រុកស្អាង ខេត្តកណ្តាល | ១១-១០-០៤ | រោគាពាធ | ៥៤៧៨ កណ | - ៤០៧៦ |
| ៣ | សៅ វុន | ៥១ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស ពាមស្លា ស្រុកពញាឮ ខេត្តកណ្តាល | ០៣-១០-០៤ | លើសឈាម | ១៦២០ កណ | - ៤០៧៧ |
| ៤ | ទិត តេង | ៥៤ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស ពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្តាល | ១៧-១០-០៤ | ខ្យល់គរ | ២៦៤៧ កណ | - ៤០៧៨ |
| ៥ | ចាន់ ស៊ុំ | ៥៤ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស ពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្តាល | ២២-១០-០៤ | ជំងឺក្រពះ | ២៦៥០ កណ | - ៤០៧៩ |
| ៦ | កែវ ស៊ីខុន | ៥៦ | ស | គ្រូ ប.ឋ.ស | ប.ឋ.ស គគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល | ១៥-១០-០៤ | រោគាពាធ | ៧៣២២កណ | - ៤០៨០ |
| ៧ | ស្រី មិថុនា | ៣៦ | ប | គ្រូ ម.ប.ភ | មន្ទីរ អ.យ.ក ខេត្តសៀមរាប | ២០-១១-០៤ | គ្រោះថ្នាក់ចរាចរ | ១៣៤ សរ | - ៤០៨១ |
| ៨ | សេក សុទីន | ៣០ | ស | គ្រូ ប.ឋ.ស | ប.ឋ.ស ស្វាយជ័យ ស្រុកប្រាសាទបាគង-សៀមរាប | ០៥-១១-០៤ | រោគាពាធ | ១៦៣៤ សរ | - ៤០៨២ |
| ៩ | មុំ សារ៉េម | ៣៧ | ស | គ្រូ ប.ឋ.ស | ប.ឋ.ស សន្ទាយ ស្រុកបាភ្នំ ខេត្តព្រៃវែង | ២៤-១០-០៤ | រោគាពាធ | ៤៧៧៦ ពវ | - ៤០៨៣ |
| ១០ | យឹម សំអាង | ៦៣ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាកោះជ្រៃ ស្រុកបាភ្នំ ខេត្តព្រៃវែង | ០៨-១១-០៤ | រោគាពាធ | ៤៧១១ ពវ | - ៤០៨៤ |
| ១១ | អ៊ឹង ឆន | ៦១ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលានាគរង្សី ស្រុកបាភ្នំ ខេត្តព្រៃវែង | ០៩-១១-០៤ | រោគាពាធ | ៤៣៦១ ពវ | - ៤០៨៥ |
| ១២ | ខៀន សិត | ៧៣ | ប | គ្រូ ម.ប.ភ | និវត្តជន អនុ.អ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង | ១០-១០-០៤ | រោគាពាធ | ៥៣៦១ ពវ | - ៤០៨៦ |
| ១៣ | សួង សុខា | ៣១ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស កំព្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង | ១៧-១១-០៤ | ឈឺក្រពះ | ៣១០១ ពវ | - ៤០៨៧ |
| ១៤ | អ៊ិន សយ | ៥៦ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស បឹងខ្សាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង | ០៣-១២-០៤ | រោគាពាធ | ៤៨០០ ពវ | - ៤០៨៨ |
| ១៥ | មុជ សំ | ៥៩ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស បឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង | ១១-១២-០៤ | រោគាពាធ | ៤៦៤៧ ពវ | - ៤០៨៩ |
| ១៦ | ឡុច ចន្ថា | ៤២ | ប | គ្រូ ម.ប.ភ | វិ.ពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង | ១៧-១១-០៤ | រោគាពាធ | ៤៨១៨ ពវ | - ៤០៩០ |
| ១៧ | សួន សុផល | ៥០ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស បារាយណ៍ ស្រុកកំពង់លាវ ខេត្តព្រៃវែង | ០៣-១២-០៤ | រោគាពាធ | ៥២៩៤ ពវ | - ៤០៩១ |
| ១៨ | គីម រឿន | ៥៤ | ប | គ្រូ ម.ទ.ភ | សាលាបំពេញវិជ្ជាពាក់កណ្តាលរៀបរយ ខេត្តកំពង់ឆ្នាំង | ០៦-០៦-០៤ | រោគាពាធ | ១៣០ កឆ | - ៤០៩២ |
| ១៩ | អ៊ិន សិន | ៦៥ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាត្រពាំងថ្ម-សាមគ្គីមានជ័យ-កំពង់ឆ្នាំង | ២១-០៥-០៤ | រោគាពាធ | ៦៦៤ កឆ | - ៤០៩៣ |
| ២០ | ជូ ស្រេង | ៦៤ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាតំរូក្រុង-កំពង់ឆ្នាំង-កំពង់ឆ្នាំង | ១៨-០៦-០៤ | រោគាពាធ | ១៣៥៨ កឆ | - ៤០៩៤ |
| ២១ | ខៀវ ជួប | ៥៦ | ប | គ្រូ ប.ឋ.ស | ប.ឋ.សសាលាលេខ៥ ស្រុកកំពង់ត្រឡាច-កំពង់ឆ្នាំង | ២៦-០៥-០៤ | រោគាពាធ | ៩០៧ កឆ | - ៤០៩៥ |
| ២២ | ជា គី | ៣៥ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស ស្នៃគ្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ២៥-០៧-០៤ | ផ្ទុះបាក់សង្កត់ | ១៨២៥ កឆ | - ៤០៩៦ |
| ២៣ | លាស់ ញ៉ិប | ៦៤ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាគរុកោសល្យ និងវិក្រឹតការ-កំពង់ឆ្នាំង | ២១-០៧-០៤ | រោគាពាធ | ១៥៧ កឆ | - ៤០៩៧ |
| ២៤ | ចាន់ មុន្នី | ៣៤ | ស | គ្រូមត្តេយ្យ | សាលាទួលខ្សាច់ ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង | ០៩-១០-០៤ | រលាកខួរក្បាល | ២៣៧៥ កឆ | - ៤០៩៨ |
| ២៥ | ប៉ែន សារិន | ៥៩ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស ច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | ១៨-០៩-០៤ | រោគាពាធ | ១០៧៤ កឆ | - ៤០៩៩ |
| ២៦ | សូ ម៉ប់ | ៦១ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាថ្នល់តាសែង-រលាប្អៀរ-កំពង់ឆ្នាំង | ០៨-០៩-០៤ | រោគាពាធ | ១៦៨៣ កឆ | - ៤១០០ |
| ២៧ | វឺន សុវណ្ណ | ៤៥ | ស | គ្រូ ប.ឋ.ស | ការិ.អ.យ.ក ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង | ០៨-១០-០៤ | លង់ទឹក | ១៤៥២ កឆ | - ៤១០១ |
| ២៨ | ពៅ ចិន | ៥១ | ប | គ្រូ ប.ឋ.ស | ប.ឋ.សសំបួរមាស-រលាប្អៀរ-កំពង់ឆ្នាំង | ២១-០៩-០៤ | មាច់ទឹក | ២៤៣១ កឆ | - ៤១០២ |
| ២៩ | ជា សុខនី | ៣៦ | ប | គ្រូ ប.ឋ.ស | ការិ.អ.យ.ក ស្រុកតំបែរ ខេត្តកំពង់ចាម | ១៨-១១-០៤ | គ្រោះថ្នាក់ចរាចរ | ៦០៦៧ កច | - ៤១០៣ |
| ៣០ | ថាច់ ឃឿង | ៤០ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស ខ្នងក្រពើ-ចំការកៅស៊ូមេមត់ ខេត្តកំពង់ចាម | ១៧-១១-០៤ | គ្រោះថ្នាក់ចរាចរ | ១១៩៣១កច | - ៤១០៤ |
| ៣១ | ស៊ាម វិបុល | ២៦ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស កន្ត្រើយចំការកៅស៊ូមេមត់ ខេត្តកំពង់ចាម | ២៤-១១-០៤ | អេដស៍ | ៩៩៤៤ កច | - ៤១០៥ |
| ៣២ | លី ចាន់ | ៥៩ | ប | គ្រូ ម.ប.ភ | ការិ.អ.យ.ក ស្រុកមេមត់ ខេត្តកំពង់ចាម | ១៦-១១-០៤ | រោគាពាធ | ៥០០ កច | - ៤១០៦ |
| ៣៣ | ហ៊ាន សំអូន | ៣១ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស វាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម | ១០-១១-០៤ | រោគាពាធ | ១១០៧៧កច | - ៤១០៧ |
| ៣៤ | នាង សុខុម | ៥៣ | ប | គ្រូ ប.ឋ.ស | ការិ.អ.យ.ក ស្រុកចំការលើ ខេត្តកំពង់ចាម | ១៨-១១-០៤ | រោគាពាធ | ៥៥៤៩ កច | - ៤១០៨ |
| ៣៥ | ទឹក ហុន | ៥៨ | ប | គ្រូ ម.ប.ភ | និវត្តជន អនុ.ទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ | ០៨-១០-០៤ | គ្រោះថ្នាក់ចរាចរ | ១៩៥៦ កច | - ៤១០៩ |
| ៣៦ | គីម មិន | ៥៨ | ប | គ្រូ ប.ឋ.ស | និវត្តជន សាលារកាជួរ ស្រុកសណ្តាន់ ខេត្តកំពង់ធំ | ១១-១០-០៤ | រោគាពាធ | ២៧៩៧ កច | - ៤១១០ |
| ៣៧ | ខៀវ ដេត | ៥៨ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស អ្នករវាំង ស្រុកបារាយណ៍ ខេត្តកំពង់ធំ | ២០-១០-០៤ | រោគាពាធ | ១១៣៣កច | - ៤១១១ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣៨ | រឹម សុផានី | ៣០ | ស | គ្រូ ប.ឋ.ស | ប.ឋ.ស បឹងខាងជើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ | ១៨-១១-០៤ | តាំងបេះដូង | ៣០០៥ កធ | - ៤១១២ |
| ៣៩ | ឈើរ ប៊ុន ហេង | ៦២ | ប | គ្រូ ម.ទ.ភ | និវត្តជន អនុ.ទួលស្វាយព្រៃ រាជធានីភ្នំពេញ | ៣០-១១-០៤ | ជំងឺថ្លើម | ៥៧៥៧ ភព | - ៤១១៣ |
| ៤០ | អ៊ិន ចាន់អេង | ៣៥ | ស | គ្រូមត្តេយ្យ | សាលាបឋមសិក្សាអនុវត្ត រាជធានីភ្នំពេញ | ១៨-១១-០៤ | ជំងឺសួតនិងថ្លើម | ២៥៧២ ភព | - ៤១១៤ |
| ៤១ | អ៊ុន ធឹម | ៥៨ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស ត្រពាំងឡើយ ស្រុកជងទង់ ខេត្តកំពត | ០៣-១២-០៤ | រោគាពាធ | ២៦០១ កព | - ៤១១៥ |
| ៤២ | ញ៉ុញ សារុន | ៥៥ | ប | គ្រូ ប.ឋ.ស | ប.ឋ.ស ស្ពាន ស្រុកថ្មគោល ខេត្តបាត់ដំបង | ១០-១០-០៤ | លង់ទឹក | ១៧៣៥ បប | - ៤១១៦ |
| ៤៣ | តឹម សៀ | ៦៧ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាខ្នាចរមាស ស្រុកបវេល-បាត់ដំបង | ០៣-១១-០៤ | របេង | ២៩៩៣ បប | - ៤១១៧ |
| ៤៤ | ម៉េង សារឿន | ៤៤ | ប | កម្មករ | វិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបង | ០៥-១១-០៤ | រោគាពាធ | ២៧២៥ បប | - ៤១១៨ |
| ៤៥ | ឃុត ផាន់ | ៧៤ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកបាត់ដំបង ខេត្តបាត់ដំបង | ០៩-១១-០៤ | រោគាពាធ | ២៨៣៣ បប | - ៤១១៩ |
| ៤៦ | ហួត ភិន់ថេម | ៧១ | ស | គ្រូ ប.ឋ.ស | និវត្តជនស្រុកបាត់ដំបង ខេត្តបាត់ដំបង | ០៩-១២-០៤ | រោគាពាធ | ៥០៩៧ បប | - ៤១២០ |
| ៤៧ | សៅ សាគួ | ៥៩ | ស | គ្រូ ប.ឋ.ស | ប.ឋ.សវត្តលៀប ស្រុកបាត់ដំបង-បាត់ដំបង | ១០-១២-០៤ | តាំងបេះដូង | ៥០៣ បប | - ៤១២១ |
| ៤៨ | អ៊ិន សៅឡេង | ៣០ | ប | គ្រូ ម.ទ.ភ | វិទ្យាល័យពោធិសាត់ ខេត្តពោធិសាត់ | ០៨-១០-០៤ | ធ្លាក់ពីលើផ្ទះ | ២៥៣៤ ពស | - ៤១២២ |
| ៤៩ | អ៊ុក បាន | ៥១ | ប | គ្រូ ប.ឋ.ស | សាលាស្នាមព្រះ ស្រុកបាកាន ខេត្តពោធិសាត់ | ១៥-១០-០៤ | រោគាពាធ | ១៨៥៥ ពស | - ៤១២៣ |
| ៥០ | ម៉េង វិន | ៦៥ | ប | គ្រូ ប.ឋ.ស | និវត្តជន ក្រោមការគ្រប់គ្រងគណៈកម្មាធិការនាយក | ១៧-១០-០៤ | រោគាពាធ | ២០៥៦ តក | - ៤១២៤ |
| ៥១ | ថ្វាង គួរ | ៦១ | ប | គ្រូ ម.ប.ភ | និវត្តជន ក្រោមការគ្រប់គ្រងគណៈកម្មាធិការនាយក | ១៣-១១-០៤ | ឈើសណ្ឋាម | ៦១៤ តក | - ៤១២៥ |

ខ. មរណភាពគ្រួសារសមាជិក

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | មុខរបរ | អត្តសញ្ញាណទំនាក់ទំនងរបស់សមាជិក | ថ្ងៃ.ខែ.ឆ្នាំ មរណៈ | មូលហេតុ | លេខចំណូល | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ១ | មុំ ណយ | ៥៥ | ស | កសិករ | ប្រពន្ធលោក តាន់ ឡាយ សាលាព្រែកតាកូវ-ខ្សាច់កណ្ដាល-កណ្ដាល | ១៧-១០-០៤ | មាត់ទឹក | ៣៤៤៤ កណ | - ២៦៣៦ |
| ២ | យូ ស | ៦៥ | ប | កសិករ | ប្ដីអ.ស សួស សុភាព សាលាជោរ ស្រុកកំចាយមារ ខេត្តព្រៃវែង | ០៧-១០-០៤ | ខ្យល់គរ | ២៤៥៨ ពវ | - ២៦៣៧ |
| ៣ | អ៊ិង រ៉េន | ៥៧ | ស | កសិករ | ប្រពន្ធលោក គុយ លន់ សាលាត្រោក ស្រុកបាភ្នំ ខេត្តព្រៃវែង | ០៥-១២-០៤ | រោគាពាធ | ៤២៩១ ពវ | - ២៦៣៨ |
| ៤ | ចេង សាភិន់ | ៥០ | ស | កសិករ | ប្រពន្ធលោក ប៊ិន សុផាត សាលាមាសជុំ ស្រុកបរិបូណ៌-កំពង់ឆ្នាំង | ១២-០៦-០៤ | គ្រោះថ្នាក់ចរាចរ | ២១៧៨ កឆ | - ២៦៣៩ |
| ៥ | ឱ សឿន | ៥០ | ប | ខ.ម | ប្ដីអ.ស នន ម៉ៅរី សាលាគុំក្រុង ខេត្តកំពង់ឆ្នាំង | ២០-១១-០៤ | ជំងឺសួត | ១២៦៣ កឆ | - ២៦៤០ |
| ៦ | ជា ស៊ីន | ៣០ | ស | កសិករ | ប្រពន្ធលោក សយ ប៊ុនសឿន សាលាមេព្រីង ស្រុកចំការ-កំពង់ចាម | ០៩-១១-០៤ | ជំងឺថ្លើម | ៥៤០៥ កច | ២៦៤១ |
| ៧ | ច្រឹក ភិន់ | ៤៨ | ប | កសិករ | ប្ដីអ.ស ហ៊ាប សាមឿន សាលាខ្នងក្រពើចំការកៅស៊ូ-កំពង់ចាម | ១០-១១-០៤ | ទឹកចូលសួត | ៤០១ កច | - ២៦៤២ |
| ៨ | រឹម សុផានី | ៣០ | ស | គ្រូបង្រៀន | ប្រពន្ធលោក អ៊ិន គឹមសុង សាលាបឹងខាងជើង-បារាយណ៍-កំពង់ធំ | ១៨-១១-០៤ | តាំងបេះដូង | ៥៦៥ កធ | - ២៦៤៣ |
| ៩ | ឡេង ស៊ូណាង | ៥៩ | ប | កសិករ | ប្ដីអ.ស ពុធ យ៉ន សាលាអូរឫស្សីកណ្ដាល-សៀមបូក-ស្ទឹងត្រែង | ០៩-០៩-០៤ | រោគាពាធ | ៤០៥ សត | - ២៦៤៤ |
| ១០ | លី ហោ | ៤៤ | ប | ប្រជាជន | ប្ដីអ.ស ជ័យ សុខមៀន សាលាសន្ធរម៉ុក រាជធានីភ្នំពេញ | ១៥-១១-០៤ | ជំងឺថ្លើម | ២៦៧៨ ភព | - ២៦៤៥ |
| ១១ | ហ៊ូវ ធឹម | ៧៤ | ប | ប្រជាជន | ប្ដីអ.ស នួន អ៊ិញ និវត្តជនសាលាចំរើនជាតិ-ឫស្សីកែវ-ភ្នំពេញ | ២០-១១-០៤ | រោគាពាធ | ៣៨៣០ ភព | - ២៦៤៦ |
| ១២ | មាស វ៉ុចអេង | ៦១ | ស | មេផ្ទះ | ប្រពន្ធលោក ទី សារុន អនុ.ទួលស្វាយព្រៃ រាជធានីភ្នំពេញ | ១៤-១១-០៤ | ជំងឺបេះដូង | ៥៧៧៦ ភព | - ២៦៤៧ |
| ១៣ | លឹម ភាព | ៤៧ | ស | មេផ្ទះ | ប្រពន្ធលោក រឿន សាភ៌ ការិ.អ.យ.ក រតនមណ្ឌល-បាត់ដំបង | ២២-១០-០៤ | មហារីកថ្លើម | ១៩២៨ បប | - ២៦៤៨ |
| ១៤ | អ៊ិត កាសៀម | ៦០ | ប | ប្រជាជន | ប្ដីអ.ស សេង ប៊ុនរេត និវត្តជនសាលាគរុកោសល្យ-បាត់ដំបង | ២៤-១០-០៤ | គ្រោះថ្នាក់ចរាចរ | ៨០ បប | - ២៦៤៩ |
| ១៥ | សេង សុផល | ៤៤ | ស | ធ្វើស្រែ | ប្រពន្ធលោក ឈី ប៊ុនថេង សាលាសោមនស្ស ស្រុកឯកភ្នំ-បាត់ដំបង | ០៥-១២-០៤ | រោគាពាធ | ៤៦៩៣ បប | - ២៦៥០ |
| ១៦ | អ៊ឹម សារ៉េត | ៣៤ | ប | ធ្វើស្រែ | ប្ដីអ.សថាំង ផល្លា ស្រុកបាត់ដំបង ខេត្តបាត់ដំបង | ១០-១២-០៤ | រោគាពាធ | ៦២៩៣ បប | - ២៦៥១ |
| ១៧ | រិទ្ធ វណ្ណា | ២០ | ស | ធ្វើស្រែ | ប្រពន្ធលោក មាស ស៊ន ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង | ១៣-១២-០៤ | សំរាលកូន | ៧៨៩៧ បប | - ២៦៥២ |
| ១៨ | ជា ពាកណ្ឌរៈ | ៤៨ | ស | ធ្វើស្រែ | ប្រពន្ធលោក ហ៊ុយ សយ និវត្តជនស្រុកក្រគរ ខេត្តពោធិសាត់ | ៣០-១០-០៤ | រោគាពាធ | ១៥៨៥ ពស | - ២៦៥៣ |

មេត្តាប្រមូលភាគទានឧបត្ថម្ភសពប្រចាំខែ **មករា** ឆ្នាំ ២០០៥ អោយទាន់ពេលវេលា ដើម្បីដោះស្រាយជូនគ្រួសារសព ។

**ចំណាំ:**

ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក.................... ៥១ន x ៣០៛ = ១៥៣០ រៀល

សពគ្រួសារ................................................ ១៨ន x ១៥៛ = ២៧០ រៀល

ភាគទានប្រចាំខែ ........................................................ = ១០០ រៀល

ភាគទានសាងសង់ផ្ទះគ្រូបង្រៀន...................................... = ៣០០ រៀល

**សរុប** = ២២០០រៀល

ភ្នំពេញ, ថ្ងៃទី ០៤ ខែ **មករា** ឆ្នាំ ២០០៥

**ជ.គណៈកម្មាធិការនាយក**

**អគ្គលេខាធិការរង**

**ស្វាយ និត្យ**

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការនាយក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១៥/០៥ គ.ក.

# សេចក្តីជូនដំណឹងមរណភាព

តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការនាយកនៃ ស.ប.ស.ខ
សូមសំដែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបំរើការ | ថ្ងៃ ខែ ឆ្នាំមរណៈ | មូលហេតុ | លេខបណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ក. មរណៈភាពសមាជិក | | | | | | | | | |
| ១ | ម៉ុត ឃន | ៦៤ | ប | គ្រូ ម.ប.ភ | និវត្តជន វិ.ហ.ស មង្គលបុរី ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ | ០៧-១០-០៤ | លើសឈាម | ៦៩៧ បជ | សពទី៤១២៦ |
| ២ | គិម យ៉ុន | ៦៣ | ប | គ្រូ ម.ប.ភ | និវត្តជន សាលាគរុកោសល្យ ខេត្តបន្ទាយមានជ័យ | ០៦-១០-០៤ | ធ្លាក់ឈាម | ២២៣៦បជ | - ៤១២៧ |
| ៣ | លី ពាត់ | ៦៣ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកសំរោង ខេត្តឧត្តរមានជ័យ | ២២-០៩-០៤ | រោគាពាធ | ១១០ ឧជ | - ៤១២៨ |
| ៤ | គង់ ជឿន | ៣០ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង | ១០-១០-០៤ | ចោរប្លន់ម៉ូតូ | ២១០ កក | - ៤១២៩ |
| ៥ | មី ផាត់ | ៦៦ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ០១-១១-០៤ | រោគាពាធ | ២៤៥១ ស្វរ | - ៤១៣០ |
| ៦ | សុក ស៊ាន | ៦២ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ១៤-០៩-០៤ | រោគាពាធ | ២៤១៤ ស្វរ | - ៤១៣១ |
| ៧ | កែវ វណ្ណា | ៣០ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សព្រះសីហនុ ស្រុកស្វាយរៀង ខេត្តស្វាយរៀង | ២០-០៧-០៤ | រោគាពាធ | ៦៩៣ ស្វរ | - ៤១៣២ |
| ៨ | ជឹម ឈុន | ៥១ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាទួលច្រេស ស្រុករំដួល ខេត្តស្វាយរៀង | ១៨-០៩-០៤ | ខ្យល់គរ | ២៨៣៤ស្វរ | - ៤១៣៣ |
| ៩ | ជឹង ឡេង | ៥៧ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សជៀងអំ សេដ្ឋាពងទឹក ស្រុករំដួល ខេត្តស្វាយរៀង | ២២-១១-០៤ | រលាកស្រោមខួរក្បាល | ៣១០៥ស្វរ | - ៤១៣៤ |
| ១០ | ចាប សារុន | ៥៩ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សត្រពាំងកំពឹស ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង | ០៦-០៩-០៤ | លើសឈាម | ២៥១៦ ស្វរ | - ៤១៣៥ |
| ១១ | ឃួន សាគុម | ៥០ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាគគីរសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង | ១២-១១-០៤ | ខ្យល់គរ | ២៣៩៦ស្វរ | - ៤១៣៦ |
| ១២ | ពេជ សុគន្ធា | ៤៨ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស៧មករាបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ២០-១១-០៤ | ខ្យល់គរ | ១៨៣៣ស្វរ | - ៤១៣៧ |
| ១៣ | ជា សុភាព | ៥៣ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាបាក្រូង ស្រុករំដួល ខេត្តស្វាយរៀង | ០៤-១២-០៤ | ខ្យល់គរ | ២៩១៥ ស្វរ | - ៤១៣៨ |
| ១៤ | រាជ សៅ | ៥៣ | ប | គ្រូ ម.ប.ភ | វិទ្យាល័យ ហ.ស ប្រសូតិ ស្រុកស្វាយទាប ខេត្តស្វាយរៀង | ០៦-១១-០៤ | ខ្យល់គរ | ២៣៦៥ ស្វរ | - ៤១៣៩ |
| ១៥ | គង់ សារិន | ៤៨ | ប | គ្រូ ម.ប.ភ | សាលាបឋមសិក្សាឈូកស ស្រុកសំរោង ខេត្តតាកែវ | ១៩-១១-០៤ | លើសឈាម | ៣៤៦៥ តក | - ៤១៤០ |
| ១៦ | ឡូច ម៉ុន | ៥៣ | ប | គ្រូ ម.ប.ភ | វិទ្យាល័យអង្គប្រិយ៍ ស្រុកសំរោង ខេត្តតាកែវ | ៣០-១១-០៤ | រោគាពាធ | ៣២០៤ តក | - ៤១៤១ |
| ១៧ | ម៉ែត ម៉ៃម | ៧៤ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកទ្រាំង ខេត្តតាកែវ | ២៤-១២-០៤ | គ្រុនចាញ់ | ២០០២ តក | - ៤១៤២ |
| ១៨ | ម៉ែត លឹម | ៥៥ | ប | គ្រូ ប.ឋ.ស | ការិ.អ.យ.ក ស្រុកត្រាំកក់ ខេត្តតាកែវ | ១៧-១២-០៤ | លើសឈាម | ២៧៧៦ តក | - ៤១៤៣ |
| ១៩ | សរ ជួន | ៥៧ | ប | គ្រូ ប.ឋ.ស | អនុ.សំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល | ១៣-១១-០៤ | រោគាពាធ | ៦៨០៨កណ | - ៤១៤៤ |
| ២០ | គៀន គុន | ៥៦ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល | ២០-១១-០៤ | គ្រោះថ្នាក់ចរាចរ | ៦៣២៧កណ | - ៤១៤៥ |
| ២១ | អ៊ិន សារុន | ២៩ | ប | គ្រូ ម.ប.ភ | អនុវិទ្យាល័យខ្ពប ស្រុកស្អាង ខេត្តកណ្តាល | ២៩-១១-០៤ | រោគាពាធ | ៥៦៨២កណ | - ៤១៤៦ |
| ២២ | សាយ ទូន | ៣៦ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាទួលសាលា ស្រុកអង្គស្នួល ខេត្តកណ្តាល | ១៤-១១-០៤ | រោគាពាធ | ៤៩០៨កណ | - ៤១៤៧ |
| ២៣ | យ៉ាំ សំអឿន | ៣៨ | ប | គ្រូ ប.ឋ.ស | អនុ.ការិ.អ.យ.ក ខ័ណ្ឌសាលាក្រៅ ក្រុងប៉ៃលិន | ២៤-១១-០៤ | រោគាពាធ | ០៣៨ បល | - ៤១៤៨ |
| ២៤ | អេង ស៊ាង | ៦១ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាដំបងដែក ស្រុកកំពង់ត្រាច ខេត្តកំពត | ១៥-១២-០៤ | រោគាពាធ | ៦៣៤ កព | - ៤១៤៩ |
| ២៥ | ម៉ិញ ចំណាន | ៣១ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សានារាយណ៍ ស្រុកឈូក ខេត្តកំពត | ១៥-១២-០៤ | រោគាពាធ | ៤០៣៣កព | - ៤១៥០ |
| ២៦ | នូ គីមសួរ | ៥២ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាមានជ័យ ស្រុកពាមជរ ខេត្តព្រៃវែង | ១៨-១១-០៤ | ចុកពោះ | ៣២២១ ពវ | - ៤១៥១ |
| ២៧ | ចាន់ យុន | ៥២ | ស | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាពានា ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង | ៣០-១១-០៤ | លើសឈាម | ២៩១៥ ពវ | - ៤១៥២ |
| ២៨ | ម៉ុង សំណាង | ៤៨ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាព្រៃដង្ហំ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | ១៧-១២-០៤ | របេង | ១៦៧៩ ពវ | - ៤១៥៣ |
| ២៩ | ចាន់ ជួន | ៧២ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាឈើទាល ស្រុកពាមជរ ខេត្តព្រៃវែង | ២០-១២-០៤ | រោគាពាធ | ៦៨៩១ ពវ | - ៤១៥៤ |
| ៣០ | ថួម អ៊ី | ៥៤ | ស | គ្រូ ប.ឋ.ស | សាលាប.ឋ.សស្វាយទាប ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង | ២០-១២-០៤ | លើសឈាម | ២៩១១ ពវ | - ៤១៥៥ |
| ៣១ | នៅ ស៊ីណាត | ៣៧ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាក្តីកណ្តាល ស្រុកកំពង់លាវ ខេត្តព្រៃវែង | ០៤-០១-០៥ | រលាកខួរក្បាល | ២៣១៩ ពវ | - ៤១៥៦ |
| ៣២ | ស្វាយ ឆេង | ៥៣ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាក្បៀររាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង | ០៦-០១-០៥ | របេង | ១៦៤០ ពវ | - ៤១៥៧ |
| ៣៣ | ឈឹម វន់ | ៦២ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាកញ្ជ្រៀច ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង | ០២-០១-០៥ | រោគាពាធ | ៨៣៦ ពវ | - ៤១៥៨ |
| ៣៤ | ងួន គីមហាន | ៦៦ | ប | គ្រូ ម.ប.ភ | និវត្តជនអនុ.ស្វាយរមៀត ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង | ០៣-០១-០៥ | ទឹកនោមផ្អែម | ៧៩០ ពវ | - ៤១៥៩ |
| ៣៥ | ហួល ទូច | ៣២ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សអរញ្ញសាគរ ស្រុកសៀមរាប ខេត្តសៀមរាប | ២១-១២-០៤ | គ្រុនពោះវៀន | ៧៩៤ សរ | - ៤១៦០ |
| ៣៦ | អៀ ច័ន្ទម៉ុល | ៣៥ | ស | គ្រូ ម.ប.ភ | អនុ.បុរី១០០ខ្នង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ | ២០-១២-០៤ | រោគាពាធ | ៧៨២៦ ភព | - ៤១៦១ |
| ៣៧ | មាស គីមអាន | ៧៦ | ប | គ្រូ ប.ឋ.ស | និវត្តជន នា.ផែនការ គ្រប់គ្រងដោយគណៈកម្មាធិការនាយក | ១៦-១២-០៤ | លើសឈាម | ២១៤៥ តក | - ៤១៦២ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣៨ | ញ៉ែ ញ៉ានស៊ី | ៦៣ | ស | គ្រូ ប.បំ.ស | និវត្តជន សាលាវត្តកោះ គ្រប់គ្រងដោយគណៈកម្មាធិការនាយក | ១៨-១២-០៤ | រោគាពាធ | ១០១៦ តក | - ៤១៦៣ |
| ៣៩ | ច័ន្ទ ធី | ៣១ | ស | គ្រូ ម.ប.ភ | នាយកដ្ឋានអប់រំកុមារតូច ទីស្តីការអ.យ.ក. | ២០-១២-០៤ | គ្រោះថ្នាក់ចរាចរ | ៨៤៣កសន | - ៤១៦៤ |
| ៤០ | សាន់ តាំង | ៥១ | ប | គ្រូ ម.ប.ភ | នាយកដ្ឋានអប់រំកុមារតូច ទីស្តីការអ.យ.ក. | ២០-១២-០៤ | គ្រោះថ្នាក់ចរាចរ | ១៤១៩ កច | - ៤១៦៥ |
| ៤១ | ប៊ិន វស្នី | ៤៣ | ប | គ្រូ ប.បំ.ស | នាយកដ្ឋានអប់រំកុមារតូច ទីស្តីការអ.យ.ក. | ២០-១២-០៤ | គ្រោះថ្នាក់ចរាចរ | ៩៤១២កណ | - ៤១៦៦ |
| ៤២ | ទិន សុមិត្តា | ៣៩ | ស | គ្រូ ម.ទ.ភ | នាយកដ្ឋានអប់រំកុមារតូច ទីស្តីការអ.យ.ក. | ២៤-១២-០៤ | គ្រោះថ្នាក់ចរាចរ | ៩០២ តក | - ៤១៦៧ |
| ៤៣ | ជា ស៊ីផុល | ៥៦ | ស | គ្រូ ប.បំ.ស | សាលាបឋមសិក្សាអនុវត្តន៍ ទីស្តីការអ.យ.ក. | ១៤-១១-០៤ | គ្រោះថ្នាក់ចរាចរ | ២៦៨ តក | - ៤១៦៨ |
| ៤៤ | ប៊ុង យ៉ុន | ៦៧ | ស | គ្រូ ប.បំ.ស | និវត្តជន នា.មធ្យមសិក្សាចំណេះទូទៅ ទីស្តីការអ.យ.ក. | ២៩-១២-០៤ | រោគាពាធ | ៩៦៣ តក | - ៤១៦៩ |

**ខ. មរណភាពគូស្រករសមាជិក**

| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | មុខងារ | អង្គភាពបំរើការរបស់សមាជិក | ថ្ងៃ ខែ ឆ្នាំមរណៈ | មូលហេតុ | លេខបណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ១ | កុំ សាផុន | ៤៨ | ប | គ្រូបង្រៀន | ប្តីអ.ស ឈី គិមហេង សាលាអញ្ចាញ-មង្គលបុរី-បន្ទាយមានជ័យ | ១២-០៩-០៤ | ជំងឺថ្លើម | ២៤១៨ បជ | - ២៦៥៤ |
| ២ | ម៉ុត ឃន | ៦៤ | ប | គ្រូបង្រៀន | ប្តីអ.ស ហេង អេងណៃ វិ.មង្គលបុរី ខេត្តបន្ទាយមានជ័យ | ០៧-១០-០៤ | លើសឈាម | ៧០៥ បជ | - ២៦៥៥ |
| ៣ | ខៀវ យ៉ុវ | ៦៣ | ស | ធ្វើស្រែ | ប្រពន្ធលោក សយ វិចាន និវត្តជនស្រុកភ្នំស្រុក-បន្ទាយមានជ័យ | ១១-០៩-០៤ | រោគាពាធ | ១៥៥៩ បជ | - ២៦៥៦ |
| ៤ | ខយ ណៃហុន | ៦២ | ស | ធ្វើស្រែ | ប្រពន្ធលោក មូល ឈួន និវត្តជនស្រុកមង្គលបុរី-បន្ទាយមានជ័យ | ០២-១២-០៤ | រោគាពាធ | ២៣២១បជ | - ២៦៥៧ |
| ៥ | មាស ពៅ | ៦០ | ស | ធ្វើស្រែ | ប្រពន្ធលោក វៀប ឡោម ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ | ១៨-០៦-០៤ | រោគាពាធ | ១៤៣ ឧជ | - ២៦៥៨ |
| ៦ | កែ យ៉ា | ៥១ | ស | ធ្វើស្រែ | ប្រពន្ធលោក ឈាន សាង សាលាត្រពាំងប្រាសាទ-ឧត្តរមានជ័យ | ២៩-០៩-០៤ | រោគាពាធ | ៣៩៣ ឧជ | - ២៦៥៩ |
| ៧ | ប៊ិច សុគិត | ៣២ | ប | ឧស្សាហកម្ម | ប្តីអ.ស ស ស៊ីណាត សាលាប៊ូថង ស្រុកបាលុង ខេត្តមណ្ឌលគិរី | ៣០-១០-០៤ | ខ្យល់គរ | | - ២៦៦០ |
| ៨ | យិន សារិន | ៣៨ | ប | ធ្វើស្រែ | ប្តីអ.ស ប៉ែន ថេរ៉ាយុ សាលាសាមគ្គីរង្សី-ស្វាយទាប-ស្វាយរៀង | ០២-១០-០៤ | ជំងឺក្រពះ | ៤៣ ស្វរ | - ២៦៦១ |
| ៩ | សុខ សុផាន | ៣៥ | ប | ធ្វើស្រែ | ប្តីអ.ស ចាន់ ណារី សាលាស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ០៤-១០-០៤ | ជំងឺអាសន្នរោគ | ២០១២ ស្វរ | - ២៦៦២ |
| ១០ | ជីម ជីម | ៣៣ | ស | ធ្វើស្រែ | ប្រពន្ធលោក អ៊ុក ម៉ៅ សាលាស្វាយថ្លើម ស្រុកស្វាយជ្រំ-ស្វាយរៀង | ០៦-១០-០៤ | រោគាពាធ | ១៨៩៧ ស្វរ | - ២៦៦៣ |
| ១១ | អ៊ុង ឡេង | ៦៧ | ស | ធ្វើស្រែ | ប្រពន្ធលោក ម៉ី ផ្លូយ និវត្តជនស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ២៧-១១-០៤ | ជរាពាធ | ៣៦៥០ ស្វរ | - ២៦៦៤ |
| ១២ | ខៀវ ម៉េន | ៥៥ | ប | ធ្វើស្រែ | ប្តីអ.ស នៅ ប៊ុនយ៉ា សាលាចំបក់ ស្រុកបាទី ខេត្តតាកែវ | ២០-១១-០៤ | លើសឈាម | ១៨០៩ តក | - ២៦៦៥ |
| ១៣ | ឡេង លុន | ៥៤ | ស | ធ្វើស្រែ | ប្រពន្ធលោក ឡូច ឆន សាលាបន្ទាយរី ស្រុកបាទី ខេត្តតាកែវ | ១២-១១-០៤ | រោគាពាធ | ១៤៣៧តក | - ២៦៦៦ |
| ១៤ | សៅ ផុល | ៧០ | ស | ធ្វើស្រែ | ប្រពន្ធលោក គីម យាន និវត្តជនស្រុកបាទី ខេត្តតាកែវ | ២២-១១-០៤ | រោគាពាធ | ៥៣៥៣តក | - ២៦៦៧ |
| ១៥ | ហ៊ន អ៊ាវ | ៤៩ | ស | ធ្វើស្រែ | ប្រពន្ធលោក លន់ ហួយ សាលាក្តមសំណ-លើកដែក ខេត្តកណ្តាល | ០៤-១១-០៤ | រោគាពាធ | ២១៨៥កណ | - ២៦៦៨ |
| ១៦ | ស៊ុម ហៀង | ៥៤ | ស | ធ្វើស្រែ | ប្រពន្ធលោក ឌួន សួរ និវត្តជនស្រុកពញាឮ ខេត្តកណ្តាល | ០៥-១១-០៤ | រោគាពាធ | ១៦៨១កណ | - ២៦៦៩ |
| ១៧ | អ៊ុត ប៉េងឡុង | ៤៧ | ប | ធ្វើស្រែ | ប្តីអ.ស ឡេង ស៊ុនលី សាលាព្រែកអំបិល ស្រុកស្អាង-កណ្តាល | ០៥-១១-០៤ | ខ្យល់គរ | ៥៥៥៧កណ | - ២៦៧០ |
| ១៨ | ប៉ុល ណើ | ៥៤ | ស | ធ្វើស្រែ | ប្រពន្ធលោក អៀម ណុល សាលាប្រឡាយ-ប្រាសាទសំបូរ-កំពង់ធំ | ១៦-១១-០៤ | រោគាពាធ | ៧០១ កធ | - ២៦៧១ |
| ១៩ | អ៊ិន ណុំ | ៥៤ | ស | ធ្វើស្រែ | ប្រពន្ធលោក គាត់ អឿន សាលាអង្គរជាតិ-អង្គរជ័យ ខេត្តកំពត | ១០-១២-០៤ | រោគាពាធ | ២០២៤ កព | - ២៦៧២ |
| ២០ | ស្វ ជឿន | ៦០ | ស | ធ្វើស្រែ | ប្រពន្ធលោក រដ្ឋ ស៊ីថន សាលាក្របៅចាស់-កំចាយមារ-ព្រៃវែង | ០៧-១១-០៤ | រោគាពាធ | ២៧៧៤ ពវ | - ២៦៧៣ |
| ២១ | ចាន់ យុន | ៥២ | ស | គ្រូបង្រៀន | ប្រពន្ធលោក អ៊ូ ផេង សាលាពានា ស្រុកស៊ីធរកណ្តាល-ព្រៃវែង | ៣០-១១-០៤ | លើសឈាម | ២៥០៧ ពវ | - ២៦៧៤ |
| ២២ | ហួល ទូច | ៣២ | ប | គ្រូបង្រៀន | ប្តីអ.ស យ៉ន រតនៈ សាលាអរញ្ញសាគរ-សៀមរាប-សៀមរាប | ២១-១២-០៤ | គ្រុនពោះវៀន | ១៤៤៤ សរ | - ២៦៧៥ |
| ២៣ | ភិត សុភា | ៣៤ | ប | ប្រជាជន | ប្តីអ.ស ជុំ ពុទ្ធារី សាលាបាក់ទូក រាជធានីភ្នំពេញ | ០៦-០១-០៥ | ជំងឺថ្លើម | ១៣៧៧ភព | - ២៦៧៦ |
| ២៤ | ជួន ចន្ថា | ៥៤ | ស | ប្រជាជន | ប្រពន្ធលោក យូស វង ការិ.អ.យ.ក. ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | ១១-០១-០៥ | លើសឈាម | ១៤០២ ភព | - ២៦៧៧ |
| ២៥ | ហ៊ូ ហេមវណ្ណ | ៣៨ | ប | ប.កំពង់ផែ | ប្តីអ.ស ច័ន្ទ ធី នាយកដ្ឋានអប់រំកុមារតូច ទីស្តីការអ.យ.ក. | ២០-១២-០៤ | គ្រោះថ្នាក់ចរាចរ | ៨៤៣កសន | - ២៦៧៨ |

មេត្តាប្រមូលភាគទានឧបត្ថម្ភសពប្រចាំខែ **កុម្ភៈ** ឆ្នាំ ២០០៥ អោយទាន់ពេលវេលា ដើម្បីដោះស្រាយជូនគ្រួសារសព ។

**ចំណាំ:**

ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក.................... ៤៤ន x ៣០៛ = ១៣២០ រៀល

សពគូស្រករ.............................................. ២៥ន x ១៥៛ = ៣៨០ រៀល

ភាគទានប្រចាំខែ ................................................ = ១០០ រៀល

ភាគទានសាងសង់ផ្ទះគ្រូបង្រៀន.............................. = ៣០០ រៀល

**សរុប** = ២១០០រៀល

ភ្នំពេញ, ថ្ងៃទី ០៧ ខែ **កុម្ភៈ** ឆ្នាំ ២០០៥

**ជ.គណៈកម្មាធិការនាយក**

**អគ្គលេខាធិការរង**

**ស្វាយ និស្ស**

**សមាគមបុគ្គលិកសិក្សាខ្មែរ**
**គណៈកម្មាធិការនាយក**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ : ១៦/០៥ គ.ក.

# សេចក្ដីជូនដំណឹងមរណភាព

តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការនាយកនៃ ស.ប.ស.ខ
សូមសំដែងសេចក្ដីសោកស្ដាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខណ្ឌ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ក. មរណៈភាពសមាជិក | | | | | | | | | |
| ១ | អ៊ឹង សេងឆាយ | ៦០ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាស៊ីរ៉ុង ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ | ២៨-១១-០៤ | លើសឈាម | ៥៤៦កសន | សពទី៤១៧០ |
| ២ | សួន ចាន់ថៃ | ២៥ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ហ.ស មិត្តភាព ខ័ណ្ឌមិត្តភាព-ព្រះសីហនុ | ១៦-១២-០៤ | ជំងឺថ្លើម | ៣២២៣កសន | - ៤១៧១ |
| ៣ | ទូច ស៊ីម | ៣៣ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាឈើទាលជ្រុំ ស្រុកបាទី ខេត្តតាកែវ | ២៦-១២-០៤ | រោគាពាធ | ៦១៧៦តក | - ៤១៧២ |
| ៤ | ភី ប៊ុនតាន់ | ៦៦ | ប | កម្មករ | និវត្តជននៃ.អង្គរកា ស្រុកត្រាំកក់ ខេត្តតាកែវ | ០២-១២-០៤ | លើសឈាម | ៥៦៤៥ តក | - ៤១៧៣ |
| ៥ | ឈី សាន | ៣០ | ប | គ្រូ ម.ទ.ភ | អនុ.បរ-ហ.ស ភ្នំជីសូរ ស្រុកសំរោង ខេត្តតាកែវ | ១៥-១២-០៤ | ទឹកនោមផ្អែម | ៦៧២៣តក | - ៤១៧៤ |
| ៦ | ងិន វុទ្ធី | ៣៧ | ស | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាស្នារម ស្រុកសំរោង ខេត្តតាកែវ | ១៩-១២-០៤ | លើសឈាម | ៥៨៤៩ តក | - ៤១៧៥ |
| ៧ | ទួន ហ៊ិន | ៤៩ | ប | គ្រូ ម.ទ.ភ | វិ.ទន្លាប់ ស្រុកគិរីវង់ ខេត្តតាកែវ | ២៣-១២-០៤ | ជំងឺបេះដូង | ៣៩៥៣តក | - ៤១៧៦ |
| ៨ | ប៉ូច ស៊ុត | ៧៥ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកព្រៃកប្បាស ខេត្តតាកែវ | ២៧-០១-០៥ | រោគាពាធ | ៤៩០៧តក | - ៤១៧៧ |
| ៩ | ឌិម តុងភិន | ៦២ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកគិរីវង់ ខេត្តតាកែវ | ២៨-០១-០៥ | លើសឈាម | ៤៤៩៩ តក | - ៤១៧៨ |
| ១០ | កង វ៉ន | ៦៣ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកត្រាំកក់ ខេត្តតាកែវ | ១២-០១-០៥ | រោគាពាធ | ៥៤៦៧តក | - ៤១៧៩ |
| ១១ | ពៅ សេរ | ៥៦ | ប | គ្រូ ម.ប.ភ | អនុ.អង្គរុន ស្រុកត្រាំកក់ ខេត្តតាកែវ | ២០-០១-០៥ | រោគាពាធ | ២៣៨៤តក | - ៤១៨០ |
| ១២ | សុខ ខាន់ម៉ាច | ៣០ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាភូមិថស្វាយឃ្លាំង ស្រុកក្រូចឆ្មារ-កំពង់ចាម | ២២-១១-០៤ | រោគាពាធ | ៦២៣៩កច | - ៤១៨១ |
| ១៣ | យក់ ម៉េង | ៦៣ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាកងតាណឹង ស្រុកកងមាស-កំពង់ចាម | ១៨-១១-០៤ | លើសឈាម | ៨៣៥៧កច | - ៤១៨២ |
| ១៤ | យិន តែម | ៤៨ | ប | គ្រូ ម.ប.ភ | អនុ.ក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម | ១៩-១២-០៤ | លើសឈាម | ៦៦៥៤ កច | - ៤១៨៣ |
| ១៥ | ឈឹម អាន | ៥៥ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាអង្គរក្រៅ ស្រុកពញាក្រែក-កំពង់ចាម | ៣០-១២-០៤ | គ្រោះថ្នាក់ចរាចរ | ៦៨០៧កច | - ៤១៨៤ |
| ១៦ | រស់ ហាន | ៦០ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាអន្លង់ក្រេះ ស្រុកពញាក្រែក-កំពង់ចាម | ២៧-១២-០៤ | រោគាពាធ | ៦៦៩៦ កច | - ៤១៨៥ |
| ១៧ | ប្រាជ្ញ សុខុម | ៦០ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកក្រគរ ខេត្តពោធិ៍សាត់ | ២៤-១២-០៤ | រោគាពាធ | ១៦៧០ពស | - ៤១៨៦ |
| ១៨ | ផាន ផានិត | ២៤ | ប | គ្រូ ប.ឋ.ស | បុ.ការិ.អ.យ.ក. ស្រុកបាកាន ខេត្តពោធិ៍សាត់ | ១២-០១-០៥ | គ្រោះថ្នាក់ចរាចរ | ៣២៨៨ ពស | - ៤១៨៧ |
| ១៩ | មុី ហ៊ុំ | ៥៥ | ប | គ្រូ ប.ឋ.ស | សាលាស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ | ១៨-១១-០៤ | គ្រោះថ្នាក់ចរាចរ | ១៨៨៦ពស | - ៤១៨៨ |
| ២០ | បូ ចំរើន | ៣៥ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សក្រាំងតាសែន ស្រុកសំពៅមាស-ពោធិ៍សាត់ | ០៣-០១-០៥ | រោគាពាធ | ៥២០ ពស | - ៤១៨៩ |
| ២១ | ហុក សៃ | ៥០ | ប | គ្រូ ប.ឋ.ស | ប្រធានការិ.រដ្ឋបាលនៃមន្ទីរអ.យ.ក. ក្រុងប៉ៃលិន | ១១-០១-០៥ | រោគាពាធ | ០៩៥ បល | - ៤១៩០ |
| ២២ | លី កាងអៅ | ៥២ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាមាត់ពាម ស្រុកកំពត ខេត្តកំពត | ១០-០១-០៥ | រោគាពាធ | ២៦៥ កព | - ៤១៩១ |
| ២៣ | ដួង សម័យ | ៦៥ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាអង្គខ្នាយ ស្រុកអង្គរជ័យ ខេត្តកំពត | ២៣-០១-០៥ | រោគាពាធ | ១៩០៣កព | - ៤១៩២ |
| ២៤ | ឯម ផាត | ៥៦ | ប | គ្រូ ម.ប.ភ | វិ.ព្រះរាជសម្ភារ ស្រុកកំពង់បាយ ខេត្តកំពត | ១៧-០១-០៥ | លើសឈាម | ១១៨៥ កព | - ៤១៩៣ |
| ២៥ | សិទ្ធ ណារិន | ៦៥ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង | ២៧-១២-០៤ | រោគាពាធ | ៥០៣០ ពវ | - ៤១៩៤ |
| ២៦ | ប៉ែន យឹម | ៦៣ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាអង្គរស ស្រុកមេសាង ខេត្តព្រៃវែង | ២១-១០-០៤ | រោគាពាធ | ៥៦៥៤ ពវ | - ៤១៩៥ |
| ២៧ | គង់ សុភី | ៣៥ | ម | គ្រូ ម.ប.ភ | វិ.ហ.ស កំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង | ២២-០១-០៥ | រោគាពាធ | ២២១៦ ពវ | - ៤១៩៦ |
| ២៨ | អ៊ុច នី | ៦១ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាបារាំច ស្រុកមេសាង ខេត្តព្រៃវែង | ២២-១២-០៤ | រោគាពាធ | ៥៨០៦ ពវ | - ៤១៩៧ |
| ២៩ | ហ៊ុន ចាន់លាប | ៥០ | ស | គ្រូ ម.ប.ភ | វិ.រស្មីសាមគ្គី ស្រុកពាមជរ ខេត្តព្រៃវែង | ២១-០១-០៥ | ជំងឺថ្លើម | ៣៣៥២ ពវ | - ៤១៩៨ |
| ៣០ | តាំ ឡាញ់ | ៦៤ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលានគរក្រៅ ស្រុកសៀមរាប ខេត្តសៀមរាប | ១២-០១-០៥ | ជំងឺបេះដូង | ៥១៣ សរ | - ៤១៩៩ |
| ៣១ | ចៀម គ្រៃ | ៥១ | ប | គ្រូ ម.ប.ភ | វិ.ពួក ស្រុកពួក ខេត្តសៀមរាប | ០១-០១-០៥ | ខ្យល់គរ | ៣២៥៤ សរ | - ៤២០០ |
| ៣២ | ប៊ូ ចុន | ៦៥ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាអូរតាណឹង ស្រុកសំបូរ ខេត្តក្រចេះ | ០១-០១-០៥ | រោគាពាធ | ១៧១៥ ក្រច | - ៤២០១ |
| ៣៣ | ទូច ភន | ៦១ | ប | គ្រូ ម.ប.ភ | និវត្តជនការិ.អ.យ.ក. ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ០៧-១២-០៤ | រោគាពាធ | ១៩៧៣ កស្ព | - ៤២០២ |
| ៣៤ | ពុធ ឆាំ | ៥៥ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាវត្តកក់ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ | ៣០-០១-០៥ | រោគាពាធ | ២៩១០កស្ព | - ៤២០៣ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣៥ | សេក សម្បត្តិ | ៦៦ | ប | គ្រូ ម.ប.ភ | និវត្តជនអនុ.បាត់ជីង ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ | ២៩-១២-០៤ | រោគាពាធ | ៣៣៣៩កស្ព | - ៤២០៤ |
| ៣៦ | ពូល ធន | ៥៧ | ប | គ្រូ ប.ឋ.ស | សាលាជ្រៃហូរញ៉ៅ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | ២៨-១២-០៤ | រោគាពាធ | ៥៥៣ កស្ព | - ៤២០៥ |
| ៣៧ | អួង ចី | ៣១ | ប | គ្រូ ប.ឋ.ស | សាលាបឋមសិក្សាអង្គខ្មៅ ស្រុកសំរោងទង-កំពង់ស្ពឺ | ០៨-០៦-០៤ | រោគាពាធ | ៤២៦៤ កស្ព | - ៤២០៦ |
| ៣៨ | ប្រាក់ កំសាន្ត | ៣០ | ប | គ្រូ ម.ទ.ភ | វិ.បវេល ស្រុកបវេល ខេត្តបាត់ដំបង | ២៧-១២-០៤ | មហារីកសួត | ៧០១៩ បប | - ៤២០៧ |
| ៣៩ | រស់ សំណាង | ៤០ | ប | គ្រូ ម.ទ.ភ | វិ.ទេពប្រណម្យ ស្រុកពញាឮ ខេត្តកណ្ដាល | ២៤-១១-០៤ | ជំងឺថ្លើម | ៧៥៥៦កណ | - ៤២០៨ |
| ៤០ | ប៉ាន់ ស៊ុងួន | ៦២ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល | ២៥-១២-០៤ | រោគាពាធ | ៤៣០៦កណ | - ៤២០៩ |
| ៤១ | កែវ សុផន | ៤៦ | ស | គ្រូ ប.ឋ.ស | អនុ.សំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល | ១៨-១២-០៤ | រោគាពាធ | ៧១២៩ កណ | - ៤២១០ |
| ៤២ | ភួង ធឿន | ៦១ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ | ០១-១១-០៤ | របេង | ១៦០៣បជ | - ៤២១១ |
| ៤៣ | សួយ សួរ | ៥១ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សអូរអំបិល ស្រុកសិរីសោភ័ណ-បន្ទាយមានជ័យ | ២៣-០១-០៥ | ក្រិនថ្លើម | ២៣៧០ បជ | - ៤២១២ |
| ៤៤ | សៅ ហេង | ៦៨ | ប | គ្រូបច្ចេកទេស | និវត្តជននាយកដ្ឋានផែនការ គ្រប់គ្រងដោយគណៈកម្មាធិការនាយក | ១៦-០១-០៥ | រោគាពាធ | ១២៦៦គណ | - ៤២១៣ |

**ខ. មរណៈភាពគ្រួសារសមាជិក**

| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | មុខរបរ | អត្តភាពនៃគ្រួសាររបស់សមាជិក | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខបណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ១ | ងន ហៀក | ៤៧ | ស | ធ្វើស្រែ | ប្រពន្ធលោក ហ៊ីង ចន្ទី សាលាភ្នំមាស-ព្រៃកប្បាស-តាកែវ | ០៤-០១-០៥ | រោគាពាធ | ៤៧៧១តក | - ២៦៧៩ |
| ២ | ស៊ុម សំបូរ | ៣០ | ប | គ្រូបង្រៀន | ប្ដីអ.ស ប្រាក់ ពៅ សាលាចំប៉ាលើក ស្រុកត្រាំកក់-តាកែវ | ២០-១២-០៤ | រោគាពាធ | ៧៥៥៩តក | - ២៦៨០ |
| ៣ | ពុធ ម៉ារឌី | ៦៥ | ស | ធ្វើស្រែ | ប្រពន្ធលោក ច្រុង យុន និវត្តជនស្រុកកោះអណ្ដែត-តាកែវ | ១២-០១-០៥ | រោគាពាធ | ២២០៨តក | - ២៦៨១ |
| ៤ | ឡា គីមឡាយ | ៣៧ | ប | កសិករ | ប្ដីអ.ស សេក សុខឡា សាលាមេសរជ្រៃ-ស្ទឹងត្រង់-កំពង់ចាម | ១៦-០៨-០៤ | រោគាពាធ | ៥៩៥២កច | - ២៦៨២ |
| ៥ | ហ៊ាន សំអួន | ៣១ | ប | គ្រូបង្រៀន | ប្ដីអ.ស ម៉ូលីដា សាលាទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម | ១០-១១-០៤ | រោគាពាធ | ១១៧៥៥កច | - ២៦៨៣ |
| ៦ | សុខ ខាន់ម៉ាច | ៣០ | ប | គ្រូបង្រៀន | ប្ដីអ.ស សុខ ស៊ីណៃ សាលាភូមិថ្មស្វាយឃ្លាំង-ក្រូចឆ្មារ-កំពង់ចាម | ២២-១១-០៤ | រោគាពាធ | ១០៧១២កច | - ២៦៨៤ |
| ៧ | ហ៊ឹម ស៊ីមាន | ១៨ | ស | កសិករ | ប្រពន្ធលោក សំ សៃ អនុ.វង់តឹក ស្រុកស្រីសន្ធរ-កំពង់ចាម | ១៧-១១-០៤ | រោគាពាធ | ១២០៦៧ កច | - ២៦៨៥ |
| ៨ | ចេង សេត | ៥២ | ស | កសិករ | ប្រពន្ធលោក ភួង មាន សាលាកុមារជុំឡា ស្រុកជើងព្រៃ-កំពង់ចាម | ២០-១២-០៤ | រោគាពាធ | ២៤៥៣កច | - ២៦៨៦ |
| ៩ | ពេញ សាវ៉ន់ | ៤១ | ប | គ្រូបង្រៀន | ប្ដីអ.ស ផាន់ ផល្លី សាលាររកាអារ ស្រុកកងមាស-កំពង់ចាម | ២៨-០៨-០៤ | រោគាពាធ | ៨៦២៦កច | - ២៦៨៧ |
| ១០ | សូ សាម៉ល់ | ៣២ | ស | ធ្វើស្រែ | ប្រពន្ធលោក វ៉ា សុខុម វិ.ហ.ស ស្រុកស្វាយជ្រំ-ស្វាយរៀង | ០៣-១២-០៤ | គ្រោះថ្នាក់ចរាចរ | ៤៩៤ ស្វរ | - ២៦៨៨ |
| ១១ | ប្រាក់ ហេង | ៣៩ | ស | ធ្វើស្រែ | ប្រពន្ធលោក ពត ធូ សាលាបឋម.៧មករា ខេត្តស្វាយរៀង | ០៤-១២-០៤ | ជំងឺបេះដូង | ២៩៥ ស្វរ | - ២៦៨៩ |
| ១២ | មាស ពៅ | ៥១ | ស | ធ្វើស្រែ | ប្រពន្ធលោក គីម សារិន នាយកសាលាឃ្លាំងមឿង-បាកាន-ពោធិ៍សាត់ | ១៣-១១-០៤ | រលាកសាច់ដុំ | | - ២៦៩០ |
| ១៣ | ហ៊ុន ចាន់ណាប | ៥០ | ស | គ្រូបង្រៀន | ប្រពន្ធលោក ប៊ូ សក្ដដា វិ.រស្មីសាមគ្គី ស្រុកពាមជ-ព្រៃវែង | ២១-០១-០៥ | ជំងឺថ្លើម | ៣៣៨៥៧ | - ២៦៩១ |
| ១៤ | ចៀម ត្រៃ | ៥១ | ប | គ្រូបង្រៀន | ប្ដីអ.ស ស្រី សារី សាលាព្រៃក្មេង ស្រុកពួក-សៀមរាប | ០១-០១-០៥ | ខ្សោយតម្រងនោម | ៣១១០សរ | - ២៦៩២ |
| ១៥ | ជេត ឈិត | ៥១ | ប | កម្មករ | ប្ដីអ.ស ប៉ែន សារ៉េន វិ.វត្តស្វាយ ស្រុកនិងខេត្តសៀមរាប | ០៩-០១-០៥ | មហារីកថ្លើម | ៣៤១ សរ | - ២៦៩៣ |
| ១៦ | ព្រំ ប៊ុណ្ណា | ៤៦ | ប | ឆត្រីយ៍ | ប្ដីអ.ស ឌូ សៀងឌី សាលាអូរកំបុត ស្រុកឯកភ្នំ-បាត់ដំបង | ១៧-១២-០៤ | រោគាពាធ | ៤៧៥១បប | - ២៦៩៤ |
| ១៧ | អ៊ិន សាត | ៤៨ | ស | ធ្វើស្រែ | ប្រពន្ធលោក អៀម សម្បត្តិ សាលាបវេល ស្រុកបវេល-បាត់ដំបង | ២៧-១២-០៤ | ជំងឺថ្លើម | ៣០៥៩បប | - ២៦៩៥ |
| ១៨ | សុខ សុវណ្ណច័ន្ទ | ៤៦ | ប | អង្គភាពឃុំ | ប្ដីអ.ស ស សិរិទ្ធ អា.អ.ឃ.ក. ស្រុកបាត់ដំបង-បាត់ដំបង | ០៧-០២-០៥ | លើសឈាម | ៧៣៣បប | - ២៦៩៦ |
| ១៩ | ខឹម សាឌន | ៤៤ | ប | កសិករ | ប្ដីអ.ស លី សុវណ្ណ សាលាក្រុមព្រះរាជឫទ្ធិ-កណ្ដាលស្ទឹង-កណ្ដាល | ១៣-១២-០៤ | រោគាពាធ | ៤៦៤០កណ | - ២៦៩៧ |
| ២០ | សួន ទន | ៤២ | ប | កសិករ | ប្ដីអ.ស រេត មុំ សាលាជួនស ស្រុកកៀនស្វាយ-កណ្ដាល | ០១-០១-០៥ | រោគាពាធ | ៧០៨៨កណ | - ២៦៩៨ |
| ២១ | ប៊ិន រស្មី | ៤៤ | ប | គ្រូបង្រៀន | ប្ដីអ.ស លី គិមខៀង មជ្ឈមណ្ឌលគរុកោសល្យ-កណ្ដាល | ២០-១២-០៤ | គ្រោះថ្នាក់ចរាចរ | ៣៨២៤កណ | - ២៦៩៩ |
| ២២ | សោ គិមស៊ុន | ៦២ | ប | ប្រជាជន | ប្ដីអ.ស ជាំង ចាន់ធុណា សាលាព្រះពន្លា-សិរីសោភ័ណ-បន្ទាយមានជ័យ | ២៤-០១-០៥ | ជំងឺបេះដូង | ០៥៥៧បជ | - ២៧០០ |
| ២៣ | ឈៀក សុងហាក់ | ៤៤ | ប | ប្រជាជន | ប្ដីអ.ស ហួត ណាងអាយ សាលាជ័យជំនះ-ចំការមន-រាជធានីភ្នំពេញ | ០១-០២-០៥ | រោគាពាធ | ៦១០៤ភព | - ២៧០១ |
| ២៤ | យស់ ចាន់ថាច | ៥៣ | ស | មេផ្ទះ | ប្រពន្ធលោក ម៉ុំ ណេទី អនុ.ទឹកល្អក់ រាជធានីភ្នំពេញ | ០៦-០២-០៥ | រោគាពាធ | ៦១៩៨ភព | - ២៧០២ |
| ២៥ | យូ សៅ | ៣៣ | ប | ប្រជាជន | ប្ដីអ.ស ប៉ុ សុខឃីម សាលាឫស្សីកែវ រាជធានីភ្នំពេញ | ០៤-០២-០៥ | រោគាពាធ | ៣៨៨៦ភព | - ២៧០៣ |

មេត្តាប្រមូលភាគទានឧបត្ថម្ភសពប្រចាំខែ **មីនា** ឆ្នាំ ២០០៥ អោយទាន់ពេលវេលា ដើម្បីដោះស្រាយជូនគ្រួសារសព ។

**ចំណាំ:** ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក..................... ៤៤ᵃ x ៣០៛ = ១៣២០ រៀល

សពគ្រួសារ............................................. ២៥ᵃ x ១៥៛ = ៣៨០ រៀល

ភាគទានសាងសង់ផ្ទះគ្រូបង្រៀន........................................ = ៣០០ រៀល

**សរុប** = ២១០០រៀល

ភ្នំពេញ, ថ្ងៃទី ០៣ ខែ **មីនា** ឆ្នាំ ២០០៥

**ជ.គណៈកម្មាធិការនាយក**

**អគ្គលេខាធិការរង**

**ស្វាយ និត្យ**

# ភ្នំពេញកាលពី១០០ឆ្នាំមុន



ព្រែកឧកញ៉ាផុង(សួនច្បារមុខស្ថានីយរថភ្លើងបច្ចុប្បន្ន)
ឯនាយបន្តិចគឺស្ពាននាគ (ចំមហាវិថីព្រះនរោត្តម)




ស្ពានដែក ឆ្លងកាត់ព្រែកឧកញ៉ាផុង (ចំតិរវិថីព្រះស៊ីសុវត្ថិបច្ចុប្បន្ន)